18K-CA079-柬埔寨文：三摩地釋義-字.pdf 1 2019/8/5 下午 03:16:13

# សមាធិនិទ្ទេស

ព្រះគ្រូវិរិយមុនីវិសុទ្ធិញាណ អ.រស. រសបញ្ញោ

អាចារ្យបង្រៀននៅសាលាបាឡីជាន់ខ្ពស់ ក្រុងភ្នំពេញ

តែងនិងរៀបរៀង

កុង្សីយសេនាបតី បានអនុញ្ញាត

និងសម្តេចព្រះសង្ឃនាយកទាំងពីរគណៈយល់ព្រម

**ភ្នំពេញ**

**ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ**

**បោះពុម្ពចែកជាធម្មទាន**

**ព.ស. ២៥៦៣** **គ.ស. ២០១៩**

CA079

**សមាធិនិទ្ទេស**

**Samādhiniddesa**

As this is a Dhamma text,
we request that it be treated with respect.
If you are finished with it,
please pass it on to others or
offer it to a monastery, school or public library.
Thanks for your co-operation.
**Namo Amitabha!**

《柬埔寨文：三摩地釋義 Samādhiniddesa》
財團法人佛陀教育基金會 印贈
Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Website: www.budaedu.org ; overseas@budaedu.org,
**This book is for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
CA079

# សមាធិនិទ្ទេសសង្ខេប

ព្រះគ្រូវីរិយមុនីវិសុទ្ធិញាណ អ.រស. រសបញ្ញោ

អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

តែងនិងរៀបរៀង

កុង្សីយសេនាបតី បានអនុញ្ញាត

និងសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈយល់ព្រម


**ភ្នំពេញ**

**ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ**

**បោះពុម្ពចែកជាធម្មទាន**

**ព.ស. ២៥៦៣** **គ.ស. ២០១៩**

# សមាធិនិទ្ទេសសង្ខេប

## *សាសនគុណកថា*

ក្នុងខាងដើមនេះ នឹងពណ៌នានូវគុណនៃព្រះពុទ្ធសាសនា ដោយសង្ខេបទុកជាមុន ដើម្បីនឹងបង្ហូរនូវទឹកចិត្តនៃកុលបុត្រ អ្នកមានសទ្ធាក្នុងព្រះពុទ្ធសាសនា ឲ្យយាងចុះដោយស្រួល កាន់សមាធិភាវនា ។

ធម្មជាតិអ្វីដែលលោកហៅថា "ពុទ្ធសាសនា?" មានគ្រឿងអាងដូចម្ដេច?

បើពោលដោយរួបរួមមកសំដៅយកសីល សមាធិ បញ្ញា តែ ៣ ប៉ុណ្ណោះឯង ដែលលោកហៅថា "ពុទ្ធសាសនា" អាងមានពាក្យលោកពោលទុកថា "ពុទ្ធសាសនានេះ មានសីលជាខាងដើម សមាធិជាកណ្ដាល បញ្ញាជាខាងចុងបំផុត" ។ ន័យមួយទៀតថា សីលបាត់ទុកជាគុណល្អគួររាប់ថ្នាក់ខាងដើមនៃសាសនា (អាទិកល្យាណ) ព្រោះនាំមកនូវអវិប្បដិសារាទិគុណ(១) សមាធិបាត់ទុកជាគុណល្អគួររាប់ថ្នាក់

---

១- គុណមានមិនក្ដៅក្រហាយចិត្តជាដើម ។

កណ្ដាលនៃសាសនា (មជ្ឈេកល្យាណ) ព្រោះនាំមកនូវឥទ្ធិវិធាទិគុណ(១) បញ្ញារាប់ទុកជាគុណល្អគួររាប់ថ្នាក់ខាងចុងបំផុតនៃសាសនា (បរិយោសានកល្យាណ) ព្រោះនាំមកនូវតាទិភាព(២) ។ ព្រោះហេតុនោះ បុគ្គលដែលបានឈ្មោះថាជាអ្នកជឿតាម កាន់តាមព្រះពុទ្ធសាសនានោះ លុះតែបានប្រតិបត្តិត្រង់ទៅតាមថ្នាក់នៃព្រះពុទ្ធសាសនាទាំង ៣ នេះ យ៉ាងហោចត្រឹមថ្នាក់ណានីមួយក្ដី ។

ព្រះពុទ្ធសាសនាទាំង ៣ ថ្នាក់នេះ មានគុណអាចនឹងហុចប្រយោជន៍មកឲ្យដល់បុគ្គលដែលប្រតិបត្តិតាម ប្លែកគ្នាដូចម្ដេចខ្លះ?

សីល ញុំាងបុគ្គលដែលប្រតិបត្តិតាមឲ្យបាននូវវិជ្ជា ៣, សមាធិ ឲ្យបាននូវអភិញ្ញា ៦, បញ្ញាឲ្យបាននូវបដិសម្ភិទា ៤ ។

សីល ញុំាងបុគ្គលដែលប្រតិបត្តិតាម ឲ្យវៀរបង់នូវកាមសុខល្លិកានុយោគបាន, សមាធិ ឲ្យវៀរបង់នូវអត្តកិលមថានុយោគបាន, បញ្ញា ឲ្យសេពនូវមជ្ឈិមាបដិបទាបាន ។

---

១- គុណមានប្លែងឫទ្ធិបានជាដើម ។២-ភាពជាអ្នកមិនរំភើបក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ។

សីល ញុំាងបុគ្គលដែលប្រតិបត្តិតាមឲ្យកន្លងនូវអបាយ-ភូមិបាន, សមាធិ ឲ្យកន្លងនូវកាមធាតុបាន, បញ្ញា ឲ្យកន្លងនូវភពទាំងអស់បាន ។

សីល ញុំាងបុគ្គលដែលប្រតិបត្តិតាម ឲ្យលះបង់នូវកិលេសបានដោយតទង្គប្បហាន, សមាធិ ឲ្យលះបង់នូវកិលេសបានដោយវិក្ខម្ភនប្បហាន, បញ្ញា ឲ្យលះបង់នូវកិលេសបានដោយសមុច្ឆេទប្បហាន ។

សីល ញុំាងបុគ្គលដែលប្រតិបត្តិតាម ឲ្យផ្ចាញ់នូវវីតិក្កម-ទោសនៃកិលេសទាំងឡាយបាន(១), សមាធិ ឲ្យផ្ចាញ់នូវបរិយុដ្ឋាននៃកិលេសទាំងឡាយបាន(២), បញ្ញា ឲ្យផ្ចាញ់នូវអនុស័យនៃកិលេសទាំងឡាយបាន(៣) ។

សីល ញុំាងបុគ្គលដែលប្រតិបត្តិតាមឲ្យជម្រះនូវសង្កិលេស-ធម៌គឺទុច្ចរិតទាំង ៣ បាន, សមាធិ ឲ្យជម្រះនូវសង្កិលេសធម៌

---

១- ទោសកំហុសដែលកិលេសយ៉ាងគ្រោតគ្រាតបណ្តាលឲ្យប្រព្រឹត្តកន្លងក្នុងទ្វារទាំង ៣ ។

២- កិរិយាដែលកិលេសយ៉ាងកណ្តាលគ្របសង្កត់នូវកុសលចិត្តទុកមិនឲ្យប្រព្រឹត្តទៅបាន ។

៣- កិរិយាដែលកិលេសយ៉ាងល្អិតតាមដេកត្រាំនៅក្នុងចិត្ត ទទ្ទឹងចាំមានបច្ច័យគួរកើតឡើងបានក៏កើតឡើង ។

គឺតណ្ហាបាន, បញ្ញា ឲ្យជម្រះនូវសង្កិលេសធម៌គឺទិដ្ឋិបាន ។

សីល ញ៉ាំងបុគ្គលដែលប្រតិបត្តិតាម ឲ្យដល់នូវភាពជាសោតាបន្នបុគ្គល និងសកទាគាមិបុគ្គលបាន, សមាធិ ឲ្យដល់នូវភាពជាអនាគាមិបុគ្គលបាន, បញ្ញា ឲ្យដល់នូវភាពជាព្រះអរហន្តបាន ។

*សាសនគុណកថា ចប់*

# ប្រភេទនៃសមាធិ

ព្រះយោគាវចរកុលបុត្រ កាលបើបានឃើញគុណរបស់ព្រះពុទ្ធសាសនាដូចបានពណ៌នាមកយ៉ាងនេះហើយ ពេលដែលបានបំពេញសីលបរិបូណ៌ហើយ គប្បីចម្រើននូវសមាធិ-បិត្តជាលំដាប់តទៅទៀត ។

ធម្មជាតអ្វីដែលហៅថា “សមាធិ”? សមាធិនោះមានប៉ុន្មានយ៉ាង?

ភាពរបស់ចិត្តជាកុសល ដែលតម្កល់នៅស្មើល្អក្នុងអារម្មណ៍តែមួយ ហៅថា “សមាធិ” ។

សមាធិនោះ មានច្រើនប្រការពេកណាស់ តែដែល

នឹងត្រូវនាំមកពោលក្នុងទីនេះតែ ២ យ៉ាង ។

សមាធិទាំង ២ យ៉ាងនោះគឺ

១- លោកិយសមាធិ សមាធិជាលោកិយ គឺភាពរបស់ចិត្តជាកុសលដែលតម្កល់នៅស្មើល្អក្នុងអារម្មណ៍តែ ១ ប្រព្រឹត្តទៅក្នុងភូមិ ៣ គឺកាមភូមិ ១ រូបភូមិ ១ អរូបភូមិ ១ ។

២- លោកុត្តរសមាធិ សមាធិជាលោកុត្តរៈ គឺភាពរបស់ចិត្តដែលតម្កល់នៅស្មើល្អក្នុងអារម្មណ៍តែ ១ សម្បយុត្តដោយអរិយមគ្គ ។

បណ្ដាសមាធិទាំង ២ យ៉ាងនេះ ដែលនឹងត្រូវនាំយកមកអធិប្បាយក្នុងសមាធិភាវនានេះ បំពោះតែលោកិយសមាធិម្យ៉ាងប៉ុណ្ណោះ ឯលោកុត្តរសមាធិ មិនបាននាំយកមកអធិប្បាយឡើយ ព្រោះលោកសង្គ្រោះចូលក្នុងបញ្ញាភាវនា ។

ក៏លោកិយសមាធិនោះសោតលោកបែកចេញជា ២ យ៉ាងតទៅទៀតគឺ

១- ឧបចារសមាធិ ភាពរបស់ចិត្តជាកុសលដែលតម្កល់នៅស្មើល្អក្នុងអារម្មណ៍តែ ១ ក្នុងឧបចារភូមិ គឺភូមិដែលជិត

នឹងបានឈាន ជាបុព្វភាគនៃអប្បនាសមាធិ ។

២- អប្បនាសមាធិ ភាពរបស់ចិត្តជាកុសលដែលតម្កល់នៅស្មើល្អក្នុងអារម្មណ៍តែ ១ ក្នុងបដិលាភភូមិ គឺភូមិដែលបានឈានហើយ ។

ក្នុងសមាធិទាំង ២ យ៉ាងនេះ ឧបចារសមាធិ ជាកាមាវចរ ឯអប្បនាសមាធិជារូបាវចរនិងអរូបាវចរ បើក្នុងបញ្ញាភាវនាជាលោកុត្តរៈ ។

## វិធីរៀនយកនូវកម្មដ្ឋាន

### ពាក្យផ្តើម

កាលបើព្រះយោគាវចរកុលបុត្រមានប្រាថ្នាដើម្បីនឹងបម្រើននូវសមាធិ ដូចសម្តែងមកនេះ ក៏គប្បីជម្រះនូវសីលរបស់ខ្លួនឲ្យបរិសុទ្ធជាមុន បន្ទាប់អំពីនោះមក បើបលិពោធគឺសេចក្តីកង្វល់ទាំង ១០ យ៉ាងបលិពោធណាមួយកើតឡើង ត្រូវផ្តាច់បង់បេញ ហើយចូលទៅកាន់សំណាក់អាចារ្យអ្នកបង្រៀននូវកម្មដ្ឋានដែលជាកល្យាណមិត្ត រៀនយកនូវកម្មដ្ឋានទាំង ៤០ កម្មដ្ឋានណាមួយដែលសមគួរដល់ចរិតរបស់ខ្លួន ហើយរៀរ

បង់នូវវិហារដែលមិនសមគួរដល់សមាធិភាវនា បេញទៅនៅក្នុងវិហារដែលសមគួរដល់សមាធិភាវនា ផ្តាច់បង់នូវបលិពោធដែលតូចៗបេញ ហើយគប្បីចម្រើននូវកម្មដ្ឋានឲ្យត្រឹមត្រូវតាមរបៀបនៃវិធីចម្រើនឲ្យសព្វគ្រប់ ។

*កិច្ចត្រូវជម្រះសីល*

ត្រង់ដែលថាត្រូវជម្រះសីលឲ្យបរិសុទ្ធជាមុននោះ មានពាក្យបុច្ឆាជ្រែកចូលមកថា : បើព្រះយោគីចម្រើននូវសមាធិភាវនាតែម្តង មិនទាន់បានជម្រះសីលឲ្យបរិសុទ្ធជាមុន តើនឹងអាចញ៉ាំងគុណវិសេសឲ្យកើតបានឬទេ? ព្រោះហេតុអ្វី?

មិនអាចញ៉ាំងគុណវិសេសឲ្យកើតឡើងបានឡើយ ព្រោះសន្តានចិត្តរបស់បុគ្គលទ្រុស្តសីលតែងមានវិប្បដិសារីអស់កាលជានិច្ច មិនមែនជាទីតាំងនៅនៃគុណវិសេសឡើយ ធម្មតាទោសទ្រុស្តសីលកុំថាឡើយដល់ធំ សូម្បីតែទុក្កដាបត្តិ ១ យ៉ាងតូចដែលប្រកបដោយចិត្តក្លែង ក៏ធ្វើឲ្យអន្តរាយដល់គុណវិសេសមានសមាធិជាដើមបាន ហេតុនោះត្រូវតែជម្រះសីលឲ្យបរិសុទ្ធជាមុនតាមសមគួរដល់ភេទជាគ្រហស្ថឬបព្វជិត ។

## *បលិពោធ*

ត្រង់ដែលថាត្រូវផ្តាច់បង់នូវបលិពោធទាំង ១០ យ៉ាង នោះ តើបលិពោធអ្វីខ្លះ? ត្រូវផ្តាច់បង់ដូចម្តេច?

បលិពោធទាំង ១០ យ៉ាងនោះគឺ

១- អាវាសបលិពោធ កង្វល់ដោយគ្រប់គ្រងទីលំនៅ ។

២- កុលបលិពោធ កង្វល់ដោយជាប់ជំពាក់នៅក្នុងត្រកូលញាតិឬត្រកូលរបស់ឧបដ្ឋាក ។

៣- លាភបលិពោធ កង្វល់ដោយទទួលលាភ គឺកង្វល់ដោយធ្វើអនុមោទនាឬសម្តែងធម៌ដល់ទាយក។

៤- គណបលិពោធ កង្វល់ដោយពួកលោកអ្នករៀនព្រះសូត្រឬពួកលោកអ្នករៀនព្រះអភិធម្ម គឺកង្វល់ដោយការបង្រៀន ។

៥- កម្មបលិពោធ កង្វល់ដោយការងារ គឺកង្វល់ដោយធ្វើការងារខ្លួនឯងឬបាត់បង្គាប់ឲ្យគេធ្វើ ។

៦- អទ្ធានបលិពោធ កង្វល់ដោយដើរដំណើរផ្លូវឆ្ងាយ ។

៧- ញាតិបលិពោធ កង្វល់ដោយថែទាំព្យាបាលជំងឺ

របស់ញាតិ គឺអាចារ្យនិងឧបជ្ឈាយ៍ជាដើម ឬមាតានិងបិតាជាដើម ។

៨- អាហារបលិពោធ កង្វល់ដោយព្យាបាលរោគរបស់ខ្លួន ។

៩- គន្ថបលិពោធ កង្វល់ដោយរៀនព្រះបរិយត្តិ ។

១០- ឥទ្ធិបលិពោធ កង្វល់ដោយរក្សាទុកនូវឫទ្ធិជារបស់បុថុជ្ជន តែឫទ្ធិនេះជាកង្វល់ដល់វិបស្សនា មិនមែនជាកង្វល់ដល់សមាធិឡើយ គឺត្រូវឱ្យលោកអ្នកចម្រើននូវវិបស្សនាផ្តាច់បង់ចេញ ។

វិធីដែលនឹងផ្តាច់បង់នូវបលិពោធទាំង ១០ យ៉ាងនេះ ត្រូវផ្តាច់បង់ដោយហេតុ ២ យ៉ាង គឺដោយលះបង់ចេញម្យ៉ាងដោយធ្វើបង្ហើយម្យ៉ាង (ណាដែលគួរលះបង់ចេញបាន ត្រូវលះបង់ចេញ ណាដែលមិនគួរលះបង់ចេញបានត្រូវធ្វើបង្ហើយ) ។

*កល្យាណមិត្តកថា*

លោកដែលហៅថា “កល្យាណមិត្ត” គួរធ្វើជាអាចារ្យ

បង្រៀននូវកម្មដ្ឋានបាននោះ តើបែបដូចម្តេច?

លោកដែលហៅថា "កល្យាណមិត្ត" នោះសំដៅយកលោកណាដែលមានសទ្ធា ជឿប្រាជ្ញាពោធិញ្ញាណរបស់ព្រះតថាគត ជឿកម្មនិងផលរបស់កម្ម មានសីលបរិសុទ្ធជាទីស្រឡាញ់ និងជាទីគោរពសរសើរនៃមនុស្សនិងទេវតាទាំងពួង ជាអ្នកតិះដៀលបុគ្គលបាប ជាអ្នកអត់ធ្មត់ ជាអ្នកបេះបរមត្ថធម៌ដ៏ជ្រាលជ្រៅ មិនដែលប្រកបការអាក្រក់ មានសេចក្តីសន្តោស ជាអ្នកប្រាថ្នាតិច មិនជំពាក់ដោយគ្រហស្ថ មានព្យាយាមមិនខ្ជិលច្រអូស មានស្មារតីតម្កល់ខ្ជាប់ មានចិត្តតម្កល់មាំមិនរាយមាយ ជាអ្នកមានប្រាជ្ញាយល់ត្រូវ ជាពហុស្សូតបេះចាំពុទ្ធវចនៈច្រើន ជាអ្នកអៀនខ្មាសអំពើបាបគ្រប់ជំពូក ។ បុគ្គលដែលជាកល្យាណមិត្តគួរយកធ្វើជាអាចារ្យបង្រៀននូវកម្មដ្ឋាននោះមានទំនងដូច្នេះឯង ។

*កិច្ចត្រូវប្រគល់ខ្លួនចំពោះអាចារ្យ*

វេលាដែលចូលទៅកាន់សំណាក់អាចារ្យជាកល្យាណមិត្តដូចពោលមកនេះ ដើម្បីរៀនយកនូវកម្មដ្ឋាននោះ បើជា

បព្វជិតត្រូវប្រព្រឹត្តតាមគមិកវត្តនិងអាចរិយវត្ត ឲ្យសព្វគ្រប់ លុះដល់ប្រោរព្ធនឹងរៀន ត្រូវប្រគល់ខ្លួនចំពោះអាចារ្យថា “**ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ** (ប្រែថា) បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាសូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់” ។

ក្នុងកិច្ចដែលប្រគល់ខ្លួននេះមានអានិសង្សដូចម្តេចខ្លះ?

មានអានិសង្សនឹងធ្វើខ្លួន ឲ្យលុះក្នុងអំណាចរបស់អាចារ្យ ឲ្យជាអ្នកប្រដៅងាយ មិនប្រព្រឹត្តទៅតាមអំពើចិត្ត អាចារ្យសោតលោកក៏នឹងសង្គ្រោះដោយផ្លូវអាមិសនិងផ្លូវធម៌គ្រប់ជំពូក ។

បើបែរជាមិនប្រគល់ខ្លួនដូច្នេះវិញទេ នឹងមានទោសដូចម្តេច?

នឹងទៅជាបុគ្គលមិនគួរឲ្យអាចារ្យ លោកគម្រាមកំហែងស្តីប្រដៅបាន ព្រះយោគាវចរកុលបុត្រនោះនឹងទៅជាបុគ្គលប្រដៅក្រ មិនប្រព្រឹត្តតាមឱវាទ ចង់ទៅទីណាក៏ទៅតាមទំនើងចិត្ត ហើយអាចារ្យក៏លោកមិនបានសង្គ្រោះដោយផ្លូវអាមិសនិងផ្លូវធម៌ លោកមិនបង្រៀនសេចក្តីណាដែលជាអាថ៌

កំបាំងជ្រាលជ្រៅ, កាលបើដូច្នេះ ព្រះយោគាវចរកុលបុត្រនោះ នឹងទៅជាបុគ្គលមិនមានទីពឹងអាស្រ័យ នឹងបែរទៅជាប្រព្រឹត្តទ្រុស្តសីលវិលបាកភេទទៅវិញក៏សឹងមាន ហេតុនោះត្រូវតែប្រគល់ខ្លួន ដូចន័យដែលបានពោលមកនេះ ។

*អជ្ឈាសយធម៌ ៦ យ៉ាង*

ព្រះយោគាវចរកុលបុត្រ កាលបើបានប្រគល់ខ្លួនចំពោះអាចារ្យជាកល្យាណមិត្តរូបហើយ ត្រូវប្រកបដោយអជ្ឈាសយធម៌ ៦ យ៉ាង ដែលប្រព្រឹត្តទៅដើម្បីធ្វើប្រាជ្ញាពោធិញ្ញាណឱ្យបាស់ក្លា ។

*អជ្ឈាសយធម៌ ៦ យ៉ាងនោះគឺ*

១- **អលោភជ្ឈាសយ** ត្រូវមានអធ្យាស្រ័យមិនលោភជាអ្នកឃើញទោសក្នុងសេចក្តីលោភ ។

២- **អទោសជ្ឈាសយ** ត្រូវមានអធ្យាស្រ័យមិនប្រទូស្តជាអ្នកឃើញទោសក្នុងសេចក្តីប្រទូស្ត ។

៣- **អមោហជ្ឈាសយ** ត្រូវមានអធ្យាស្រ័យមិនវង្វេងជាអ្នកឃើញទោសក្នុងសេចក្តីវង្វេង ។

៤- **នេក្ខម្មជ្ឈាសយ** ត្រូវមានអធ្យាស្រ័យបេញចាកកាម ឬបេញបួស ជាអ្នកឃើញទោសក្នុងឃរាវាស ។

៥- **បវិវេកជ្ឈាសយ** ត្រូវមានអធ្យាស្រ័យពេញចិត្ត ក្នុងទីស្ងាត់ ជាអ្នកឃើញទោសក្នុងការប្រឡូកដោយពួក ។

៦- **និស្សរណជ្ឈាសយ** ត្រូវមានអធ្យាស្រ័យពេញចិត្ត នឹងរលាស់ខ្លួនបេញចាកភព ជាអ្នកឃើញទោសក្នុងដំណើរ ទៅកាន់ភពទាំងឡាយ ។

សព្វត្ថកកម្មដ្ឋាន បារិហារិយកម្មដ្ឋាន

ត្រង់ដែលថារៀនយកនូវកម្មដ្ឋាននោះ តើអ្វីហៅថា "កម្មដ្ឋាន"? បានសេចក្ដីដូចម្ដេច? មានប៉ុន្មានយ៉ាង?

អារម្មណ៍ដែលគួរបម្រើនឲ្យកើតសតិសម្បជញ្ញៈ និងគុណវិសេសផ្សេងៗ មានសមាធិជាដើម លោកហៅថា "កម្មដ្ឋាន" បានសេចក្ដីថា ហេតុជាទីតាំងនៃភាវនាកម្ម គឺជាអារម្មណ៍សម្រាប់ធ្វើបរិកម្មភាវនា ម្យ៉ាងទៀតថា ហេតុជាទីតាំងនៃអំពើព្យាយាមដើម្បីនឹងបម្រើននូវសមាធិភាវនា ឬជាហេតុនឹងឲ្យកើតភាវនាកម្មបំណែកជាន់លើ ។

កម្មដ្ឋានក្នុងទីនេះលោកចែកចេញជា ២ យ៉ាងគឺ

១- សព្វត្ថកកម្មដ្ឋាន កម្មដ្ឋានដែលមានប្រយោជន៍ដល់ព្រះយោគីកុលបុត្រ(១) គ្រប់ចរិតទាំងអស់ ទោះចរិតណាក្តី ត្រូវតែសេពជាមុន ។

២- បារិហារិយកម្មដ្ឋាន កម្មដ្ឋានទាំង ៤០ មានបឋវីកសិណជាដើម កម្មដ្ឋានណាមួយ ដែលសមគួរដល់ចរិតដែលព្រះយោគីចម្រើនបានហើយ ត្រូវរក្សាទុកជាបទដ្ឋាន(២) នៃភាវនាកម្មជាន់លើ ។

សព្វត្ថកកម្មដ្ឋាន លោកសំដៅយកកម្មដ្ឋាន ៣ គឺ

(ក) មេត្តា ត្រូវចម្រើនមេត្តាចិត្ត បំពោះភិក្ខុសង្ឃក្នុងសីមា បំពោះទេវតាដែលស្ថិតនៅក្នុងសីមា បំពោះឥស្សរជនក្នុងគោចរគ្រាម ដរាបដល់សព្វសត្វទាំងអស់ថា “**សុខិតា ភវន្តុ អព្យាបជ្ឈា** សូមឲ្យបានសេចក្តីសុខ កុំបីមានទុក្ខទោសអ្វីឡើយ” ។

(ខ) មរណស្សតិ ត្រូវរឭកដល់សេចក្តីស្លាប់របស់ខ្លួន

---

១- កុលបុត្រអ្នកមានព្យាយាម (ប្រើពាក្យនេះជំនួសពាក្យថា យោគាវចរកុលបុត្រ

២- ហេតុដែលជិត ។

ថា “**អវស្សំ មយា មរិតព្វំ** អញគង់តែនឹងស្លាប់ដោយពិត” ។

(គ) អសុភសញ្ញា ត្រូវសម្គាល់អារម្មណ៍ថាជារបស់មិនស្អាត ។

អានិសង្សក្នុងកិរិយាចម្រើនសព្វត្ថកកម្មដ្ឋាន ទាំង ៣ នេះដូចម្ដេចខ្លះ?

ចម្រើនមេត្តាចិត្ត នឹងបាននៅរួមជាសុខមួយអន្លើដោយភិក្ខុសង្ឃផងគ្នា ទេវតានឹងថែរក្សា តស្សរជននឹងជួយឃុំគ្រងទំនុកបម្រុង ទោះបីនឹងត្រាច់ទៅកាន់ទីណាក៏តតមានទើសទាល់ចិត្ត ។ ចម្រើនមរណស្សតិ នឹងបានលះបង់នូវកិរិយាស្វែងរកចិញ្ចឹមជីវិតមិនគួរ នឹងមានសេចក្ដីសង្វេគ នឹងមិនមានចិត្តរួញរាខ្ជិលប្រអូស ។ល។ ចម្រើនអសុភសញ្ញា ចិត្តនឹងមិនប្រកៀកប្រកាន់អារម្មណ៍ដោយសេចក្ដីលោភ ។

ឯបារិហារិយកម្មដ្ឋាន មិនបានអធិប្បាយក្នុងទីនេះឡើយ ព្រោះជាសេចក្ដីពិស្ដារក្រៃពេក ទុករួបរួមពោលទៅខាងចុង ។

*ចរិត ៦ យ៉ាង*

ត្រង់ដែលថារៀនយកនូវកម្មដ្ឋានទាំង ៤០ កម្មដ្ឋាន

ណាមួយតាមសមគួរដល់ចរិតរបស់ខ្លួននោះ អ្វីហៅថា "ចរិត"? មានប៉ុន្មានយ៉ាង? ត្រូវសម្គាល់ដឹងបានដូចម្ដេច?

លំនាំប្រព្រឹត្តជាប្រក្រតី ឬសំណាមវាសនាដែលធ្លាប់សន្សំអប់រំទុកមកអំពីអតីតជាតិ ហើយមកផុសផុរឡើងក្នុងសន្ដានដោយច្រើន ក្នុងបច្ចុប្បន្នជាតិនេះ ហៅថា "ចរិត ឬចរិយា" បែកដោយសង្ខេបមាន ៦ យ៉ាងគឺ(១)

១- រាគចរិត លំនាំរាគ គឺច្រើនដោយសេចក្ដីតម្រេក ។

២- ទោសចរិត លំនាំទោស គឺច្រើនដោយសេចក្ដីប្រទុស្ដ ។

៣- មោហចរិត លំនាំមោហ គឺច្រើនដោយសេចក្ដីវង្វេង ។

៤- សទ្ធាចរិត លំនាំសទ្ធា គឺច្រើនដោយសេចក្ដីជឿ ។

---

១- ក្នុងអភិធម្មត្ថវិភាវិនី លោកសម្ដែងចរិតដោយពិស្ដារមានដល់ ៦៣, អាចារ្យខ្លះថាមានដល់ ៦៤។

៥- ពុទ្ធិចរិត លំនាំប្រាជ្ញា គឺច្រើនដោយសេចក្ដីចេះដឹង ។

៦- វិតក្កចរិត លំនាំវិតក្ក គឺច្រើនដោយសេចក្ដីត្រិះរិះ ។

បុគ្គលក្នុងលោកបំប្រួញមកមានតែ ៦ ពួក បានឈ្មោះតាមចរិតទាំង ៦ នេះឯង គឺតាមដោយមានចរិតណាមួយផុសផុរឡើងក្នុងសន្ដានច្រើន ត្រូវសម្គាល់ដឹងបានថាបុគ្គលនេះជារាគចរិតឬជាចរិតណាមួយ នោះដោយពិនិត្យសង្កេតមើលឥរិយាបថ សង្កេតមើលស្នាដៃធ្វើការងារ សង្កេតមើលកិរិយាបរិភោគភោជន សង្កេតមើលកិរិយាក្រឡេកឃើញរូបជាដើម សង្កេតមើលធម៌ដែលប្រព្រឹត្តនៅក្នុងសន្ដាន ។

បុគ្គលដែលជារាគចរិត ដំណើរដើរជាប្រក្រតី ទ្រង់រំពាស់ ញ៉េងញ៉ង លើកដាក់ជើងស្មើ ទ្រង់ថ្នមៗ ផ្ទៃបាទជើងផត ដានជើងកំពុងកណ្ដាល ជំហរនិងបង្ហុយទ្រង់សុភាពរម្យទមគួរឲ្យជ្រះថ្លា តាក់តែងទីដំណេកស្មើៗ មិនរណ្ដោងរណោង ប្រមូលអវយវៈតូចធំឲ្យមូលគ្នា ទើបប្រះខ្លួនដេក

មើលក្រោកក៏សន្សឹមៗ និយាយពាក្យទ្រង់ស្រទន់ ធ្វើការងារច្រើនស្អាត ស្លៀកដណ្ដប់ច្រើនបរិមណ្ឌល ច្រើនពេញចិត្តបរិភោគភោជនដែលស្និទ្ធនឹងបង្អែម ពួតពំនួតបាយជាបរិមណ្ឌល ទំពាហ្មត់ទើបលេប បានអ្វីបន្តិចបន្តួចឆាប់ត្រេកអរ ឃើញរូបល្អ ឮសំឡេងពីរោះជាដើមឆាប់ជាប់ចិត្ត ខំសម្លក់ឬផ្ទៀងស្ដាប់អស់កាលយូរ ផ្គាប់ផ្គុនបន្តិចបន្តួចឆាប់គាប់មិនសូវប្រកាន់ទោសគេ បេញដើរទៅទីណាច្រើនអាល័យទីកន្លែង មានធម៌ប្រព្រឹត្តនៅក្នុងសន្ដាន ច្រើនបិទបាំងទោសខ្លួន ច្រើនអំនួត ច្រើនប្រកាន់ខ្លួន ច្រើនប្រាថ្នាលាមកច្រើនប្រាថ្នាធំ មិនសន្ដោស ច្រើនក្រអឺតក្រទម ឆ្មើងឆ្មៃ ។

បុគ្គលដែលជាទោសចរិត ដើរដំណើរទ្រង់កាយដីដោយចុងម្រាម លើកដាក់ជើងរហ័ស ដានជើងធ្ងន់ជ្រៅខាងមុខ ជំហរនិងបង្គុយមានអាការទ្រង់រឹង រៀបចំទីដំណេកតូងតាងព្រួសប្រះតាមតែបាន ប្រះខ្លួនដេកខ្លាំង ដេកបងចិញ្ចើមធ្វើមុខក្រញូវក្រោករហ័ស និយាយសំដីទ្រង់ដូចជាខឹង ធ្វើការងារដៃធ្ងន់ មិនស្អាត ស្លៀកដណ្ដប់ច្រើនរឹតណែនមិនបរិមណ្ឌល ច្រើនពេញ

ចិត្តបរិភោគភោជនដែលសៅហ្មងនិងម្ហូរ បរិភោគធ្វើឲ្យទ្វេញ ថ្លាល់ ឆាប់លេបមិនសូវទំពាឲ្យហ្មត់ បានអ្វីមិនល្អឆាប់តូចចិត្ត ឃើញរូបឬស្តាប់សំឡេងមិនជាទីគាប់ចិត្ត ចិត្តទ្រង់ដូចជាលំបាក ណាស់ សម្លឹងឬស្តាប់មិនបានយូរ ឆាប់ប្រកាន់ទោសគេ ផ្គាប់ផ្គុនមិនសូវគាប់ ចេញដើរទៅទីណាមិនមានអាល័យ កន្លែង មានធម៌ប្រព្រឹត្តនៅក្នុងសន្តាន ច្រើនក្រោធ ច្រើន សន្សំរឿងទុក ច្រើនបំភ្លេចគុណគេ ច្រើនលើកខ្លួនផ្ទឹមស្មើ នឹងលោកអ្នកធំ ច្រើនប្រណែន ច្រើនកំណាញ់ ។

បុគ្គលដែលជាមោហចរិត ដើរដំណើរទ្រង់រឡេមរឡាម លើកដាក់ជើងទ្រង់ដូចជាភ័យ ដានជើងធ្ងន់ខាងក្រោយ ជំហរ និងបង្គុយមានអាការទ្រង់រឹករវរខ្ជីខ្ជា រៀបចំទីដំណេកមាន សណ្ឋានមិនល្អ ប្រះខ្លួនដេកច្រើនប្រងេងប្រងាង ច្រើន ដេកផ្កាប់មុខ គេដាស់ច្រើនថ្ងូរហ៊ុះៗ ក្រោកយឺត ធ្វើការងារ ចាប់កាន់ធូរៗ គ្រវីសគ្រវាសលំៗប្លោលៗ ស្លៀកដណ្តប់ ទ្រង់រយីករយាកខ្ជីខ្ជាតាមតែបាន ពេញចិត្តបរិភោគភោជន មិនទៀងម្តងនេះម្តងនោះ បរិភោគធ្វើពំនូតបាយតូចៗ ចោល

គ្រាប់បាយរោយរាយក្នុងភាជន៍ ច្រើនបរិភោគឲ្យប្រឡាក់មាត់ ច្រើនបរិភោគមានចិត្តរាយមាយ គិតពីនេះពីនោះបណ្ដើរ ឃើញរូបឬស្ដាប់សំឡេងជាដើម ច្រើនបណ្ដោយតាមគេ បើគេនិន្ទាក៏និន្ទាតាម បើគេសរសើរក៏សរសើរតាម បើម្នាក់ឯង ច្រើនព្រងើយៗ មានធម៌ប្រព្រឹត្តនៅក្នុងសន្ដាន ច្រើនធុញទ្រាន់ងងុយដេក មានចិត្តអណ្ដែតអណ្ដូង ច្រើនក្ដៅក្រហាយស្ដាយក្រោយ ច្រើនសង្ស័យ ប្រកាន់ត្រង់ណាមាំត្រង់នោះ លះបង់បានក្រ ។

ឯបុគ្គលដែលជាសទ្ធាចរិត ពុទ្ធិចរិត និងវិតក្កចរិត ឥរិយាបថ ស្នាដៃធ្វើការងារ កិរិយាបរិភោគភោជន កិរិយាក្រឡេកឃើញរូបជាដើម មានទំនងប្រហែលៗគ្នានឹងចរិត ៣ ខាងដើមដែរ គឺសទ្ធាចរិត ប្រហែលគ្នានឹងរាគចរិត ពុទ្ធិ-ចរិត ប្រហែលគ្នានឹងទោសចរិត វិតក្កចរិត ប្រហែលគ្នានឹងមោហចរិត តែបើទុកណាជាដូច្នោះ ក៏គង់មានលំនាំផ្សេងគ្នាខ្លះ គួយ៉ាងដូចរាគ តែងស្វែងរកវត្ថុកាម មិនលះបង់អំពើឥតប្រយោជន៍ ឯសទ្ធា តែងស្វែងរកសីលាទិគុណ មិន

លះបង់អំពើដែលមានប្រយោជន៍, ទោសក្នុងពួកខាងអកុសល មិនមានស្នេហាជាប់នៅក្នុងអារម្មណ៍ តែងស្វែងរកទោស ដែលមិនពិត ប្រព្រឹត្តទៅដើម្បីវៀរបង់នូវសត្វ ឯពុទ្ធិ គឺបញ្ញា ក្នុងពួកខាងកុសល មិនមានស្នេហាជាប់នៅក្នុងអារម្មណ៍ តែងស្វែងរកទោសដែលពិត ប្រព្រឹត្តទៅដើម្បីវៀរបង់នូវសង្ខារ មោហ តាំងនៅមិននឹងនួន ដោយវង្វេងភាន់ តែងឃ្លេងឃ្លោង ដោយយាងបុះមិនស៊ប់ ឯវិតក្ក តាំងនៅមិននឹងនួន ដោយ ត្រិះរិះនូវហេតុផ្សេងៗ តែងឃ្លេងឃ្លោង ឬឆ្លេឆ្លាដោយគំនិត រហ័ស តែងធម៌ដែលប្រព្រឹត្តនៅក្នុងសន្តានផ្សេងៗ គ្នា ។

បុគ្គលដែលជាសទ្ធាចរិត មានធម៌ប្រព្រឹត្តនៅក្នុងសន្តាន ច្រើនលះបង់បរិច្ចាគទាន ច្រើនប្រាថ្នាចង់ឃើញព្រះអរិយ ចង់ស្តាប់ព្រះសទ្ធម្ម ច្រើនដោយសេចក្តីអំណររីករាយ មិន អួតអាងខ្លួន មិនបិទបាំងទោសខ្លួន ជ្រះថ្លាក្នុងហេតុដែល គួរជ្រះថ្លា ។

បុគ្គលដែលជាពុទ្ធិចរិត មានធម៌ប្រព្រឹត្តនៅក្នុងសន្តាន ជាអ្នកប្រដៅងាយ សេពគប់តែកល្យាណមិត្ត ដឹងប្រមាណ

ក្នុងភោជន មានសតិសម្បជញ្ញៈ ជាអ្នកភ្ញាក់រឭក តែង សង្វេគក្នុងហេតុដែលគួរសង្វេគ ប្រើនតាំងទុកនូវព្យាយាម ដោយឧបាយប្រាជ្ញា ។

បុគ្គលដែលជាវិតក្កចរិត មានធម៌ប្រព្រឹត្តនៅក្នុងសន្តានច្រើន ពោលតិរច្ឆានកថាលេងសើច ច្រើនត្រេកអរក្នុងពួក មិនសូវ ត្រេកអរក្នុងការកសាងកុសល ច្រើនកាន់ការមិនបំពោះ ពេល យប់បែកគំនិតហុយដូចផ្សែង ពេលថ្ងៃចាត់ការក្តៅក្រហាយ ដូចភ្លើងឆេះ គំនិតច្រើនរវើរវាយ ឆ្វេឆ្វា នេះបន្តិច នោះបន្តិច ។

ត្រូវសម្គាល់ដឹងបានថា បុគ្គលនេះជាចរិតនេះ បុគ្គល នោះជាចរិតនោះ តាមលំអានដែលបានពោលមកនេះឯង ។

គួរឲ្យមានសេចក្តីសង្ស័យកើតឡើងថា ហេតុអ្វីក៏បាន ជាបណ្តាលឲ្យមនុស្សទាំងពួងមានចរិតផ្សេងៗ គ្នាដូច្នេះ?

ព្រោះកាលអំពីអតីតជាតិធ្លាប់ប្រព្រឹត្តដូច្នោះ ហើយ វាសនានោះ ក៏ជិតជាប់តាមមក ឬកាលដែលគាត់តែងធ្វើ កុសលណាមួយក្នុងអតីតភព ហើយធម៌ទាំងនោះ ណាមួយ មានកម្លាំងក្លាតាំងនៅក្នុងសន្តាន ដល់ពេលដែលធ្វើមរណៈ-

កាល បើកុសលនោះហុចបដិសន្ធិឲ្យមក សំណាមរបស់ធម៌នោះ ក៏ជាប់ដោយតាមមកផង ហេតុនោះ ទើបមនុស្សក្នុងលោកមានចរិតខុសគ្នាដូច្នេះឯង ។

*អាការ ១០ យ៉ាង*

ត្រង់ដែលថាត្រូវរៀនយកកម្មដ្ឋានទាំង ៤០ កម្មដ្ឋានណាមួយ ដែលសមគួរដល់ចរិតរបស់ខ្លួននោះ តើកម្មដ្ឋានទាំង ៤០ អ្វីខ្លះ? បណ្ដាចរិតទាំង ៦ យ៉ាង តើកម្មដ្ឋានណាសមគួរដល់ចរិតណា?

មុនដែលនឹងដឹងអំពីរឿងនេះ ត្រូវដឹងអាការ ១០ យ៉ាងជាមុនសិន គង់នឹងដឹងបានឯងជាខាងក្រោយ(១) ។

អាការទាំង ១០ យ៉ាងនោះគឺ

១- សង្ខាតនិទ្ទេស ត្រូវដឹងអាការដែលលោកសម្ដែងបេញរាប់បំនួននៃកម្មដ្ឋាន ។

២- ឧបចារប្បនាវហ ត្រូវដឹងកម្មដ្ឋានដែលនាំមកនូវឧបចារជ្ឈាន និងកម្មដ្ឋានដែលនាំមកនូវអប្បនាឈាន ។

---

១- កម្មដ្ឋាន ត្រូវមើលត្រង់អាការទី ១ កម្មដ្ឋានដែលសមគួរដល់ចរិត ត្រូវមើលត្រង់អាការទី ១០ ។

៣- ឈានប្បភេទ ត្រូវដឹងប្រភេទរបស់ឈាន ។

៤- សមតិក្កម ត្រូវដឹងវិធីប្រព្រឹត្តកន្លងរបស់កម្មដ្ឋាន ។

៥- វឌ្ឍនាវឌ្ឍន ត្រូវដឹងកម្មដ្ឋាន ដែលគួរបម្រើនថែមនិងកម្មដ្ឋានដែលមិនគួរបម្រើនថែម ។

៦- អារម្មណ៍ ត្រូវដឹងអារម្មណ៍របស់កម្មដ្ឋាន ។

៧- ភូមិ ត្រូវដឹងភូមិរបស់កម្មដ្ឋាន ។

៨- គហណ ត្រូវដឹងកិច្ចដែលត្រូវរៀនយកនូវកម្មដ្ឋាន

៩- បច្ចយ ត្រូវដឹងបច្ច័យរបស់កម្មដ្ឋាន ។

១០- ចរិយានុកូល ត្រូវដឹងកម្មដ្ឋានដែលសមគួរដល់ចរិត ។

*អធិប្បាយអាការទី១- កម្មដ្ឋាន ៤០*

ត្រង់សង្ខាតនិទ្ទេសទី ១ ដែលថាត្រូវឲ្យដឹងអាការដែលលោកសម្តែងចេញរាប់តាមចំនួននៃកម្មដ្ឋាននោះ គឺត្រូវដឹងថាកម្មដ្ឋានមាន ៤០ គឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤(១) អារុប្ប ៤ សញ្ញា ១ វវដ្ឋាន ១ រួមត្រូវជា ៤០ ។

១- ជួនណាលោកហៅថា "អប្បមញ្ញា" ។

## កសិណ ១០

១- បឋវីកសិណ យកដីធ្វើជាវង់កសិណ ។

២- អាបោកសិណ យកទឹកធ្វើជាកសិណ ។

៣- តេជោកសិណ យកភ្លើងធ្វើជាកសិណ ។

៤- វាយោកសិណ យកខ្យល់ធ្វើជាកសិណ ។

៥- នីលកសិណ យកវត្ថុមានពណ៌ខៀវជាកសិណ ។

៦- បីតកសិណ យកវត្ថុមានពណ៌លឿងជាកសិណ ។

៧- លោហិតកសិណ យកវត្ថុមានពណ៌ក្រហមជាកសិណ ។

៨- ឱទាតកសិណ យកវត្ថុមានពណ៌សជាកសិណ។

៩- អាកាសកសិណ យកអាកាសដែលកំណាត់ទុកជាកសិណ ។

១០- អាលោកកសិណ យកពន្លឺជាកសិណ ។

*អសុភ ១០*

១- ឧទ្ធុមាតក   អសុភហើមពោរពងឡើង ។

២- វិនីលក    អសុភហើមមានពណ៌ខៀវដោយច្រើន ។

៣- វិបុព្វក    អសុភហើមមានខ្ទុះហូរទៅក្នុងខាងលើ ខាងក្រោម ។

៤- វិច្ឆិទ្ទក    អសុភដែលគេកាត់ដាច់ពាក់កណ្តាលខ្លួន

៥- វិក្ខាយិតក  អសុភដែលសត្វខាំកកេរស៊ីមានសំណាម រលុះរលួយផ្សេងៗ ។

៦- វិក្ខិត្តក    អសុភដែលគេកាត់ដាច់បេញពីគ្នាជាកំណាត់ៗ រាត់រាយទៅផ្សេងៗ ។

៧- ហតវិក្ខិត្តក អសុភដែលគេកាប់សាប់មានស្នាមសាំរវាម  ។

៨- លោហិតក អសុភត្រូវប្រហារមានឈាមហូរស្រោបស្រព ។

៩- បុឡុវក    អសុភមានដង្កូវបុះហូរបេញតាមទ្វារទាំង៩  ។

១០- អដ្ឋិក អសុភមានតែរាងឆ្អឹងរាត់រាយខ្ចាត់ខ្ចាយផ្សេងៗ ។

*អនុស្សតិ ១០*

១- ពុទ្ធានុស្សតិ សេចក្តីរឭករឿយៗ មានពុទ្ធគុណជាអារម្មណ៍ ។

២- ធម្មានុស្សតិ សេចក្តីរឭករឿយៗ មានធម្មគុណជាអារម្មណ៍ ។

៣- សង្ឃានុស្សតិ សេចក្តីរឭករឿយៗ មានសង្ឃគុណជាអារម្មណ៍ ។

៤- សីលានុស្សតិ សេចក្តីរឭករឿយៗ មានសីលគុណជាអារម្មណ៍ ។

៥- ចាគានុស្សតិ សេចក្តីរឭករឿយៗ មានចាគគុណជាអារម្មណ៍ ។

៦- ទេវតានុស្សតិ សេចក្តីរឭករឿយៗ មានសទ្ធាទិ-គុណរបស់ទេវតា និងសទ្ធាទិគុណរបស់ខ្លួនជាអារម្មណ៍ ។

៧- មរណានុស្សតិ សេចក្តីរឭករឿយៗ មាន

សេចក្ដីស្លាប់ជាអារម្មណ៍ ។

៨- កាយគតាសតិ សេចក្ដីរឭកតាំងចុះក្នុងកាយ មានកោដ្ឋាសនិមិត្ត(១) នៃអាការមានសក់ជាដើម ជាអារម្មណ៍ ។

៩- អានាបានស្សតិ សេចក្ដីរឭកមានអស្សាស បស្សាសនិមិត្ត(២) ជាអារម្មណ៍ ។

១០- ឧបសមានុស្សតិ សេចក្ដីរឭករឿយៗ មានគុណរបស់ព្រះនិព្វាន ដែលជាទីរម្ងាប់នូវទុក្ខទាំងពួង ជាអារម្មណ៍ ។

## *ព្រហ្មវិហារ ៤*

១- មេត្តា ផ្សាយមេត្តាដល់សព្វសត្វទាំងអស់ ។

២- ករុណា ផ្សាយករុណាដល់សព្វសត្វទាំងអស់ ។

៣- មុទិតា ផ្សាយមុទិតាដល់សព្វសត្វទាំងអស់ ។

៤- ឧបេក្ខា ផ្សាយឧបេក្ខាដល់សព្វសត្វទាំងអស់ ។

## *អារុប្ប ៤*

១- អាកាសានញ្ចាយតន យកអាកាសក្នុងបដិភាគ

---

**១- និមិត្តរបស់ចំណែកនៃអាការទាំង៣២ មានសក់ជាដើម ។**

**២- និមិត្តរបស់ខ្យល់ដង្ហើមចេញចូល ។**

និមិត្តដែលកើតអំពីកសិណ ៩ លើកអាកាសកសិណបេញ ដែលមិនមានទីបំផុតមកជាអារម្មណ៍ ។

២- វិញ្ញាណញ្ចាយតន ស្រាវយកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅ មិនមានទីបំផុតមកជាអារម្មណ៍ ។

៣- អាកិញ្ចញ្ញាយតន កំណត់យកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅ មិនមានកង្វល់តិចតួចមកជាអារម្មណ៍ ។

៤- នេវសញ្ញានាសញ្ញាយតន កំណត់យកសេចក្ដីល្អិត របស់អរូបវិញ្ញាណទី ៣ ដែលមានស្ទើរតែនឹងមិនមានមក ជាអារម្មណ៍ ។

សញ្ញា ១ នោះ សំដៅយកអាហារបដិកូលសញ្ញា ដែល ព្រះយោគាវចរ ពិចារណាអាហារដោយបដិកូល ។

វវដ្ឋាន ១ នោះ សំដៅយកបតុធាតុវវដ្ឋាន ដែល ព្រះយោគាវចរពិចារណាកំណត់ធាតុទាំង ៤ ក្នុងករជកាយ ។ រួមទាំងអស់ត្រូវជាកម្មដ្ឋាន ៤០ ។

អធិប្បាយអាការទី ២ - កម្មដ្ឋានដែលនាំមកនូវ ឧបចារដ្ឋាននិងអប្បនាឈាន ។

ត្រង់ឧបចារប្បនាវហទី ២ ដែលថាត្រូវឲ្យដឹងកម្មដ្ឋាន ដែលនាំមកនូវឧបចារជ្ឈាន និងកម្មដ្ឋានដែលនាំមកនូវអប្បនា-ឈានតោះ គឺត្រូវឲ្យដឹងថា អនុស្សតិ ៨ លើកកាយគតា-សតិ ១ អានាបានស្សតិ ១ ចេញ និងសញ្ញា ១ វវដ្ឋាន ១ រួមត្រូវជា ១០ កម្មដ្ឋាន ទាំង ១០ នេះ មានអំណាចនាំមកបានតែត្រឹមឧបចារជ្ឈាន កម្មដ្ឋាន ៣០ ក្រៅអំពីនេះ សុទ្ធតែមានអំណាចនាំមកបានដល់អប្បនាឈាន ។

*អធិប្បាយអាការទី ៣- ប្រភេទរបស់កម្មដ្ឋាន*

ត្រង់ឈានប្បភេទទី ៣ ដែលថាត្រូវឲ្យដឹងប្រភេទរបស់ឈានតោះ គឺត្រូវឲ្យដឹងថា បណ្ដាកម្មដ្ឋានទាំង ៣ ដែលនាំមកបានដល់អប្បនាឈានតោះ កម្មដ្ឋាន ១១ គឺ កសិណ ១០ អានាបានស្សតិ ១ មានអំណាចឲ្យសម្រេចបានតាំងអំពីបឋមជ្ឈាន រហូតដល់ចតុត្ថជ្ឈាន បើឈានចតុក្កន័យ បើជាបញ្ចកន័យវិញ រហូតដល់បញ្ចមជ្ឈាន កម្មដ្ឋាន ១១ ទៀត គឺ អសុភ ១០ កាយគតាសតិ ១ មានអំណាចឲ្យសម្រេចបាន តែត្រឹមបឋមជ្ឈានប៉ុណ្ណោះ

ព្រហ្មវិហារ ៣ ខាងដើម គឺ មេត្តា ១ ករុណា ១ មុទិតា ១ មានអំណាចឲ្យសម្រេចបានតាំងអំពីបឋមជ្ឈាន រហូតដល់តតិយជ្ឈាន បើឈានបតុក្កន័យ, បើជាបញ្ចកន័យវិញ រហូតដល់បតុត្ថជ្ឈាន ព្រហ្មវិហារទី ៤ គឺឧបេក្ខា ១ និងអារុប្ប ទាំង ៤ ត្រូវជា ៥ មានអំណាចឲ្យសម្រេចដល់បតុត្ថជ្ឈាន ក្នុងបតុក្កន័យ ឬបញ្ចមជ្ឈានក្នុងបញ្ចកន័យតែម្តង តែបើឧបេក្ខា-ព្រហ្មវិហារឲ្យសម្រេចខាងរូបជ្ឈាន ឯអារុប្បទាំង ៤ ឲ្យសម្រេចខាងអរូបជ្ឈាន ។

*អធិប្បាយអាការទី ៤ - កម្មដ្ឋានដែលកន្លងអង្គនិងកន្លងអារម្មណ៍*

ត្រង់សមតិក្កមទី ៤ ដែលថាត្រូវឲ្យដឹងវិធីប្រព្រឹត្តកន្លងរបស់កម្មដ្ឋាននោះ គឺត្រូវឲ្យដឹងថា វិធីប្រព្រឹត្តកន្លងរបស់កម្មដ្ឋានមាន ២ យ៉ាងគឺ

១- អង្គសមតិក្កម ប្រព្រឹត្តកន្លងនូវអង្គ ។

២- អារម្មណសមតិក្កម ប្រព្រឹត្តកន្លងនូវអារម្មណ៍ ។

កម្មដ្ឋានដែលមានអំណាចឲ្យសម្រេចបាន តាំងអំពីបឋមជ្ឈានដរាបដល់តតិយជ្ឈាន និងកម្មដ្ឋានដែលមាន

អំណាចឲ្យសម្រេចបាន តាំងអំពីបឋមជ្ឈាន ដរាបដល់ចតុត្ថជ្ឈាន នោះរមែងប្រព្រឹត្តកន្លងនូវអង្គ ព្រោះព្រះយោគាវចរនឹងចូលដល់ឈានជាន់លើ លុះតែកន្លងនូវអង្គរបស់ឈានជាន់ក្រោមមានវិតក្កនិងវិចារជាដើមទៅជាលំដាប់ ទើបចូលបាន ឯឧបេក្ខាព្រហ្មវិហារទៀតសោតក៏ដូចគ្នា ព្រោះព្រះយោគាវចរនឹងចូលទៅដល់បាន លុះតែកន្លងនូវអង្គសោមនស្ស របស់មេត្តាព្រហ្មវិហារជាដើម អារុប្បកម្មដ្ឋានទាំង ៤ រមែងប្រព្រឹត្តកន្លងនូវអារម្មណ៍ គឺអារុប្បទី ១ ប្រព្រឹត្តកន្លងនូវកសិណទាំង ៩ ក្រៅអំពីអាកាសកសិណចេញ, អារុប្ប ៣ ខាងចុង ប្រព្រឹត្តកន្លងនូវអារម្មណ៍មានអាកាសជាដើម ព្រោះព្រះយោគាវចរដែលមានប្រាថ្នានឹងចូលកាន់ឈាន ក្នុងកម្មដ្ឋានទាំង ៤ នេះ លុះតែប្រព្រឹត្តកន្លងនូវអារម្មណ៍ដូចពោលមកហើយយ៉ាងនេះ ទើបអាចចូលដល់បាន ។

*អធិប្បាយអាការទី ៥-កម្មដ្ឋានដែលគួរចម្រើនបន្ថែមនិងមិនគួរចម្រើនបន្ថែម*

ត្រង់វិឌ្ឍនាវិឌ្ឍនទី ៥ ដែលជាត្រូវឲ្យដឹងកម្មដ្ឋានដែលគួរបម្រើនបន្ថែម និងកម្មដ្ឋានដែលមិនគួរបម្រើនបន្ថែមនោះ គឺ

ត្រូវឲ្យដឹងថា ក្នុងកម្មដ្ឋានទាំង ៤០ កាលបើព្រះយោគាវចរបាន បម្រើន ឲ្យសម្រេចគុណវិសេសដល់ទីបំផុតរបស់កម្មដ្ឋាននោះ ៗ ហើយ បើមានប្រាថ្នានឹងបម្រើនបន្ថែមឲ្យកើនឡើងទៀត គប្បី បម្រើនតែក្នុងកសិណទាំង ១០ ប៉ុណ្ណោះ ព្រោះថាកសិណទាំង ១០ នោះ បើផ្សាយទៅកាន់ទិឱកាសត្រឹមណា ក៏អាចនឹងស្តាប់ សំឡេងឮដោយទិព្វសោតធាតុ មើលរូបឃើញដោយទិព្វចក្ខុ ដឹងបិត្តសត្វដទៃដោយបរចិត្តវិជ្ជា ក្នុងទិឱកាសត្រឹមណោះបាន ឯកម្មដ្ឋានឯទៀត មិនគួរបម្រើនបន្ថែមឲ្យកើនទៅទៀតទេ ព្រោះ មិនមានអានិសង្សឲ្យបានដល់ទិព្វសោតធាតុ និងទិព្វចក្ខុ ជាដើម ដូចជាកសិណទាំង ១០ នោះឡើយ ។

*អធិប្បាយអាការទី ៦-អារម្មណ៍របស់កម្មដ្ឋាន*

ត្រង់អារម្មណ៍ទី ៦ ដែលថាត្រូវឲ្យដឹងអារម្មណ៍របស់ កម្មដ្ឋាននោះ គឺត្រូវឲ្យដឹងថា : កម្មដ្ឋាន ២២ គឺ កសិណ ១០ អសុភ ១០ អានាបានស្សតិ ១ កាយគតាសតិ ១ កាន់យក បដិភាគនិមិត្តមកជាអារម្មណ៍បាន កម្មដ្ឋានក្រៅអំពីនោះ ១៨ កាន់យកបដិភាគនិមិត្តមកជាអារម្មណ៍មិនបានឡើយ កម្មដ្ឋាន

១២ គឺ អនុស្សតិ ៨ លើកអានាបានស្សតិ និង កាយគតា-សតិចេញ និងអាហារបដិក្កូលសញ្ញា ១ ចតុធាតុវវដ្ឋាន ១ វិញ្ញាណញ្ចាយតន ១ នេវសញ្ញានាសញ្ញាយតន ១ កាន់យកសភាពធម៌មកជាអារម្មណ៍ កម្មដ្ឋាន ២២ គឺ កសិណ ១០ អសុភ ១០ អានាបានស្សតិ ១ កាយគតាសតិ ១ កាន់យកនិមិត្តមកជាអារម្មណ៍ កម្មដ្ឋាន ៦ គឺ ព្រហ្មវិហារ ៤ អាកាសានញ្ចាយតន ១ អាកិញ្ចញ្ញាយតន ១ កាន់យកនូវអារម្មណ៍ពោលកំណត់មិនបាន កម្មដ្ឋាន ៨ គឺ វិបុព្វកអសុភ ១ លោហិតកអសុភ ១ បុឡុវកអសុភ ១ អានាបា-នស្សតិ ១ អាបោកសិណ ១ តេជោកសិណ ១ វាយោ-កសិណ ១ អាលោកកសិណ ត្រង់ដែលសម្លឹងយកមណ្ឌលរស្មីនៃព្រះអាទិត្យជាដើមមកជាអារម្មណ៍ ១ មុនដែលនឹងកើតបដិភាគនិមិត្ត អារម្មណ៍ញ័រ ដល់បដិភាគនិមិត្តកើត អារម្មណ៍ស្ងប់មិនមានកម្រើក កម្មដ្ឋានសល់អំពីនោះ ២២ មានអារម្មណ៍ស្ងប់ឥតកម្រើក ។

*អធិប្បាយអាការទី ៧-ភូមិរបស់កម្មដ្ឋាន*

ត្រង់ភូមិទី ៧ ដែលថាត្រូវឱ្យដឹងភូមិរបស់កម្មដ្ឋាននោះ គឺត្រូវឱ្យដឹងថា កម្មដ្ឋាន ១២ គឺ អសុភ ១០ កាយគតាសតិ ១ អាហារបដិកូលសញ្ញា ១ ប្រព្រឹត្តទៅក្នុងទេវលោកមិនបាន,(១) កម្មដ្ឋាន ១៣ គឺ អសុភ ១០ កាយគតាសតិ ១ អាហារបដិកូល-សញ្ញា ១ អានាបានស្សតិ ១ ប្រព្រឹត្តទៅក្នុងព្រហ្មលោកមិនបាន(២) កម្មដ្ឋានដទៃក្រៅអំពីអារុប្បកម្មដ្ឋានទាំង ៤ ចេញ ប្រព្រឹត្តទៅក្នុងអរូបភពមិនបាន(៣) ឯក្នុងមនុស្សលោក ប្រព្រឹត្តទៅបានគ្រប់ទាំង ៤០ ។

*អធិប្បាយអាការទី ៨- កិច្ចដែលត្រូវរៀនយកនូវកម្មដ្ឋាន*

ត្រង់គហណទី ៨ ដែលថាត្រូវឱ្យដឹងកិច្ចដែលត្រូវរៀនយកនូវកម្មដ្ឋាននោះ គឺត្រូវឱ្យដឹងថា កម្មដ្ឋាន ១៩ គឺ កសិណ ៩ លើកវាយោកសិណចេញ និងអសុភ ១០ ត្រូវរៀនយកមុនដំបូងតាមនិមិត្តដែលមើលឃើញចំពោះភ្នែក កាយគតា-សតិ ត្រូវរៀនយកតាមនិមិត្តដែលមើលឃើញខ្លះ តាមដែលស្តាប់ឮខ្លះ គឺត្រង់តបបញ្ចកត្រូវរៀនយកតាមនិមិត្តដែល

**១-២-៣ ព្រោះភពទាំងនោះមិនមានអារម្មណ៍បែបនេះដែលល្មមនឹងចម្រើនបាន។**

មើលឃើញសល់អំពីនោះតាមដោយស្តាប់ឮ អានាបានស្សតិ ត្រូវរៀនយកតាមខ្យល់អស្សាសបស្សាស ដែលពាល់ត្រូវបន្លោះកាយអំពីខាងក្នុង វាយោកសិណ ត្រូវរៀនយកតាមដែលមើលទៅឃើញខ្យល់បក់កម្រើកស្លឹកឈើខ្លះ បក់មកប៉ះពាល់ត្រូវកាយរបស់ខ្លួនខ្លះ កម្មដ្ឋានដែលសល់អំពីនេះ ១៨ ត្រូវរៀនយកតាមដោយស្តាប់ឮអាចារ្យពន្យល់ប្រាប់ កម្មដ្ឋាន ៥ គឺ ឧបេក្ខាព្រហ្មវិហារ ១ អារុប្ប ៤ ព្រះយោគាវចរកុលបុត្រដែលជាអាទិកម្មិក(១) មិនត្រូវរៀនឡើយ ត្រូវរៀនតែកម្មដ្ឋាន ៣៥ ក្រៅអំពីនេះ ។

### *អធិប្បាយអាការទី ៩- បច្ច័យរបស់កម្មដ្ឋាន*

ត្រង់បច្ច័យទី ៩ ដែលថាត្រូវឲ្យដឹងបច្ច័យរបស់កម្មដ្ឋាននោះ គឺត្រូវឲ្យដឹងថា កសិណ ៩ ក្រៅអំពីអាកាសកសិណចេញ ជាបច្ច័យដល់អារុប្បកម្មដ្ឋានទាំង ៤ កសិណគ្រប់ទាំង ១០ ជាបច្ច័យដល់អភិញ្ញា ៥ ព្រហ្មវិហារ ៣ ជាន់ក្រោម ជាបច្ច័យដល់ព្រហ្មវិហារទី ៤ អារុប្បជាន់ក្រោមៗ ជាបច្ច័យ

---

១- កុលបុត្រដែលមិនធ្លាប់សន្សំទុកមកអំពីអតីតជាតិ ទើបតែនឹងប្រារព្ធក្នុងបច្ចុប្បន្នជាតិនេះជាដម្បូង ឬដែលមិនទាន់ចម្រើនកម្មដ្ឋានឯទៀតនៅឡើយ ។

ដល់អារុប្បជាន់លើៗ នេវសញ្ញានាសញ្ញាយតន ជាបច្ច័យដល់និរោធសមាបត្តិ កម្មដ្ឋានគ្រប់ទាំង ៤០ ជាបច្ច័យឱ្យព្រះខីណាស្រពនៅជាសុខក្នុងបច្ចុប្បន្ន ជាបច្ច័យដល់វិបស្សនាបើព្រះយោគី បម្រើនមិនបានត្រាស់ដឹងគុណវិសេសអ្វីជាន់ខ្ពស់ក្នុងបច្ចុប្បន្នជាតិ ក៏គង់ជាបច្ច័យឱ្យកើតសម្បត្តិនៅក្នុងភព ។

*អធិប្បាយអាការទី ១០- កម្មដ្ឋានដែលសមគួរដល់ចរិត*

ត្រង់ចរិយានុកុលទី ១០ ដែលថាត្រូវឱ្យដឹងកម្មដ្ឋានដែលសមគួរដល់ចរិតនោះគឺ ត្រូវឱ្យដឹងថាកម្មដ្ឋាន ១១ គឺអសុភ ១០ កាយគតាសតិ ១ សមគួរដល់បុគ្គលជារាគចរិត កម្មដ្ឋាន ៨ គឺព្រហ្មវិហារ ៤ វណ្ណកសិណ ៤ គឺនីលកសិណ ១ បីតកសិណ ១ លោហិតកសិណ ១ ឱទាតកសិណ ១ សមគួរដល់បុគ្គលជាទោសចរិត អានាបានស្សតិតែ ១ សមគួរដល់បុគ្គលជាមោហ-ចរិត និងវិតក្កចរិត, អនុស្សតិ ៦ ខាងដើមគឺ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ សមគួរដល់បុគ្គលជាសទ្ធាចរិត កម្មដ្ឋាន ៤ គឺ មរណានុស្សតិ ១ ឧបសមានុស្សតិ ១ ចតុធាតុវវដ្ឋាន ១

អាហារបដិកូលសញ្ញា ១ សមគួរដល់បុគ្គលជាពុទ្ធិចរិត កម្មដ្ឋានសល់អំពីនោះ ១០ គឺ បឋវីកសិណ ១ អាបោកសិណ ១ តេជោកសិណ ១ វាយោកសិណ ១ អាកាសកសិណ ១ អាលោកកសិណ ១ អារុប្ប ៤ សមគួរដល់បុគ្គលគ្រប់ចរិតទាំងអស់ តែបើបុគ្គលជាវិតក្កចរិត ត្រូវធ្វើវង់កសិណឲ្យតូច បើជាមោហចរិតត្រូវធ្វើវង់កសិណឲ្យធំ ទើបបានជាទីសប្បាយ ។

បើរៀនយកនូវកម្មដ្ឋានណាមួយ ដែលខុសទំនងមិនសមគួរដល់ចរិតបែបនេះ តើនឹងមិនមានប្រយោជន៍អ្វីតិចតួចទេឬ? គង់មានប្រយោជន៍ ធម្មតាកុសលកម្មតែសតូកសាងសន្សំហើយ បើទុកជាដូចម្ដេចក៏គង់បានខ្លះមិនខាន តែថានឹងបានផ្ចិតផ្ចង់ធម៌ជាសត្រូវឲ្យបំៗ នឹងឲ្យបានជាទីសប្បាយដល់សន្តានចិត្ត ជាហេតុនឹងញុំាងគុណវិសេសជាន់ខ្ពស់ឲ្យកើតឡើងនោះពុំបានឡើយ ហាក់ដូចជាគ្រូពេទ្យដាក់ថ្នាំខុសរោគរបស់អ្នកជំងឺ ។

### *វិហារមិនសមគួរដល់សមាធិភាវនា*

ត្រង់ដែលថាត្រូវឲ្យវៀរបង់មិនឲ្យនៅក្នុងវិហារ(១) ដែល

១- ដែលហៅថា "វិហារ" ក្នុងទីនេះ សំដៅយកទីអាវាសទាំងមូល ។

មិនសមគួរដល់សមាធិភាវនានោះ តើវិហារដែលមិនសមគួរ មានប៉ុន្មានយ៉ាង? ដូចម្ដេចខ្លះ? មានទោសដូចម្ដេច?

*វិហារដែលមិនសមគួរដល់សមាធិភាវនាមាន ១៨ យ៉ាងគឺះ*

១- **មហាវត្តំ** វិហារធំ ។

២- **នវត្តំ** វិហារទើបកប្អី ។

៣- **ជិណ្ណាវត្តំ** វិហារចាស់បាក់បែក ។

៤- **បន្ថសន្និស្សិតត្តំ** វិហារអាស្រ័យនៅក្បែរផ្លូវថ្លា ។

៥- **សោណ្ឌី** វិហារមានត្រពាំងទឹក ។

៦- **បណ្ណំ** វិហារសម្បូរស្លឹកឈើបន្លែ ។

៧- **បុប្ផំ** វិហារសម្បូរដោយផ្កាឈើ ។

៨- **ផលំ** វិហារសម្បូរដោយផ្លែឈើ ។

៩- **បត្ថនីយតា** វិហារដែលគេត្រូវការបុះបួលច្រើន

១០- **នគរសន្និស្សិតតា** វិហារដែលអាស្រ័យនៅក្នុងក្រុង ។

១១- **ទារុសន្និស្សិតតា** វិហារដែលអាស្រ័យនៅក្បែរ ព្រៃឈើឧស ។

១២- **ខេត្តសន្និស្សិតតា** វិហារដែលអាស្រ័យនៅក្បែរស្រែ។

១៣- **វិសភាគានំ បុគ្គលានំ អត្ថិតា** វិហារដែលមានបុគ្គលខុសប្លែបគ្នា(១) ។

១៤- **បដ្ដនសន្និស្សិតតា** វិហារដែលអាស្រ័យនៅក្បែរកំពង់បំណាត ។

១៥- **បច្ចន្តសន្និស្សិតតា** វិហារដែលអាស្រ័យនៅក្នុងបច្ចន្តគ្រាម ។

១៦- **រជ្ជសីមន្តរសន្និស្សិតតា** វិហារដែលអាស្រ័យនៅក្នុងបន្លោះនៃព្រំដែន ។

១៧- **អសប្បាយតា** វិហារដែលមិនសប្បាយដោយវិសភាគារម្មណ៍ជាដើម ឬដោយអមនុស្សបៀតបៀន ។

១៨- **កល្យាណមិត្តានំ អលាភោ** វិហារដែលរកលោកជាកល្យាណមិត្តមិនបាន ។

វិហារទាំង ១៨ យ៉ាងនេះ មានទោសដូច្នេះ គឺវិហារធំមានភិក្ខុនៅអាស្រ័យច្រើន ហើយច្រើនមានឆន្ទៈផ្សេងៗគ្នា

---

១- អាវាសដែលមានភិក្ខុឈ្លោះទាស់ទែងគ្នាប្រកាន់ដោយពួក ។

ច្រើនប្រចាំមិនធ្វើវត្តមានបោសប្រាសជាដើម ភារៈនោះ នឹងធ្លាក់មកលើព្រះយោគី វិហារទើបកថ្មីនិងវិហារចាស់បាក់បែកច្រើនមានកង្វល់ដោយការងារ វិហារដែលអាស្រ័យនៅក្បែរផ្លូវថ្លា និងវិហារដែលអាស្រ័យនៅក្បែរកំពង់បំណាត ច្រើនកង្វល់ដោយអាគន្តុកៈ វិហារដែលមានត្រពាំងទឹក ដែលសម្បូរស្លឹឈើបន្លែ សម្បូរផ្កាឈើ សម្បូរផ្លែឈើ ច្រើនកើតទោសអំពីអ្នកស្រុក វិហារដែលគេត្រូវការបុះបូលច្រើន ៗ គឺកកងដោយភ្ញៀវ វិហារដែលអាស្រ័យនៅក្នុងក្រុងច្រើនប្រទះវិសភាគារម្មណ៍ វិហារដែលអាស្រ័យនៅក្បែរព្រៃឈើ និងក្បែរស្រែ ច្រើនកង្វល់ដោយគេខ្ចីរបស់ ឬផ្ញើរបស់ វិហារដែលមានបុគ្គលខុសបែបគ្នា លំបាកដោយការរាប់អានម្ខាងៗ វិហារដែលអាស្រ័យនៅក្នុងបច្ចន្តគ្រាម មនុស្សអ្នកស្រុកមិនសូវជ្រះថ្លាក្នុងពុទ្ធាទិគុណ វិហារដែលអាស្រ័យនៅក្នុងចន្លោះនៃព្រំដែន ច្រើនលំបាកដោយអាជ្ញារបស់ស្តេច(១) វិហារដែលមានអមនុស្សហ្លួងហែង ច្រើនលំបាកដោយ

---

១- ម្តងស្តេចខាងអាយកៀរបញ្ចូលមកខាងអាយ ម្តងស្តេចខាងនាយកៀរបញ្ចូលទៅខាងនាយ

អមនុស្សបៀតបៀន វិហារដែលរកលោកជាកល្យាណមិត្ត មិនបាន មានទោសធំជាងគេបំផុត ព្រោះមិនមានបុគ្គលជាទីគោរពនិងសាកសួរសេចក្តីដែលជ្រាលជ្រៅ ។

អននុរូបវិហារទាំង ១៨ នេះមានទោសដូចអធិប្បាយមកហើយ ហេតុនោះ ព្រះយោគីមិនគួរនៅអាស្រ័យឡើយ ព្រោះជាសត្រូវដល់សមាធិភាវនា តែថា បើព្រះយោគីអង់អាចនឹងរក្សាអារម្មណ៍ឲ្យផុតចាកទោសទាំងនោះបាន ក៏គួរនៅអាស្រ័យបាន ។

*វិហារដែលសមគួរដល់សមាធិភាវនា*

ត្រង់ដែលថា ត្រូវនៅក្នុងវិហារដែលសមគួរដល់សមាធិភាវនា តើវិហារនោះដូចម្តេច?

វិហារដែលសមគួរដល់សមាធិភាវនានោះ ប្រកបដោយអង្គ ៥ ប្រការគឺៈ

១- មិនឆ្ងាយជាងកន្លះគាវុត មិនជិតជាង ៥០០ ធ្នូរធ្នូអំពីទីគោចរ ហើយងាយទៅងាយមក។

២- ពេលថ្ងៃមិនប្រឡូកប្រឡំដោយមហាជន ពេលយប់

ស្ងាត់មិនមានឮស្នូរសំឡេងមហាជនប្រជុំជជែកគ្នាសព្វកាល ។

៣- មិនមានសម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃនិងពស់តូច ពស់ធំ ។

៤- មិនលំបាកដោយបច្ច័យទាំង ៤ មានចីវរប្បច្ច័យជាដើម

៥- មានលោកជាពហូសូតចេះចាំបរិយត្តិ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា អាចនឹងចូលទៅសាកសួរ ត្រង់កន្លែងដែលកំបាំង កន្លែងដែលសង្ស័យបានដោយងាយ ។

ព្រះយោគីជាអ្នកបម្រើនូវសមាធិភាវនា គួរនៅក្នុងវិហារបែបនេះបុះ ។

*បលិពោធតូចៗ និងវិធីផ្តាច់បង់*

ត្រង់ដែលថា ត្រូវផ្តាច់បង់នូវបលិពោធតូចៗ (កង្វល់បន្ទាប់បន្សំ) នោះតើបលិពោធអ្វីខ្លះ? -ត្រូវផ្តាច់បង់ដូចម្តេច?

បលិពោធតូចៗ នោះគឺ សក់វែង រោមវែង ក្រចកវែង ចីវរចាស់គ្រាំគ្រាឬសៅហ្មង បាត្រមានមន្ទិល គ្រែតាំងជាដើម មិនស្អាត ។

វិធីផ្តាច់បង់នូវបលិពោធទាំងនោះដូចនេះគឺ សក់ រោម

ក្របកវែងត្រូវកោរកាត់ចេញ ចីវរចាស់គ្រាំគ្រាឬសៅហ្មង ត្រូវប៉ះជុលលាងជ្រលក់ឲ្យហើយ បាត្រមានមន្ទិលត្រូវដុតចេញ គ្រែតាំងជាដើមមិនស្អាតត្រូវជម្រះចេញឲ្យហើយជាស្រេច ។

*វិធីរៀនយកនូវកម្មដ្ឋាន ចប់*

---

## វិធីចម្រើនកម្មដ្ឋាន ៤០

*កសិណ ១០*

## បឋវីកសិណ

ត្រង់ដែលថាចម្រើននូវកម្មដ្ឋាន ឲ្យត្រឹមត្រូវតាមរបៀបនៃវិធីចម្រើនឲ្យសព្វគ្រប់នោះ តើវិធីចម្រើនដែលត្រឹមត្រូវនោះដូចម្តេចខ្លះ?

ក៏ឯវិធីចម្រើននូវកម្មដ្ឋាននេះ ជាសេចក្តីពិស្តារជ្រាលជ្រៅពេកណាស់ ហេតុនោះគប្បីដឹងតាមលំអានដែលនឹងពោលតទៅជាលំដាប់នេះចុះ ។

ក្នុងកម្មដ្ឋានទាំង ៤០ នឹងពណ៌នានូវវិធីចម្រើនក្នុងកសិណទាំង ១០ ជាមុន តែមុនដំបូងនឹងសូមពណ៌នាអំពីបឋវីកសិណរៀងជាលំដាប់តទៅ ។

ព្រះយោគាវចរកុលបុត្រដែលជាអាទិកម្មិក កាលបើមានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងបឋវីកសិណ គប្បីយកដីមកធ្វើជាវង់កសិណទុកជាមុន(១) ឯវិធីដែលនឹងធ្វើនូវវង់កសិណនោះមាន ២ យ៉ាងគឺ យកឈើមកបង់ខ្ទង់ទុកជា ៤ ជ្រុង យកកំណាត់សំពត់ កំណាត់ស្បែក ឬកំណាត់កន្ទេលមកបង់ពាសភ្ជាប់ឲ្យណែនអំពីខាងលើ ហើយយកដីស្អិតមានពណ៌ក្រហមដូចព្រះអរុណ មិនមានលាយដោយពណ៌ខៀវជាដើម មកលាបអំពីខាងលើធ្វើឲ្យមានវង់មូលទំហំកាត់ទទឹង ១ បំអាម ៤ ធ្នាប់ ឬធំជាងនេះទៅក្តី តាមសមគួរដល់បរិត ដុះខាត់ឲ្យស្អាតស្មើដូចផ្ទៃស្គរកុំឲ្យមានសម្រាម ឫសស្មៅ ឬដុំគ្រួសនិងដីខ្សាច់ជាដើមនៅលាយឡំ ដល់ពេលចម្រើនទើបនាំយកទៅតែម្តងក៏បាន ពុំនោះនឹងបោះជាបង្គោល ៤ នៅត្រង់កន្លែងដែលស្ងាត់ មានជ្រុងញកវិហារជាដើមហើយយកកំណាត់សំពត់ កំណាត់ស្បែក ឬកំណាត់កន្ទេលទៅបង់រឹត

១- ដែលត្រូវធ្វើវង់កសិណទុកយ៉ាងនេះ ចំពោះតែព្រះយោគីដែលជាអាទិកម្មិកម្យ៉ាង បើព្រះយោគីដែលមានអភិនីហារធ្លាប់សន្សំទុកមកលោកសម្លឹងមើលតែមណ្ឌលនៃលានជាដើមប៉ុណ្ណោះ ក៏អាចនឹងញ៉ាំងឧគ្គហនិមិត្តឲ្យកើតឡើងបានរហូតដល់អប្បនាឈាន ។

អំពីខាងលើ យកដីស្អិតមកលាបធ្វើជាវង់កសិណតម្កល់ទុកជាប់ជានិច្ចក្នុងទីនោះក៏បាន ហើយត្រូវមានតាំង ១ មានជើងកម្ពស់ ១ បំអាម ៤ ធ្នាប់សម្រាប់អង្គុយបម្រើន ដល់ពេលដែលបានបន្ទោបង់នូវសេចក្ដីស្រវឹងក្នុងភត្ត ដោយស្រួលហើយត្រូវនាំយកវង់កសិណនោះទៅកាន់ទីដែលកំបាំង តម្កល់ទុកអំពីខាងមុខចម្ងាយ ២ ហត្ថ ១ បំអាម រៀបបំក្រាលតាំងឱ្យល្អឡើងអង្គុយពត់ភ្នែនតម្រង់កាយប្រុងស្មារតីឱ្យស្រួល ហើយពិចារណានូវទោសរបស់កិលេសកាមនិងវត្ថុកាម ឱ្យឃើញថាមានសេចក្ដីត្រេកអរមានប្រមាណតិច មានទុក្ខទោសបង្កៀតបង្អល់ច្រើន មិនគួរឱ្យត្រេកអរដូចជារាងឆ្អឹង តែងដុតឱ្យក្ដៅក្រហាយ រោលរាលដូចគប់ភ្លើងធ្វើដោយស្មៅជាដើម ហើយញ៉ាំងសេចក្ដីប្រាថ្នាក្នុងឈានឱ្យកើតឡើងព្រមថា "បដិបទានេះជាគ្រឿងរលាស់ចេញចាកកាមបាន ជាឧបាយឱ្យកន្លងបង់នូវទុក្ខទាំងពួងបាន" ហើយត្រូវរឭកដល់ពុទ្ធាទិ-គុណ ឱ្យកើតបីតិនិងបាមោជ្ជ(១)ជាមុន ហើយត្រូវមានសេចក្ដី

---

១- សេចក្ដីអំណរដែលកើតការឡើងហៅថា "បីតិ" ដែលនៅទន់ស្ទើរហៅថា "បាមោជ្ជ" ។

គោរព ត្រូវសង្ឃឹមចំពោះសេចក្ដីប្រតិបត្តិរបស់ខ្លួនថា "នេះជាដំណើរដែលព្រះពុទ្ធព្រះបច្ចេកពុទ្ធ និងព្រះអរិយសាវករាល់ព្រះអង្គតែងប្រតិបត្តិមកហើយ អញមុខជានឹងបាននូវចំណែកនៃសេចក្ដីសុខក្នុងវិវេក ដោយសេចក្ដីប្រតិបត្តិនេះមិនខានឡើយ" ហើយត្រូវញ៉ាំងឧស្សាហ៍ឲ្យកើតឡើងក្នុងខណៈនោះទើបបើកភ្នែកឡើងឲ្យល្មមកុំឲ្យតូចពេកធំពេក សម្លឹងយកនិមិត្តរបស់កសិណនោះ តែមិនត្រូវពិចារណាពណ៌ មិនត្រូវធ្វើទុកក្នុងចិត្តនូវលក្ខណៈរឹងឬទន់ជាដើមឡើយ ត្រូវទាញស្រាវយកពណ៌មកផ្អែបទុកជានិស្ស័យ ហើយតាំងចិត្តទុកក្នុងបញ្ញត្តិធម៌ ដែលលោកសន្មតហៅថា "ដី" ដោយមានធាតុដីផ្សាយឡើងច្រើនប៉ុណ្ណោះ ហើយត្រូវកំណត់ធ្វើទុកក្នុងចិត្តថា "**បឋវី បឋវី** ដីៗ" ដូច្នេះ បើកភ្នែកសម្លឹងមើលវង់កសិណម្ដងធ្មេចភ្នែកនឹករំពឹងម្ដង ដល់ ១ រយចប់ក្ដី ១ ពាន់ចប់ក្ដី ដរាបដល់បើកភ្នែកឡើងឃើញយ៉ាងណា ធ្មេចទៅវិញ ក៏ឃើញយ៉ាងនោះដដែល ត្រង់នេះត្រូវដឹងថា "ឧគ្គហនិមិត្តកើតឡើងហើយ ។

កាលបើបម្រើនបានឧគ្គហនិមិត្តដូច្នេះហើយ មិនត្រូវនៅក្នុងទីនោះទៀតឡើយ គប្បីថយទៅរកកន្លែងដទៃនិងបម្រើនទៀត ត្រូវពាក់ស្បែកជើងផ្ទៃមួយជាន់ កាន់ឈើប្រត់ដើរទៅ ដើម្បីរក្សាទុកនូវនិមិត្តនោះមិនឲ្យវិនាសទៅវិញ(១) លុះត្រឡប់ដល់ទីសេនាសនរបស់ខ្លួនហើយ ត្រូវអង្គុយឲ្យស្រួលហើយ នឹកទាញស្រាវយកឧគ្គហនិមិត្តនោះមកកំណត់ទុកក្នុងចិត្តថា “**បឋវី បឋវី** ដីៗ” ដូចដើមដដែល ហាត់បង្ហឹកបម្រើនឲ្យវិសេសឡើងទៀត កាលបើព្រះយោគីកំណត់ធ្វើទុកក្នុងចិត្តរឿយៗ យ៉ាងនេះហើយ នីវរណធម៌ទាំង ៥ ក៏ទ្រោមទៅ កិលេសក៏ស្ងប់ទៅជាលំដាប់ ចិត្តរបស់ព្រះយោគីសោតក៏តម្កល់នៅមាំដោយឧបចារសមាធិ ខណៈនោះបដិភាគនិមិត្តក៏កើតឡើង ។

---

១- ពាក់ស្បែកជើងការពារមិនឲ្យបន្លាមុតឬប្រទ្បាក់ធូលីជាដើមដែលជាហេតុឲ្យកើតបលិពោធ កាន់ឈើច្រត់សម្រាប់ការពារអន្តរាយមានឆ្កែជាដើម ក្នុងទីនេះលោកពោលថាត្រូវពាក់ស្បែកជើងផ្ទៃ១ជាន់ តែថាប្រហែលជាលោកពោលចំពោះមជ្ឈិមប្រទេសទេដឹង? បើក្នុងបច្ចន្តប្រទេសតាមបទេសបញ្ញត្តិពាក់បានរហូតដល់ ៤ ជាន់មិនជាអ្វី ឬនឹងទៅជាធ្ងន់នាំឲ្យកើតបលិពោធវិញ ។

ឧគ្គហនិមិត្តនិងបដិភាគនិមិត្តផ្សេងគ្នាដូចម្តេច?

ក្នុងបឋវីកសិណនេះ ឧគ្គហនិមិត្ត នៅមានលាយប្រឡាំ ដោយពណ៌ខៀវស្មៀងជាដើម ឯបដិភាគនិមិត្តក៏ហាក់ដូចជាទម្លាយនូវឧគ្គហនិមិត្តចេញមក បរិសុទ្ធល្អិតសុខុមមួយរយគុណមួយពាន់គុណ ក្រៃលែងឡើងទៀត ឧបមាដូចជាមណ្ឌលនៃកញ្ចក់ ដែលគេហូតចេញអំពីស្រោម ឬដូចជាសម្បកនៃស័ង្ខ ដែលជាងខាត់យ៉ាងល្អ ពុំនោះដូចជាមណ្ឌលនៃព្រះចន្ទ្រ ដែលទើបចេញមកអំពីចន្លោះពពក តែថាមិនមានពណ៌ មិនមានសណ្ឋានទ្រង់ទ្រាយឡើយ លំដាប់នោះ នីវរណធម៌ទាំង ៥ ក្តី កិលេសទាំងពួងក្តី ក៏ទ្រោមស្ងាត់បាត់ទៅ ចិត្តរបស់ព្រះយោគីសោត ក៏តម្កល់នៅមាំដោយឧបចារសមាធិដដែល ព្រោះនៅជាកាមាវចរ អង្គឈានទាំង ៥ មិនទាន់កើតឡើងមានកម្លាំង តែបើព្រះយោគីពុំបានលះបង់នូវលំដាប់នៃវិធីចម្រើន ក៏នឹងបានសម្រេចដល់អប្បនាឈានទាំងចតុក្កន័យនិងបញ្ចកន័យ ព្រោះហេតុនោះ បើព្រះយោគីចម្រើនបាននូវបដិភាគនិមិត្ត មានសភាពដូចពោល

មកយ៉ាងនេះហើយ តែមិនទាន់ដល់នូវអប្បនាឈានក្នុងខណៈនោះ ក៏គប្បីរក្សានូវបដិភាគនិមិត្តនោះទុក មិនគប្បីឲ្យវិនាសទៅវិញឡើយ ព្រោះកម្រនឹងបម្រើនឲ្យកើតឡើងវិញពេកណាស់ ។

រក្ខណាវិធី

ក៏វិធីដែលមិនរក្សាទុកនូវបដិភាគនិមិត្តនោះ ត្រូវវៀរបង់នូវហេតុដែលមិនជាទីសប្បាយ ៧ យ៉ាង ហើយត្រូវសេពនូវហេតុដែលជាទីសប្បាយ ៧ យ៉ាង ។

ហេតុដែលមិនជាទីសប្បាយ ៧ យ៉ាងនោះគឺ

១- **អាវាសោ** អាវាសដែលនិមិត្តមិនទាន់កើតនិងមិនកើតឡើង និមិត្តដែលកើតឡើងហើយ ក៏វិនាសបាត់ទៅវិញជាដើម ។

២- **គោចរោ** ទីគោចរដែលឆ្ងាយពេក ជិតពេក(១) លំបាកដោយភិក្ខា ។

៣- **ភស្សំ** ពាក្យដែលរោយរាយ រាប់បញ្ចូលក្នុងតិរច្ឆានកថា ៣២ ។

---

១- ទីគោចរដែលឆ្ងាយជាង ឬជិតជាង ១ ក្រោសកន្លះ គឺ ១ ពាន់ធ្នូរធ្នូ។

៤- **បុគ្គលោ** បុគ្គលដែលជាអ្នកស្លូនកាយល្មោភតែខាងស៊ី ប្រើនពោលនូវតិរច្ឆានកថា ។

៥- **ភោជនំ** ភោជនដែលបរិភោគចូលទៅនាំឲ្យមិនស្រួលខ្លួន តម្កល់ចិត្តឲ្យមាំមិនបាន ។

៦- **ឧតុ** រដូវដែលក្តៅណាស់ ឬត្រជាក់ណាស់ តម្កល់ចិត្តឲ្យមាំមិនបាន ។

៧- **ឥរិយាបថោ** ឥរិយាបថដែលមិនត្រូវទំនង តម្កល់ចិត្តឲ្យមាំមិនបាន ។

ឯហេតុដែលជាទីសប្បាយ ៧ យ៉ាងនោះ គ្រាន់តែផ្ទុយមកនឹងហេតុដែលមិនជាទីសប្បាយទាំង ៧ យ៉ាងនេះ ហើយនិងត្រង់ទី ៣ លោកសំដៅយកពាក្យដែលរាប់បញ្ចូលក្នុងកថាវត្ថុ ១០ យ៉ាងប៉ុណ្ណោះឯង ។

កាលបើ ព្រះយោគីវៀរបង់នូវហេតុដែលមិនជាទីសប្បាយសេពនូវហេតុដែលជាទីសប្បាយ ដូចពោលមកនេះ ហើយសេពនូវបដិភាគនិមិត្តនោះរឿយៗ ឡើងទៅ ជួនកាលក៏អប្បនាចិត្តកើតឡើង ។

## *អប្បនាកោសល្លវិធី*

បើព្រះយោគី វៀរបង់នូវហេតុដែលមិនជាទីសប្បាយ ហើយសេពនូវហេតុដែលជាទីសប្បាយ យ៉ាងនេះហើយ អប្បនាចិត្ត នៅតែមិនទាន់កើតឡើង ក៏គប្បីញុំាងអប្បនា-កោសល្លវិធី គឺវិធីដែលឆ្លាសក្នុងអប្បនាឲ្យសម្រេចដោយអាការ ១០ យ៉ាងតទៅទៀត ។

អប្បនាកោសល្លវិធី ១០ យ៉ាងនោះគឺ

១- **វត្ថុវិសទកិរិយា** ធ្វើវត្ថុទាំងខាងក្នុងខាងក្រៅឲ្យស្រឡះស្រឡូន មានកោរសក់ និងកាត់ក្រចកជាដើម ។

២- **ឥន្ទ្រិយសមត្តបដិបាទនំ** ប្រមុំសទ្ធិន្ទ្រិយនិងបញ្ញិ-ន្ទ្រិយឲ្យមានកម្លាំងស្មើគ្នា សមាធិន្ទ្រិយនិងវីរិយិន្ទ្រិយឲ្យមានកម្លាំងស្មើគ្នា ឯសតិន្ទ្រិយត្រូវឲ្យមានកម្លាំងគ្រប់អន្លើ ។

៣- **និមិត្តកោសល្លំ** ភាពជាអ្នកឆ្លាសក្នុងវិធីបម្រើនយកនិមិត្តនិងរក្សាទុកនូវនិមិត្តដែលបានកើតឡើងហើយ មិនឲ្យវិនាសទៅវិញ ។

៤- **សមយេ ចិត្តំ បគ្គណ្ហាតិ** ផ្គងចិត្តឡើងក្នុងសម័យ

ដែលគួរ គឺបម្រើនូវធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គក្នុងសម័យដែលចិត្តកំពុងរួញរា ។

៥- **សមយេ ចិត្តំ និគ្គណ្ហាតិ** ផ្ចិតចិត្តទុកក្នុងសម័យដែលគួរ គឺបម្រើនូវបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គក្នុងសម័យដែលចិត្តកំពុងរាយមាយ ។

៦- **សមយេ ចិត្តំ សម្បហំសេតិ** កម្លាចិត្តក្នុងសម័យដែលគួរ គឺញុំាងចិត្តឲ្យស្លុតដោយពិចារណានូវសំវេគវត្ថុ ៨ យ៉ាង ឬឲ្យជ្រះថ្លាដោយរឭកដល់ពុទ្ធាទិគុណ ។

៧- **សមយេ ចិត្តំ អជ្ឈុបេក្ខតិ** ទប់ចិត្តតម្រង់ទុកក្នុងសម័យដែលគួរ គឺមិនខ្វល់ខ្វាយនិងផ្គងឡើងផ្ចិតចុះ ឬកម្លាឡើងក្នុងសម័យដែលចិត្តប្រព្រឹត្តទៅស្មើត្រង់ តាមវិថីរបស់សមថៈហើយ ។

៨- **អសមាហិតបុគ្គលបរិវជ្ជនា** វៀរបង់នូវបុគ្គលដែលមានចិត្តមិនតម្កល់មាំ ខ្វល់ខ្វាយតែក្នុងកិច្ចការដោយច្រើន ។

៩- **សមាហិតបុគ្គលសេវនា** សេពគប់នូវបុគ្គលដែលមានចិត្តតម្កល់មាំគឺលោកអ្នកបាននូវសមាធិចិត្ត ។

១០- **តទធិមុត្តតា** ភាពជាអ្នកមានចិត្តយាងចុះស៊ប់ក្នុងសមាធិនោះ ។

កាលបើព្រះយោគី បានញុំាងអប្បនាកោសល្លវិធី ឲ្យសម្រេចដោយអាការ ១០ យ៉ាង ដូចពណ៌នាមកនេះហើយ អប្បនាចិត្តក៏នឹងកើតឡើងរៀងជាលំដាប់ ដរាបដល់ ចតុក្ក-ជ្ឈាននិងបញ្ចកជ្ឈាន (ដំណើរដែលឈានកើតឡើងយ៉ាងដូចម្ដេចនោះនឹងមានអធិប្បាយទៅខាងមុខ) ។

## អាបោកសិណ

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងអាបោកសិណ គប្បីត្រូវយកទឹកភ្លៀងដែលទើបធ្លាក់ចុះមកអំពីអាកាសមិនទាន់ដល់ផែនដី ឬទឹកឯទៀតក៏បានឲ្យតែថ្លា មានសភាពដូច្នោះ យកសម្ពត់ត្រងឲ្យស្អាតដាក់ក្នុងបាត្រ ឬកុន្ទីជាដើម វាល់ឲ្យពេញស្មើត្រឹមមាត់ នាំយកទៅតម្កល់ទុកជាកសិណ(១)ក្នុងទីដែលស្ងាត់ ឡើងអង្គុយលើតាំង

១- វិធីដែលត្រូវធ្វើកសិណយ៉ាងនេះ ចំពោះតែព្រះយោគីដែលជាអាទិកម្មិកម្យ៉ាង បើព្រះយោគីដែលមានបុណ្យមានអភិនីហារ ធ្លាប់ចម្រើនក្នុងកសិណនេះមកអំពីអតីតជាតិ លោកគ្រាន់តែសម្លឹងមើលទឹកក្នុងស្រះ ឬសមុទ្រជាដើម ក៏អាចញុំាងនិមិត្តឲ្យកើតឡើងបាន ។

បើកភ្នែកសម្លឹងមើលយកនិមិត្ត តែមិនត្រូវពិចារណាពណ៌ មិនត្រូវធ្វើទុកក្នុងចិត្តនូវលក្ខណៈដែលរាវជាដើមឡើយ ត្រូវតាំងចិត្តទុកតែក្នុងបញ្ញត្តិធម៌ គឺពាក្យដែលលោកសន្មតហៅថា "ទឹក" ដោយមានធាតុទឹកផ្សាយឡើងច្រើនប៉ុណ្ណោះ ហើយត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា "**អាបោ អាបោ** ទឹកៗ" ដូច្នេះរហូតដល់ឧគ្គហនិមិត្ត និងបដិភាគនិមិត្តកើតឡើង ។

ឧគ្គហនិមិត្តក្នុងអាបោកសិណនេះ តាំងឡើងប្រាកដហាក់ដូចជាញ័ររំជួយ បើទឹកដែលយកមកធ្វើជាកសិណនោះមានប្រឡុំដោយផេះដោយរលកឬពពុះ ក៏ប្រាកដឡើងដូច្នោះឯបដិភាគនិមិត្តទ្រង់ដូចជាផ្សាយខ្ចរព្រាបឡើងប្រាកដ ហាក់ដូចជាផ្លិតជាវិការនៃកែវមណី ដែលគេតម្កល់ទុកឰដ៏អាកាសពុំនោះ ប្រាកដហាក់ដូចជាមណ្ឌលនៃកញ្ចក់ ជាវិការនៃកែវមណី(១) ។

## តេជោកសិណ

កាលបើព្រះយោគាវចរកុលបុត្រមានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្ត ក្នុងតេជោកសិណ គប្បីយកឧសគ្រាក់ដែលខ្លឹម ។

---

១- វិធីដែលសល់អំពីនេះដូចក្នុងបឋវីកសិណ។

មកពុះបាលថ្ងៃឲ្យស្ងួត បងធ្វើជាបាច់ៗ ឲ្យមូលៗ ដល់ពេលដែលត្រូវការនឹងបម្រើន គប្បីនាំយកទៅកាន់ទីឱកាសដែលស្ងាត់ ដុតឲ្យមានជាអណ្តាតឡើង រួចយកកំណាត់កន្ទេលក៏បាន កំណាត់ស្បែកក៏បាន កំណាត់សំពត់ក៏បាន ណាមួយមកបោះធ្វើជាប្រហោងឲ្យមានវង់មូល ទំហំទទឹង ១ បំអាម ៤ ធ្នាប់(១) ហើយយកទៅដាក់បាំងអំពីខាងមុខឲ្យមើលទៅឃើញតែអណ្តាតភ្លើង ដែលឆាបឡើងត្រង់បន្លោះប្រហោងនោះ ហើយតាំងអង្គុយបើកភ្នែកសម្លឹង យកនិមិត្តត្រង់កណ្តាលអណ្តាតភ្លើងនោះ មិនត្រូវធ្វើទុកក្នុងចិត្តនូវស្មៅ ឬឧសខាងក្រោមនិងសំណុំផ្សែងខាងលើ មិនត្រូវពិចារណាពណ៌ មិនត្រូវកំណត់ធ្វើទុកក្នុងចិត្ត នូវលក្ខណៈដែលក្តៅនោះឡើយ គប្បីទាញស្រាវយកពណ៌មកផ្អែបធ្វើជានិស្ស័យ ហើយតាំងចិត្តទុកតែក្នុងបញ្ញត្តិធម៌ គឺពាក្យដែលលោកសន្មតហៅថា "ភ្លើង" ដោយមានធាតុភ្លើងផ្សាយឡើងច្រើនប៉ុណ្ណោះ ហើយ

---

១- វិធីធ្វើកសិណបែបនេះ សម្រាប់ព្រះយោគីជាអាទិកម្មិក បើព្រះយោគីអ្នកមានអភិនីហារ សម្លឹងមើលតែអណ្តាតប្រទីប ឬភ្លើងក្នុងចង្ក្រានជាដើមក៏បាន ។

តាំងកំណត់បរិកម្មធ្វើទុកក្នុងចិត្តថា “**តេជោ តេជោ** ភ្លើងៗ” ដូច្នេះ ជួនកាលបើកភ្នែកសម្លឹងមើល ជួនកាលធ្មេចភ្នែកនឹករំពឹង ដរាបដល់ឧគ្គហនិមិត្ត និងបដិភាគនិមិត្តកើតឡើង ។

ឧគ្គហនិមិត្តក្នុងតេជោកសិណនេះ ប្រាកដហាក់ដូចជាអណ្តាតភ្លើងដាច់ៗ ធ្លាក់ចុះមក បើកសិណនោះមានអង្កត់ដុំរងើក ផេះ ឬផ្សែង ក៏ប្រាកដឡើងយ៉ាងនោះ ឯបដិភាគ-និមិត្ត តាំងនៅនឹងថ្កល់ឥតមានកម្រើក ហាក់ដូចជាកំណាត់សំពត់កម្ពលមានពណ៌ក្រហម ដែលគេតម្កល់ទុកឰដ៏អាកាស ឬហាក់ដូចជាផ្លិតជាវិការនៃមាស ពុំនោះហាក់ដូចជាសសរមាស ដែលគេលើកបញ្ឈរឡើងឰដ៏អាកាស ។

## វាយោកសិណ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងវាយោកសិណ គប្បីកំណត់ចុងអំពៅក្តី ចុងឫស្សីក្តី ដែលស្មើត្រឹមក្បាល ឬសក់របស់មនុស្សក្តី ដែលមើលទៅឃើញខ្យល់បក់មកត្រូវរំភើយៗ ពុំនោះត្រូវអង្គុយនៅត្រង់ចន្លោះបង្អួច ឬត្រង់ប្រហោងជញ្ជាំង កាលបើខ្យល់

ផាត់ចូលមកពាល់ត្រូវកាយបទេសត្រង់ណា គប្បីប្រុងស្មារតីទុកថា ខ្យល់បក់មកត្រូវត្រង់នេះ ហើយបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា **“វាយោ វាយោ** ខ្យល់ៗ” ដូច្នេះ ដរាបដល់ឧគ្គហនិមិត្តនិងបដិភាគនិមិត្តកើតឡើង ។

ក្នុងវាយោកសិណនេះ ឧគ្គហនិមិត្តប្រាកដឡើងទ្រង់ញ័រ ហាក់ដូចជាសំណុំចំហាយនៃបាយាស ដែលទើបនឹងដាក់ចុះមកអំពីបង្ក្រាន ឯបដិភាគនិមិត្ត ស្ងប់ឥតមានកម្រើកឡើយ ។

## នីលកសិណ

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងនីលកសិណ គប្បីយកផ្កាឈើដែលមានពណ៌ខៀវមកដាក់ឲ្យពេញក្នុងប្រអប់ជាដើម ធ្វើឲ្យពេញស្មើត្រឹមកណ្ដាប់មាត់ ហើយចងឲ្យស្មើដូចជាផ្ទៃស្គរ ពុំនោះនឹងយកវត្ថុអ្វីក៏បានឲ្យតែមានពណ៌ខៀវ ទោះនឹងយកទៅសៀតទុកនៅជញ្ជាំងជាដើម ធ្វើជាកសិណក៏បាន កុំឲ្យតែលាយឡំដោយពណ៌ឯទៀតផ្សេងៗ ហើយបរិកម្មធ្វើទុកក្នុងចិត្តថា

"នីលំ នីលំ ខៀវៗ" ដូច្នេះ ដរាបដល់ឧគ្គហនិមិត្ត និង បដិភាគនិមិត្តកើតឡើង ។

ក្នុងនីលកសិណនេះឧគ្គហនិមិត្ត តាំងឡើងប្រាកដ នៅមានទម្រង់កេសរ ទងនិងបន្លោះនៃត្របកជាដើម ឯបដិ-ភាគនិមិត្ត ប្រាកដបាក់ដូចជាផ្ទិតជាវិការនៃកែវមណីមាន ពណ៌ខៀវលេចបេញមកអំពីមណ្ឌលនៃកសិណ ទៅតាំងនៅ ឰដ៏អាកាស ។

## បីតកសិណ-លោហិតកសិណ-ឱទាតកសិណ

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងចម្រើនយក និមិត្តក្នុងបីតកសិណក្តី លោហិតកសិណក្តី ឱទាតកសិណក្តី គប្បីយកផ្កាឈើជាដើមមកធ្វើជាមណ្ឌលកសិណ ដូចន័យ ដែលពោលមកហើយក្នុងនីលកសិណ ប្លែកគ្នាតែពណ៌ គឺបីត-កសិណពណ៌លឿង លោហិតកសិណពណ៌ក្រហម ឱទាត-កសិណពណ៌ស ហើយត្រូវបរិកម្មធ្វើទុកក្នុងចិត្តតាមឈ្មោះ របស់កសិណនោះៗ ថា "**បីតកំ បីតកំ** លឿងៗ, **លោហិតកំ លោហិតកំ** ក្រហមៗ **ឱទាតំ ឱទាតំ** សៗ ដូច្នេះ ដរាបដល់

ឧគ្គហនិមិត្តនិងបដិភាគនិមិត្តកើតឡើង សូម្បីនិមិត្តទាំង ២ យ៉ាងនេះទៀតក៏ដូចគ្នានឹងនីលកសិណ ប្លែកគ្នាខ្លះតែបដិភាគ-និមិត្ត គឺក្នុងបីតកសិណ បដិភាគនិមិត្តតាំងឡើងប្រាកដដូចផ្ទិតជាវិការនៃកែវមណីមានពណ៌លឿង ក្នុងលោហិតកសិណដូចផ្ទិតជាវិការនៃកែវមណីមានពណ៌ក្រហម ឯក្នុងឱទាត-កសិណដូចផ្ទិតជាវិការនៃកែវមណីមានពណ៌ស ។

## អាលោកកសិណ

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងចម្រើនយកនិមិត្តក្នុងអាលោកកសិណ គប្បីកំណត់យកពន្លឺព្រះអាទិត្យឬព្រះបន្ទ្រ ដែលបាំងធ្លុះចូលទៅតាំងនៅជាមណ្ឌលព្ធដ៏ជញ្ជាំង ឬបាំងធ្លុះតាមចន្លោះសំណុំស្លឹកឈើ មកតាំងនៅជាមណ្ឌលលើផែនដី ពុំនោះគប្បីយកក្អមមកចោះទម្លុះឲ្យមានប្រហោងយ៉ាងមូល ឧជប្រទីបដាក់ចុះទៅក្នុងនោះគ្របមាត់ឲ្យជិត នាំយកទៅដាក់បែរមុខផ្ទប់ទៅខាងជញ្ជាំង កាលបើពន្លឺប្រទីបនោះបាំងធ្លុះជាមណ្ឌលមូលជាប់ទៅនឹងជញ្ជាំង ហើយគប្បីកំណត់បរិកម្មធ្វើទុកក្នុងចិត្តថា “**អាលោកោ អាលោកោ** ពន្លឺៗ” ដូច្នេះ

ជរាបដល់និមិត្តទាំងពីរកើតឡើង ។

ក្នុងអាលោកកសិណនេះ ឧគ្គហនិមិត្ត កើតឡើង ប្រាកដដូចជាមណ្ឌលនៃពន្លឺ ដែលតាំងឡើងជាប្រក្រតីពួងដំ ជញ្ជាំងឬលើផែនដីតាមទំនងនៃកសិណ ឯបដិភាគនិមិត្ត ប្រាកដដូចជាពន្លឺតាំងឡើងជាដុំយ៉ាងក្រាស់ ហើយថ្លាវិសេស ហាក់ដូចជាពន្លឺដែលផ្សាយចេញអំពីសរីរកាយ នៃព្រះមាន-ព្រះភាគមានព្យាម ១ ជាប្រមាណ ។

## អាកាសកសិណ

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងបម្រើនយក និមិត្តក្នុងអាកាសកសិណ គប្បីចោះជញ្ជាំងក៏បាន កំណាត់ ស្បែក ឬកំណាត់កន្ទេលជាដើមក៏បាន ធ្វើជាវង់កសិណ ឱ្យមានប្រហោងមូលទំហំទទឹង ១ ចំអាម ៤ ធ្នាប់ ហើយ សម្លឹងយកអាកាសតាមចន្លោះប្រហោងនោះ មកកំណាត់ធ្វើទុក ក្នុងចិត្តថា “**អាកាសោ អាកាសោ** ៗៗ” ដូច្នេះ ជរាប ដល់និមិត្តទាំងពីរកើតឡើង ។

ក្នុងអាកាសកសិណនេះ ឧគ្គហនិមិត្តតាំងឡើងជាវង់

អាកាស នៅជាប់ដោយទម្រង់របស់កសិណ គឺប្រាកដដូចជាចន្លោះប្រហោងរបស់កសិណ ព្រមទាំងទីបំផុតនៃជញ្ជាំងជាដើម តែបើព្រះយោគីនឹងបម្រើនពង្រីកឲ្យធំឡើងទៀតពុំបាន ឯបដិភាគនិមិត្តតាំងឡើងប្រាកដដូចជាមណ្ឌលនៃអាកាស មិនមានទីបំផុតរបស់ជញ្ជាំងជាដើមឡើយ ហើយព្រះយោគីនឹងបម្រើនពង្រីកឲ្យធំឡើងទៀតក៏ធំឡើងបាន ។

**កសិណ ១០ ចប់**

---

## *អសុភកម្មដ្ឋាន ១០*

## **ឧទ្ធុមាតកាអសុភ**

បន្ទាប់មកអំពីកសិណទាំង ១០ នឹងពណ៌នានូវអសុភកម្មដ្ឋានទាំង ១០ តទៅទៀត តែនឹងពោលនូវឧទ្ធុមាតកអសុភជាមុន ។

កាលបើព្រះយោគាវចរ មានប្រាថ្នាដើម្បីនឹងបម្រើនយកនិមិត្តក្នុងឧទ្ធុមាតកអសុភ គប្បីចូលទៅកាន់សំណាក់កល្យាណមិត្តដូចន័យដែលពោលមកក្នុងខាងដើម រៀនយកនូវវិធីដើរទៅកាន់អសុភនិមិត្ត វិធីកំណត់នូវនិមិត្តជិតខាង វិធីកាន់យក

នូវនិមិត្ត វិធីពិចារណាតាមផ្លូវដែលដើរទៅដើរមក រហូតដល់អប្បនាវិធីជាទីបំផុត បេញទៅនៅក្នុងទីសេនាសនៈដ៏សមគួរដល់សមាធិភាវនាហើយសន្សឹមស្វែងរកអសុភនិមិត្តនិងបម្រើន ។

ត្រង់ដែលថា រៀនយកនូវវិធីដើរទៅកាន់អសុភនិមិត្តនោះដូចម្ដេច?

ត្រូវរៀនឲ្យដឹងថា មុនដែលនឹងដើរទៅកាន់កន្លែងដែលរូបអសុភតម្កល់នៅ ត្រូវប្រាប់ដល់លោកដែលជាសង្ឃត្ថេរជាមុនសន្សឹមដើរបេញទៅ មិនត្រូវទៅ ២ ឬ ៣ រូប ត្រូវធ្វើទុកក្នុងចិត្តនូវមូលកម្មដ្ឋានជានិច្ច ត្រូវកាន់ឈើប្រត់ដើរទៅ ដើម្បីការពារនូវអន្តរាយមានឆ្កែជាដើម ត្រូវដើរប្រុងស្មារតីសង្រួមឥន្ទ្រិយទាំង ៦ ត្រូវកំណត់ឲ្យដឹងទិស ដឹងទ្វារ ដឹងផ្លូវដែលខ្លួនបេញដើរទៅ ត្រូវឲ្យដឹងខាងឆ្វេងខាងស្ដាំ នៅទីណាមានវត្ថុអ្វី មិនត្រូវដើរចូលទៅកាន់អសុភអំពីខាងក្រោមខ្យល់ ។

ត្រង់ដែលថា រៀនយកនូវវិធីកំណត់និមិត្តជិតខាងនោះដូចម្ដេច ។

ត្រូវរៀនឲ្យដឹងថា ពេលដែលចូលទៅដល់រូបអសុភហើយ

មិនត្រូវសម្លឹងមើលរូបអសុភជាដម្បូងឡើយ ត្រូវកំណត់រកទិសដែលសម្លឹងមើលទៅឃើញអសុភប្រាកដ ត្រូវឈរនៅក្នុងទីជាបន្លោះមិនជាខាងក្រោមខ្យល់ខាងលើខ្យល់ មិនឆ្ងាយពេក ជិតពេក មិនបែរខាងក្បាលពេក បែរខាងចុងជើងពេក ត្រូវកំណត់ទីជុំវិញឲ្យដឹងថា ខាងណាមានវត្ថុអ្វី ថ្ម ឬ ដំបូកជាដើម ធំ ឬ តូច ខ្ពស់ ឬ ទាប ជាមុន ត្រូវធ្វើទុកក្នុងចិត្តនូវវត្ថុជិតខាងផ្អែបជាមួយនឹងតួអសុភថា "នេះថ្មនេះអសុភ" ជាដើម ។

ត្រង់ដែលថា រៀនយកនូវវិធីកាន់យកនូវនិមិត្តនោះ ដូចម្តេច?

ត្រូវរៀនឲ្យដឹង នូវវិធីកាន់យកនូវនិមិត្ត ដោយអាការ ១១ យ៉ាងគឺៈ

១- **វណ្ណតោ** កំណត់ឲ្យដឹងថា "នេះជាសរីរៈរបស់មនុស្ស សម្បុរស ឬខ្មៅជាដើម" ។

២- **លិង្គតោ** កំណត់ឲ្យដឹងថា "នេះជាសរីរៈរបស់មនុស្សស្ថិតនៅក្នុងបឋមវ័យ មជ្ឈិមវ័យ ឬបច្ឆិមវ័យ" ។

៣- **សណ្ឋានតោ** កំណត់ឲ្យដឹងថា “នេះជាសណ្ឋានក្បាល ឬ សណ្ឋានកជាដើម” ។

៤- **ទិសតោ** ក្នុងសរីរៈនេះតាំងអំពីផ្ចិតចុះទៅចាត់ជាទិសខាងក្រោម អំពីផ្ចិតឡើងលើ ចាត់ជាទិសខាងលើ ត្រូវកំណត់ឲ្យដឹងថា “នេះជាទិសខាងក្រោមនេះជាទិសខាងលើ” ឬកំណត់ឲ្យដឹងថា “អញឈរនៅក្នុងទិសនេះ អសុភនៅក្នុងទិសនេះ” ។

៥- **ឱកាសតោ** កំណត់ឲ្យដឹងថា “ដៃនៅក្នុងឱកាសនេះ ជើងនៅក្នុងឱកាសនេះ” ជាដើម ឬកំណត់ឲ្យដឹងថា “អញឈរនៅក្នុងឱកាសនេះ អសុភនៅក្នុងឱកាសនេះ” ។

៦- **បរិច្ឆេទតោ** កំណត់ឲ្យដឹងថា “សរីរៈនេះ ខាងក្រោមត្រឹមបាទជើង ខាងលើត្រឹមចុងសក់ ជុំវិញត្រឹមស្បែកក្នុងបន្លោះនេះពេញដោយសាកអសុភៈ ៣២ ប្រការ” ឬកំណត់ឲ្យដឹងថា “ដៃត្រឹមនេះជើងត្រឹមនេះ” ជាដើម ។

៧- **សន្និតោ** កំណត់ឲ្យដឹងទីតនៃសរីរៈ ទាំង១៨០[១]

៨- **វិវរតោ** កំណត់ឲ្យដឹងទីចន្លោះ របស់អសុភមានចន្លោះដៃចន្លោះជើងចន្លោះពោះជាដើម ។

៩- **និន្នតោ** កំណត់ឲ្យដឹងទីទំនាបក្នុងសរីរៈ របស់អសុភមានរណ្ដៅភ្នែកនិងក្នុងមាត់ជាដើម ឬកំណត់ឲ្យដឹងថា "អញឈរនៅក្នុងទីទំនាប ឯអសុភស្ថិតនៅក្នុងទីទួល" ។

១០- **ឧន្នតតោ** កំណត់ឲ្យដឹងទីខ្ពស់ក្នុងសរីរៈរបស់អសុភ មានជង្គង់និងទ្រូងជាដើម ឬកំណត់ឲ្យដឹងថា "អញឈរនៅក្នុងទីខ្ពស់ ឯអសុភស្ថិតនៅក្នុងទីទំនាប" ។

១១- **សមន្តតោ** ត្រូវបញ្ជូនញាណឲ្យប្រព្រឹត្តទៅសព្វក្នុងសរីរៈរបស់អសុភទាំងមូល បើត្រង់ណាតាំងឡើងប្រាកដ សន្សំមកំណត់ធ្វើទុកក្នុងចិត្តត្រង់ណោះ ។

ត្រង់ដែលថារៀនយកនូវវិធីពិចារណា តាមផ្លូវដែលដើរទៅដើរមកនោះដូចម្ដេច?

---

១- ទីត ១៨០ លោកមិនបានរាប់ចំនួនគ្រប់ទាំងអស់ទុកក្នុងទីនេះ លោករាប់តែទីតធំ ១៤ គឺ ក្នុងដៃស្ដាំ ៣ ឆ្វេង ៣ ជើងស្ដាំ ៣ ឆ្វេង ៣ ក ១ ចង្កេះ ១ ទីតក្នុងដៃស្ដាំ ៣ នោះគឺ ត្រង់ស្មា ១ ដុំដៃ ១ កដៃ ១ ខាងឆ្វេងក៏ដូចគ្នា ។ ទីតក្នុងជើងស្ដាំ ៣ នោះគឺ ត្រង់ត្រគាក ១ ជង្គង់ ១ កជើង ១ ខាងឆ្វេងក៏ដូចគ្នា ។

ក្នុងវិធីពិចារណាតាមផ្លូវ ដែលដើរទៅនិងដើរមកនោះ ត្រង់វិធីពិចារណាតាមផ្លូវដែលដើរទៅ បានពោលមកហើយក្នុងវិធីដើរទៅកាន់អសុភនិមិត្តខាងដើម នឹងពោលតែវិធីពិចារណាតាមផ្លូវដែលដើរមក ក៏ឯវិធីពិចារណាតាមផ្លូវដែលដើរមកនោះគឺ កាលបើព្រះយោគីបានកាន់យកនូវនិមិត្តដោយប្រពៃហើយ តែមិនទាន់បានសម្រេចកិច្ចដល់ទីបំផុតរបស់ភាវនា ត្រូវថយត្រឡប់មកកាន់ទីសេនាសនៈវិញ ក្នុងពេលដែលដើរមកនោះ ត្រូវធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននោះជាដរាប ត្រូវដើរប្រុងស្មារតីសង្រួមឥន្ទ្រិយទាំង ៦ ពេលដែលចេញចាកព្រៃស្មសានមក ត្រូវកំណត់ផ្លូវ កំណត់ទិស កំណត់វត្ថុជិតខាងឲ្យសព្វគ្រប់ដូចកាលដែលដើរចូលទៅ លុះមកដល់ទីសេនាសនៈហើយ បើនឹងចង្ក្រមក្តី នឹងអង្គុយក្តី ត្រូវអធិដ្ឋានទីចង្ក្រមណ៍ តាក់តែងទីអង្គុយឲ្យបែរមុខឆ្ពោះទៅកាន់ទីដែលអសុភតម្កល់នៅ ហើយត្រូវពិចារណាបញ្ជូនចិត្តនឹកទៅរកអសុភដែលខ្លួនបម្រើននោះ ។

វិធីដែលនឹងកំណត់នូវនិមិត្តជិតខាងជាដើមនេះ មានប្រយោជន៍យ៉ាងណាខ្លះ ។

វិធីកំណត់និមិត្តជិតខាង នឹងមិនវង្វេងភ្លេចស្មារតីក្នុងពេលដែលអសុភសម្តែងនូវអាការគួរសម្បើម ។

វិធីកាន់យកនូវនិមិត្តដោយអាការ ១១ យ៉ាង ដើម្បីនឹងបង្ក្រៀកទុកនូវកម្មដ្ឋានឲ្យជាបច្ច័យដល់ឧគ្គហនិមិត្ត បដិ-ភាគនិមិត្ត និងអប្បនាឈាន ជរាបដល់អរហត្តផលជាទីបំផុត បើចម្រើននូវវិបស្សនាតទៅទៀត ។

វិធីពិចារណាតាមផ្លូវដែលដើរទៅនិងដើរមក ដើម្បីញុំាងវិថីរបស់កម្មដ្ឋាន ឲ្យសម្រេចក្នុងពេលដែលព្រះយោគីចម្រើនបាននូវឧគ្គហនិមិត្ត ត្រឡប់ទៅកាន់ទីសេនាសនៈវិញ បើនិមិត្តនោះវិនាសបាត់ទៅ ហើយព្រះយោគីរឭកសាតាមលំអាននោះក៏នឹងត្រឡប់កើតឡើងវិញ ។

កាលព្រះយោគី បានរៀនយកនូវវិធីទាំងពួងដូចពោលមកនេះ ក្នុងសំណាក់នៃកល្យាណមិត្តសព្វគ្រប់ហើយ បើឃើញឬឮដំណឹងថា អសុភដែលហើមពោរពងឡើងមាននៅក្នុងទីណា ក៏គប្បីដើរទៅកាន់ទីនោះ ប្រព្រឹត្តតាមលំអានដែលពោលមក លុះទៅដល់ហើយត្រូវចម្រើនឈរ ឬអង្គុយក៏បាន កុំឲ្យ

ឆ្ងាយពេក ជិតពេក ឱ្យល្មមតែក្រឡេកមើលទៅអសុភឃើញច្បាស់ ត្រូវសង្ឃឹមថា “អញមុខជានឹងរួចចាកសំសារទុក្ខដោយបដិបទានេះជាពិត” ត្រូវសម្គាល់នូវអសុភហាក់ដូចជាដួងកែវ ត្រូវតាំងសេចក្តីគោរពឱ្យណាស់ ត្រូវមានសេចក្តីពេញចិត្តឱ្យណាស់ ត្រូវបង្គ្រៀកចិត្តទុកក្នុងអារម្មណ៍នោះ ហើយបើកភ្នែកសម្លឹងមើលកំណត់ធ្វើទុកក្នុងចិត្តថា **“ឧទ្ធុមាតកំ បដិក្កូលំ ឧទ្ធុមាតកំ បដិក្កូលំ** អសុភហើមពោរពងឡើងមុខគួរឱ្យខ្ពើមៗ” ហើយធ្មេចភ្នែកនឹករំពឹងកំណត់ធ្វើទុកក្នុងចិត្តដូចដែល ដល់ ១ រយចប់ក្តី ១ ពាន់ចប់ក្តី ដរាបដល់កាន់យកនូវនិមិត្តបានដោយល្អ ឧគ្គហនិមិត្តកើតឡើង បើកភ្នែកក៏ឃើញ ធ្មេចភ្នែកបុះទៅវិញក៏ឃើញដូចគ្នា លុះចេញចាកអំពីទីនោះទៅកាន់ទីសេនាសនៈរបស់ខ្លួនវិញ ក៏ត្រូវធ្វើទុកក្នុងចិត្តឱ្យរឿយៗ លុះត្រាតែបដិភាគនិមិត្តកើតឡើង ។

ឧគ្គហនិមិត្ត ក្នុងឧទ្ធុមាតកអសុភនេះ តាំងឡើងមានទំនងប្លែក មុខគួរឱ្យខ្ពើម សម្តែងអាការគួរឱ្យស្បើម ឯបដិភាគ-និមិត្ត ប្រាកដឡើងហាក់ដូចជាបុរសមានអវយវៈ តូចធំយ៉ាង

ជ្លោសបរិភោគផ្អែតហើយដេកនៅ លំដាប់នោះនីវរណធម៌ និងកិលេសរបស់ព្រះយោគីអង្គនោះ ក៏ទ្រោមស្ងប់ទៅ ដាលំដាប់ ចិត្តសោតក៏តម្កល់នៅមាំដោយឧបចារសមាធិ កាលបើព្រះ យោគីសេពនូវនិមិត្តនោះជារឿយៗ ពុំបានលះបង់ព្យាយាមក៏ នឹងបានសម្រេចដល់អប្បនាឈាន តែក្នុងកម្មដ្ឋាននេះមាន អំណាចឲ្យសម្រេចបានតែត្រឹមបឋមជ្ឈានប៉ុណ្ណោះ មិនមាន អំណាច ឲ្យសម្រេចដល់អប្បនាឈានជាន់លើទៀតបានឡើយ ទោះបីអសុភទាំង ៩ ខាងចុង ក៏ដូចគ្នា ។

## វិធីលក្ខអសុភ

បន្ទាប់មកអំពីឧទ្ធុមាតកអសុភ នឹងពណ៌នាក្នុងអសុភ ទាំង ៩ ខាងចុងតទៅ ។

ក៏ក្នុងអសុភទាំង ៩ នេះ មានវិធីទាំងពួងដូចគ្នានឹងឧទ្ធុ-មាតកអសុភស្ទើរតែនឹងទាំងអស់ នៅមានសេចក្ដីដែលប្លែកគ្នា នោះបន្តិចបន្តួច ហេតុនោះនឹងពណ៌នាតែសេចក្ដីណាដែលប្លែក គ្នាប៉ុណ្ណោះ ឯសេចក្ដីឯទៀតគប្បីជ្រាបតាមន័យដែលពោល មកក្នុងឧទ្ធុមាតកអសុភឯណោះចុះ ។

តែក្នុងអសុភទាំង ៩ នេះ នឹងពោលនូវវិនីលកអសុភជាមុន ហើយទើបពណ៌នានូវអសុភដ៏សេសតរៀងទៅ ។

ក៏ក្នុងវិនីលកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា “**វិនីលកំ បដិកូលំ វិនីលកំ បដិកូលំ** អសុភហើមមានពណ៌ខៀវ មុខគួរឲ្យខ្ពើមៗ” ។

ឧគ្គហនិមិត្តក្នុងវិនីលកអសុភនេះ ប្រាកដឡើង នៅមានពណ៌ពពាលៗ ដោយច្រើន ឯបដិភាគនិមិត្ត ប្រាកដឡើងតាមពណ៌ដែលផ្សាយឡើងច្រើន ពណ៌ក្រហម-ស-ខៀវ ពណ៌ណាមួយផ្សាយឡើងច្រើន ក៏ប្រាកដដូច្នោះ ។

## វិបុព្វកាអសុភ

ក្នុងវិបុព្វកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា “**វិបុព្វកំ បដិកូលំ វិបុព្វកំ បដិកូលំ** អសុភហើមមានខ្ទុះហូរទៅខាងលើខាងក្រោម មុខគួរឲ្យខ្ពើមៗ” ។

ឧគ្គហនិមិត្ត ក្នុងវិបុព្វកអសុភនេះ ប្រាកដឡើងដូចខ្ទុះកំពុងហូរចេញ ឯបដិភាគនិមិត្ត ប្រាកដឡើងទ្រង់ស្ងប់ស្ងៀមមិនមានកម្រើក ។

# វិច្ឆិទ្ទកាអសុភ

ក៏ឯវិច្ឆិទ្ទកអសុភនេះ តែងមានទៅក្នុងមណ្ឌលនៃទីចម្បាំង ក្នុងដងព្រៃដែលចោរតែងនៅអាស្រ័យ ក្នុងទីដែលពិឃាដមនុស្សទោស ឬក្នុងព្រៃដែលជាទីលំនៅនៃសត្វសាហាវមានសីហៈជាដើម ហេតុនោះ បើព្រះយោគីស្វែងរកបានក្នុងប្រទេសណាមួយ ហើយអសុភនោះដាច់បេញឃ្លាតអំពីគ្នាឆ្ងាយ ត្រូវប្រមូលអារម្មណ៍ ឲ្យមូលពិចារណារូបចូលជាមួយគ្នា ពុំនោះនឹងប្រើគេឲ្យប្រមូល ឬនឹងប្រមូលខ្លួនឯងឲ្យមូលគ្នាមកដោយឈើប្រត់ជាដើមក៏បាន កុំតែចាប់ពាល់ដោយដៃ(១) ហើយត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា **"វិច្ឆិទ្ទកំ បដិក្កូលំ វិច្ឆិទ្ទកំ បដិក្កូលំ** អសុភដែលគេកាត់ដាច់ពាក់កណ្តាលខ្លួន មុខគួរឲ្យខ្ពើមៗ" ។

ឧគ្គហនិមិត្ត ក្នុងវិច្ឆិទ្ទកអសុភនេះ ប្រាកដឡើងហាក់ដូចជាដាច់ពាក់កណ្តាល ឯបដិភាគនិមិត្ត ប្រាកដដូចជាពេញបរិបូរឡើងវិញ ។

---

១- បើចាប់ពាល់ដោយដៃឯង នឹងទៅជាស្និទ្ធស្នាលមិនកើតសង្វេគ ។

# វិក្ខាយិតកាអសុភ

ក្នុងវិក្ខាយិតកអសុភនេះ ត្រូវបរិកម្មកំណាត់ធ្វើទុកក្នុងចិត្តថា **“វិក្ខាយិតកំ បដិក្កូលំ វិក្ខាយិតកំ បដិក្កូលំ** អសុភដែលសត្វកកេរស៊ី មានសំណាមរលុះរលួយផ្សេងៗ មុខគួរឲ្យខ្ពើមៗ” ។

ឧគ្គហនិមិត្តក្នុងវិក្ខាយិតកអសុភនេះ ប្រាកដឡើងនៅដួចស្នាមដែលសត្វកកេរស៊ីក្នុងទីនោះៗ ឯបដិភាគនិមិត្តប្រាកដឡើងនៅពេញបរិបូរដួចដើម ។

# វិក្ខិត្តកាអសុភ

ក្នុងវិក្ខិត្តកអសុភនេះ ត្រូវបរិកម្មកំណាត់ធ្វើទុកក្នុងចិត្តថា **“វិក្ខិត្តកំ បដិក្កូលំ វិក្ខិត្តកំ បដិក្កូលំ** អសុភដែលគេកាត់ដាច់បេញពីគ្នាជាកំណាត់ៗ រាត់រាយទៅផ្សេងៗ មុខគួរឲ្យខ្ពើមៗ” ។

ឧគ្គហនិមិត្ត ក្នុងវិក្ខិត្តកអសុភនេះ ប្រាកដឡើងនៅមានដាចន្លោះៗ តែអវយវៈដែលប្រាកដ ឯបដិភាគនិមិត្តប្រាកដឡើង ពេញបរិបូរដួចដើម ។

# ហតវិក្ខិត្តកអសុភ

ក្នុងហតវិក្ខិត្តកអសុភនេះ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងចិត្តថា “**ហតវិក្ខិត្តកំ បដិក្កូលំ ហតវិក្ខិត្តកំ បដិក្កូលំ** អសុភដែលគេកាប់សាប់មានស្នាមសាំរវាម មុខគួរឲ្យខ្ពើមៗ” ។

ឧគ្គហនិមិត្ត ក្នុងហតវិក្ខិត្តកអសុភនេះ ប្រាកដឡើងនៅមានស្នាមមុខរបួស ឯបដិភាគនិមិត្ត ប្រាកដឡើងពេញបរិបូរដូចដើម ។

# លោហិតកអសុភ

ក៏ឯលោហិតកអសុភនេះ ព្រះយោគីរមែងស្វែងរកបានក្នុងមណ្ឌលនៃទីចម្បាំងជាដើម ដូចពោលមកហើយក្នុងវិច្ឆិទ្ទក-អសុភ តែត្រូវចម្រើនបានតែក្នុងពេលដែលឈាមកំពុងហូរចេញ អំពីមុខរបួសដែលគេប្រហារ ពុំនោះនឹងចម្រើនយកនិមិត្តក្នុងឈាមដែលហូរចេញអំពីមុខបូស ឬពកដែលបែកធ្លាយជាដើម ក្រៅអំពីអសុភស្លាប់ក៏បាន ត្រូវបរិកម្មកំណត់ទុកក្នុងចិត្តថា “**លោហិតកំ បដិក្កូលំ លោហិតកំ បដិក្កូលំ** អសុភមានឈាមហូរស្រោចស្រព មុខគួរឲ្យខ្ពើមៗ” ។

ឧគ្គហនិមិត្ត ក្នុងលោហិតកអសុភនេះ ប្រាកដឡើង មានអាការញ័រដូចជាផ្ទាំងសម្ពត់ មានពណ៌ក្រហមដែលខ្យល់ បក់មកត្រូវ ឯបដិភាគនិមិត្ត ប្រាកដឡើងមានសភាពស្ងប់ មិនមានកម្រើក ។

## បុឡុវកៈ[១]អសុភ

ក្នុងបុឡុវកអសុភនេះ ត្រូវបម្រើនយកនិមិត្តក្នុងកាល ដែលដង្កូវកំពុងហូរបេញតាមទ្វារទាំង ៩ ឬក្នុងកាលដែល សរីរអសុភនោះ រលួយរបេះបេញបាកគ្នាអស់ហើយ នៅ សល់តែដង្កូវផ្ដុំគ្នាជាគំនរ ដូចគំនរបាយស្រូវសាលីដូច្នោះ ក៏បាន ទុកណាជាសរីរៈនៃអសុភនោះ ជាសរីរៈរបស់ឆ្កែក្ដី បបកក្ដី មនុស្សក្ដី គោ ក្របី ដំរី សេះ ឬពស់ថ្លាន់ជាដើមក្ដី ក៏គួរបម្រើនបានដូចគ្នា ត្រូវបរិកម្ម កំណត់ធ្វើទុកក្នុងចិត្តថា “**បុឡុវកំ បដិក្កូលំ បុឡុវកំ បដិក្កូលំ** អសុភមានដង្កូវបុះហូរ បេញតាមទ្វារទាំង ៩[២] មុខគួរឲ្យខ្ពើមៗ” ។

---

១- “បុឡុវក” ដូច្នេះក៏ថាដែរ ។ ២- បើអសុភនោះនៅសល់តែគំនរដង្កូវ ត្រូវថា “អសុភនៅសល់តែគំនរដង្កូវ ដូចដុំបាយនៃស្រូវសាលី” ដូច្នេះវិញ ។

ឧគ្គហនិមិត្ត ក្នុងបុឡុវកអសុភនេះ ប្រាកដឡើងទ្រង់ញ៉ាវ ឯបដិភាគនិមិត្ត ប្រាកដឡើងទ្រង់ស្ងប់ដូចដុំបាយនៃស្រូវសាលី ។

## អដ្ឋិកអសុភ

ក៏ឯអដ្ឋិកអសុភនេះ ទោះបីនៅគង់ជារាងឆ្អឹងទាំងមូលក្តី ជ្រុះរង្គោះបេញទៅដោយឡែកៗអំពីគ្នាក្តី សូម្បីនៅសល់តែឆ្អឹង ១ កំណាត់ ២ កំណាត់ ពុកផុយដូចម្តេចក្តី ក៏គួរបម្រើនយកនិមិត្តបានដូចគ្នាទាំងអស់ ត្រូវបរិកម្មកំណត់ធ្វើទុកក្នុងបិត្តថា “**អដ្ឋិកំ បដិកូលំ អដ្ឋិកំ បដិកូលំ** អសុភមាននៃរាងឆ្អឹងខ្ចាត់ខ្ចាយរាត់រាយទៅផ្សេងៗ មុខគួរឲ្យខ្ពើមៗ” ។

ឧគ្គហនិមិត្តក្នុងអដ្ឋិកអសុភនេះ ប្រាកដឡើង នៅមានជាបន្លោះៗ ឯបដិភាគនិមិត្តប្រាកដឡើងពេញបរិបូរ(១) ។

---

១- និមិត្តប្រាកដឡើងបែបនេះ ចំពោះតែអសុភដែលសល់នៅតែរាងឆ្អឹងទាំងមូល បើអសុភដែលមានឆ្អឹងខ្ចាត់ខ្ចាយរាត់រាយទៅផ្សេងៗឬអសុភដែលសល់នៅតែឆ្អឹង ១ កំណាត់ ២ កំណាត់ប៉ុណ្ណោះ និមិត្តទាំង ២ យ៉ាង ក៏ប្រាកដឡើងមិនប្លែកអំពីសណ្ឋានរបស់ឆ្អឹងគោប៉ុន្មានឡើយ ។

ន័យម្យ៉ាងទៀតថា “ឧគ្គហនិមិត្តប្រាកដឡើង គួរឲ្យខ្ពើម គួរឲ្យខ្លាច ឯបដិភាគនិមិត្តប្រាកដឡើង គួរឲ្យកើតបីតិនិងសោមនស្ស” ។

អសុភកម្មដ្ឋានទាំង ១០ នេះ កាលបើព្រះយោគីបម្រើនបានដល់បដិភាគនិមិត្ត ក្នុងអសុភណាមួយហើយ នីវរណធម៌ទាំង ៥ មានកាមច្ឆន្ទជាដើម ក៏ព្រះយោគីអង្គនោះលះបង់បានជាវិក្ខម្ភនប្បហាន⑵ ព្រមគ្នានឹងបដិភាគនិមិត្តកើត ហើយអង្គឈានទាំង ៥ ក៏កើតឡើងផង ខណៈនោះ ព្រះយោគីក៏ចូលដល់ឧបចារជ្ឈាន ហើយតទៅទៀតនឹងអាចចូលបានដរាបដល់អប្បនាឈាន តែចូលបានតែត្រឹមបឋមជ្ឈានប៉ុណ្ណោះ ទុកណាជាព្រះយោគីខំសង្វាតព្យាយាម បម្រើនតទៅទៀតដូចម្ដេចក៏មិនអាចនឹងចូលដល់ឈានជាន់លើទៀតបាន មិនអាចនឹងញុំាងគុណវិសេស មានទិព្វសោតធាតុនិងទិព្វចក្ខុជាដើមឲ្យកើតឡើងបានឡើយ គ្រាន់តែឃើញគំនរអសុភប្រាកដឡើងពេញផែនដីប៉ុណ្ណោះ តែបើព្រះយោគី ទាញយកវិបស្សនា

---

២- លះដោយសង្កត់ទុកមិនឲ្យផុសផុរឡើងបាន ។

មកបម្រើនផ្អែបផង ក៏នឹងបាននសម្រេចនូវលោកុត្តរធម៌ដរាបដល់ព្រះអរហត្តជាទីបំផុត ។

*អសុភកម្មដ្ឋាន ១០ ចប់*

---

## *អនុស្សតិកម្មដ្ឋាន ១០*

## **ពុទ្ធានុស្សតិ**

បន្ទាប់មកអំពីអសុភកម្មដ្ឋានទាំង ១០ នឹងពណ៌នានូវអនុស្សតិកម្មដ្ឋានទាំង ១០ តទៅទៀត តែក្នុងអនុស្សតិកម្មដ្ឋានទាំង ១០ នេះ នឹងពណ៌នានូវពុទ្ធានុស្សតិជាមុន ហើយទើបពណ៌នានូវអនុស្សតិដ៏សេសជាលំដាប់តទៅទៀត ។

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវពុទ្ធានុស្សតិកម្មដ្ឋាន គប្បីឱ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះពុទ្ធ មិនឱ្យមានកម្រើក ហើយចូលទៅរកទីដែលស្ងាត់បាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកដល់គុណរបស់ព្រះពុទ្ធ ចាប់ដើមអំពី **ឥតិបិ សោ ភគវា អរហំ** ដរាបដល់ **ភគវា** ជាទីបំផុត ហើយត្រូវស្រង់យកគុណមួយៗ មករំពឹងពិចារណាថា “**សោ ភគវា ឥតិបិ អរហំ** ព្រះមានព្រះភាគ

អង្គនោះទ្រង់ព្រះនាមថា **អរហំ** ព្រោះហេតុដូច្នេះ ផង(១) ។ ។ ល ។ **សោ ភគវា ឥតិបិ ភគវា** ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **ភគវា** ព្រោះហេតុដូច្នេះផងៗ(២)” ហើយត្រូវឲ្យដឹងសេចក្តីអធិប្បាយក្នុងគុណនោះៗ ឲ្យបានសព្វគ្រប់ផង ។

ដោយអំណាចដែលព្រះយោគីនឹករឭករឿយៗ នូវគុណនៃព្រះមានព្រះភាគតាមន័យដែលពោលមកយ៉ាងនេះ សម័យនោះចិត្តរបស់ព្រះយោគីសោត ក៏ប្រាសចាករាគាទិកិលេស តម្កល់នៅត្រង់ចំពោះទៅរកព្រះតថាគត ព្រមទាំងនីវរណធម៌ ក៏ទ្រោមទៅផង លំដាប់នោះ វិតក្កៈនិងវិចារៈ ក៏កើតឡើងត្រិះរិះពិចារណារឿយៗ នូវពុទ្ធគុណមាន **អរហំ** ជាដើម ហើយបីតិ

---

១- ទ្រង់ព្រះនាមថា “អរហំ” ព្រោះព្រះអង្គឆ្ងាយចាកសត្រូវគឺកិលេសទាំងពួងផង ព្រោះព្រះអង្គបំបាក់បង់នូវកាំរបស់សំសារចក្របានផង ព្រោះព្រះអង្គគួរដល់សក្ការមានបច្ច័យជាដើមផង ព្រោះព្រះអង្គមិនសម្ងំធ្វើបាបក្នុងទីស្ងាត់ផង ។

២- ទ្រង់ព្រះនាមថា “ភគវា” ព្រោះព្រះអង្គមានឥស្សរិយយសផង គួរទទួលនូវបច្ច័យផង ទ្រង់ចែកនូវធម្មរតនៈផង ទ្រង់បំបាក់បង់នូវបាបធម៌មានរាគជាដើមផង មានបារមីធម៌សន្សំមកហើយអស់កាលយូរផង មានកាយនិងចិត្តចម្រើនហើយដោយភាវនាធម៌ដ៏ច្រើនផង ទ្រង់ដល់នូវទីបំផុតនៃភពគឺព្រះនិព្វានផង ទ្រង់សេពនូវអរិយគុណលើសលោកផង ទ្រទ្រង់នូវបុញ្ញសិរីផង ទ្រង់សេពនូវទិព្វព្រហ្មវិហារផង ទ្រង់ខ្ជាក់ចោលនូវដំណើរដែលវិលកើតស្លាប់ក្នុងត្រៃភពផង ។

ឡើងទៀត ដោយអំណាចដែលបីតិកើតឡើងជាបទដ្ឋាន យ៉ាងនេះ កាយបស្សទ្ធិនិងចិត្តបស្សទ្ធិ គឺសេចក្តីស្ងប់កាយ និងស្ងប់ចិត្តក៏កើតឡើង បណ្តាលឲ្យព្រះយោគីប្រាសចាក សេចក្តីក្រវល់ក្រវាយក្នុងកាយនិងចិត្ត ដោយអំណាចដែល ព្រះយោគីមានសេចក្តីក្រវល់ក្រវាយស្ងប់រម្ងាប់ យ៉ាងនេះហើយ សុខប្រព្រឹត្តទៅក្នុងកាយនិងចិត្តក៏កើតឡើងផង ពេលនោះ ចិត្តរបស់ព្រះយោគីសោតក៏តម្កល់នៅមាំ មានពុទ្ធគុណជា អារម្មណ៍ អង្គឈានកើតឡើងក្នុងខណៈជាមួយគ្នារៀងតាម លំដាប់ដូច្នេះ តែក្នុងពុទ្ធានុស្សតិកម្មដ្ឋាននេះ មានអំណាច ឲ្យកើតបានតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចនឹងឲ្យកើត បានដល់អប្បនាឈានឡើយ ព្រោះគុណរបស់ព្រះសម្ពុទ្ធជា គម្ភីរភាពក្រៃពេក ព្រះយោគីមិនអាចនឹងរឭកឲ្យសព្វគ្រប់ទៅ បាន ស្ងួប្បីអនុស្សតិ ៧ ខាងចុង លើកតែកាយគតាសតិនិង អានាបានស្សតិចេញ ក៏គប្បីដឹងថា “មានអំណាចឲ្យសម្រេច បានតែត្រឹមឧបចារជ្ឈាន ដូចជាពុទ្ធានុស្សតិនេះដែរ” ។

## ធម្មានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវធម្មានុស្សតិកម្មដ្ឋាន គប្បីឱ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះធម៌កុំឱ្យមានកម្រើក ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកដល់គុណរបស់ព្រះបរិយត្តិធម៌និងព្រះនព្វលោកុត្តរធម៌ ចាប់ដើមអំពី **ស្វាក្ខាតោ ភគវតា ធម្មោ** ដរាបដល់ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាទីបំផុត ហើយត្រូវស្រង់យកគុណមួយៗ មករំពឹងពិចារណាឱ្យដឹងសេចក្ដីច្បាស់លាស់គ្រប់គុណនោះៗ ។

## សង្ឃានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវសង្ឃានុស្សតិកម្មដ្ឋាន គប្បីឱ្យមានចិត្តជ្រះថ្លាក្នុងគុណរបស់ព្រះសង្ឃកុំឱ្យមានកម្រើក ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកដល់គុណរបស់ព្រះអរិយសង្ឃ ចាប់ដើមអំពី **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ដរាបដល់ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** ជាទីបំផុត

ហើយត្រូវស្រង់យកគុណមួយៗ មករំពឹងពិចារណាឲ្យដឹងសេចក្ដីច្បាស់លាស់គ្រប់គុណនោះៗ ។

## សីលានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវសីលានុស្សតិកម្មដ្ឋាន គប្បីជម្រះសីលរបស់ខ្លួនឲ្យបរិសុទ្ធ ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកដល់សីលគុណរបស់ខ្លួន(១) ថា "**អហោ វត មេ សីលានិ អក្ខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុបសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ** ឱហ្ន៎! សីលទាំងឡាយរបស់អញ មិនមានដាច់ មិនមានធ្លុះ មិនមានពពាល មិនមានពព្រុស រួចផុតអំពីខ្ញុំរបស់តណ្ហាគួរឲ្យអ្នកប្រាជ្ញមានព្រះពុទ្ធជាដើមលោកពោលសរសើរ តណ្ហានិងទិដ្ឋិពាល់ត្រូវមិនបាន ប្រព្រឹត្តទៅព្រមដើម្បីឲ្យបាននូវសមាធិ" ។

## ចាគានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើន

---

១- បើគ្រហស្ថត្រូវឲ្យរឭកដល់សីលរបស់គ្រហស្ថ បើជាអ្នកបួសត្រូវឲ្យរឭកដល់សីលរបស់អ្នកបួស ។

នូវចាគានុស្សតិកម្មដ្ឋាន គប្បីឲ្យមានចិត្តយាងចុះក្នុងការបរិច្ចាគទានជាប្រក្រតី គប្បីចែករំលែកឲ្យទានអស់កាលជានិច្ច ពេលដែលប្រារព្ធនឹងចម្រើនត្រូវអធិដ្ឋានថា “តាំងអំពីពេលនេះជាដើម បើមានបដិគ្គាហក អ្នកទទួលយកនូវទាន តែអញមិនទាន់បានឲ្យទោះបី ១ ពំនូតដោយយ៉ាងហោចជាមុន អញនឹងមិនបរិភោគខ្លួនឯងឡើយ” កាលបើបានឲ្យទានដល់លោកអ្នកមានគុណវិសេសអង្គណា ១ ទោះបីតិចក្ដី ច្រើនក្ដី រួចហើយត្រូវចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកដល់ចាគគុណរបស់ខ្លួនថា “**លាភា វត មេ សុលទ្ធំ វត មេ យោហំ មច្ឆេរមលបរិយុដ្ឋិតាយ បជាយ វិគតមលមច្ឆេរេន ចេតសា វិហរាមិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ** អានិសង្ស ៥ ប្រការ(១)

---

១- អានិសង្សរបស់ទាយកអ្នកឲ្យទាន ៥ ប្រការគឺ អាយុវែង ១ សម្បុរល្អ ១ សេចក្ដីសុខ ១ កម្លាំងច្រើន ១ ប្រាជ្ញាច្រើន ១ ។ ន័យមួយទៀតថា បានជាទីស្រឡាញ់ពេញចិត្តនៃមហាជន ១ លោកជាសប្បុរសតែងគប់រក ១ មានកិត្តិសព្ទល្អ ១ បានឈ្មោះថាមិនប្រាសចាកធម៌របស់គ្រហស្ថ ១ ដល់ទម្លាយកាយទៅនឹងបានទៅកើតក្នុងសុគតិភព ១ ។

ដែលព្រះមានព្រះភាគទ្រង់សរសើរថា ជាលាភរបស់ទាយក អ្នកឲ្យនូវទាន អានិសង្សទាំងនោះជាលាភរបស់អញពិត ពុទ្ធ-សាសនាក្តី ភាពជាមនុស្សក្តី ដែលអញបានហើយនេះឈ្មោះថាបានដោយប្រពៃពិត ព្រោះថា ពួកសត្វទាំងអស់កំពុងមានមន្ទិលគឺសេចក្តីកំណាញ់គ្របសង្កត់ជាប់ជានិច្ច ហើយអញម្នាក់ឯង មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ បានលះបរិច្ចាគឲ្យទាន មានដៃលាងសម្អាតដើម្បីឲ្យនូវទេយ្យធម៌ដោយគោរពដៃឯងសព្វកាល ជាអ្នកត្រេកអរក្នុងការលះបង់គួរដល់កិរិយាសូម ពេញចិត្តក្នុងកិរិយាចែករំលែកឲ្យទាន ។

## ទេវតានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវទេវតានុស្សតិកម្មដ្ឋាន គប្បីតាំងខ្លួនឲ្យតម្កល់នៅក្នុងគុណមានសទ្ធាជាដើម ហើយចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ តម្កល់ស្មារតីរឭកដល់សទ្ធាទិគុណរបស់ទេវតាទុកជាបន្ទាល់ហើយរឭកដល់សទ្ធាទិគុណរបស់ខ្លួនថា “ទេវតា

ទាំងឡាយ ក្នុងជាន់ចាតុម្មហារាជ មានទេវតាទាំងឡាយ ក្នុងជាន់តាវត្តិង្ស ជាន់យាមា ជាន់តុសិត ជាន់និម្មានរតី ជាន់បរនិម្មិត-វសវត្តី មានទេវតាទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងពួកព្រហ្ម មានទេវតាទាំងឡាយ លើសអំពីនោះទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះប្រកបដោយ សទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា មានសភាពយ៉ាងណា ទើបច្យុតអំពីមនុស្សលោកនេះទៅកើតក្នុងទេវលោកនិងព្រហ្មលោកនោះៗ បាន សទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា មានសភាពយ៉ាងនោះរបស់អញក៏មានព្រម(១) ។

## មរណានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវមរណានុស្សតិកម្មដ្ឋាន គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយធ្វើទុកក្នុងចិត្តដោយឧបាយថា "**មរណំ ភវិស្សតិ ជីវិតិន្ទ្រិយំ ឧបច្ឆិជ្ជិស្សតិ** សេចក្ដីស្លាប់គង់តែនឹងមាន ជីវិតិន្ទ្រិយមុខជានឹងដាច់បង់ទៅ" ឬថា "**មរណំ មរណំ** សេចក្ដីស្លាប់ៗ" ដូច្នេះក៏បាន ។

---

១- ដែលតម្កល់ទុកនូវទេវតាទាំងឡាយជាបន្ទាល់ហើយរឭកដល់សទ្ធាទិគុណរបស់ខ្លួនយ៉ាងនេះ ដើម្បីធ្វើសទ្ធាទិគុណរបស់ខ្លួនឲ្យកាន់តែមាំឡើង ។

បើធ្វើទុកក្នុងចិត្តដោយឧបាយយ៉ាងនេះហើយ នីវរណធម៌ទាំង ៥ មិនទាន់ទ្រោមទៅ ស្មារតីមិនទាន់តាំងនៅ កម្មដ្ឋានក៏មិនទាន់ដល់នូវឧបចារៈ ត្រូវឱ្យរឭកដល់សេចក្ដីស្លាប់ដោយអាការ ៨ យ៉ាងតទៅទៀត ។

អាការទាំង ៨ យ៉ាងនោះដូចម្ដេច?

អាការទាំង ៨ យ៉ាងនោះដូច្នេះគឺៈ

១- **វធកបច្ចុប្បដ្ឋានតោ** ត្រូវរឭកថា "សេចក្ដីស្លាប់តាំងឡើងប្រាកដ ដូចជាសត្រូវងារដាវផ្គងដាក់លើក" ។

២- **សម្បត្តិវិបត្តិតោ** ត្រូវរឭកថា "ធម្មតាសម្បត្តិក្នុងលោកសុទ្ធតែកន្លងនូវវិបត្តិទៅពុំបាន" ។

៣- **ឧបសំហរណតោ** ត្រូវរឭកដល់សេចក្ដីស្លាប់របស់ខ្លួន ប្រៀបដោយសេចក្ដីស្លាប់របស់អ្នកដទៃ ។

៤- **កាយពហុសាធារណតោ** ត្រូវរឭកថា "កាយនេះទូទៅដល់អន្តរាយច្រើនប្រការ មានត្រកូលនៃសត្វដង្កូវ ៨០ ជាដើម" ។

៥- **អាយុទុព្វលតោ** ត្រូវរឭកថា "អាយុនេះមាន

កម្លាំងថយពន់ពេកព្រោះថា ជីវិតរបស់សត្វទាំងឡាយជាប់នៅដោយខ្យល់អស្សាសៈ -បស្សាសៈជាដើម” ។

៦- **អនិមិត្តតោ** ត្រូវរឭកថា “សេចក្ដីស្លាប់មិនមានកំណត់ ព្រោះថា ជីវិតជាដើមរបស់សត្វទាំងឡាយរកកំណត់មិនបាន(១)” ។

៧- **អទ្ធានបរិច្ឆេទតោ** ត្រូវរឭកថា “ជីវិតរបស់មនុស្សក្នុងកាលឥឡូវនេះ កំណត់យ៉ាងយូរបំផុតត្រឹមមួយរយឆ្នាំ(២) បើលើសក៏បន្តិចបន្តួច” ។

៨- **ខណបរិត្តតោ** ត្រូវរឭកថា “ជីវិតក្ខណៈរបស់សត្វទាំងឡាយ បើពោលតាមបរមត្ថតូចពេកណាស់ ប្រព្រឹត្តទៅបានតែត្រឹម ១ ខណៈចិត្តប៉ុណ្ណោះឯង” ។

បណ្ដាអាការទាំង ៨ យ៉ាងនេះ ត្រង់អាការទី ៣ ដែលថាត្រូវរឭកដល់សេចក្ដីស្លាប់របស់ខ្លួន ប្រៀបដោយសេចក្ដីស្លាប់របស់អ្នកដទៃនោះ ត្រូវប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គល ៧ ពួកគឺៈ

---

១- ធម៌ដែលកំណត់មិនបានក្នុងជីវលោក មាន ៥ យ៉ាងគឺ ជីវិត ១ ព្យាធិ ១ កាល ១ ទេហនិក្ខេបន ១ គតិ ១ ។ ២- កំណត់នេះតាមជំនាន់ដើម ។

១- **យសមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានយសបរិវារច្រើន មានស្ដេចមហាសម្មតរាជនិងស្ដេចមន្ធាតុជាដើម ។

២- **បុញ្ញមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានបុណ្យច្រើន មានជោតិយ(១)សេដ្ឋី និងជដិលសេដ្ឋីជាដើម ។

៣- **ថាមមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានកម្លាំងច្រើន មានស្ដេចវាសុទេពនិងស្ដេចពលទេពជាដើម ។

៤- **ឥទ្ធិមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានឫទ្ធិច្រើនដូចព្រះមោគ្គល្លានត្ថេរ ។

៥- **បញ្ញាមហត្តតោ** ប្រៀបដោយសេចក្ដីស្លាប់របស់បុគ្គលដែលមានប្រាជ្ញាច្រើន ដូចព្រះសារីបុត្តត្ថេរ ។

៦- **បច្ចេកពុទ្ធតោ** ប្រៀបដោយបរិនិព្វានរបស់ព្រះបច្ចេកពុទ្ធ ។

---

១- “ជោតិក” ដូច្នេះក៏ថា ។

៧- **សម្មាសម្ពុទ្ធោ** ប្រៀបដោយបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ ។

ត្រូវប្រៀបដូចម្ដេច សេចក្ដីស្លាប់របស់បុគ្គលទាំង ៧ ពួកនេះ?

ត្រូវប្រៀបថា "អម្បាលដូចបុគ្គលដែលថ្កើងថ្កានដល់ម្លោះ គង់កន្លងមិនផុតអំពីសេចក្ដីស្លាប់ បំណាង់បើអាត្មាអញជាបុគ្គលថោកថយដល់ម្លេះ ដូចម្ដេចនឹងកន្លងឲ្យផុតអំពីសេចក្ដីស្លាប់ទៅបាន" ។

កាលបើព្រះយោគី រឭកដល់សេចក្ដីស្លាប់ដោយអាការទាំង ៨ យ៉ាង អាការណាមួយហើយ ដោយអំណាចដែលធ្វើទុកក្នុងចិត្តរឿយៗ ចិត្តក៏សេពនូវភាវនាដោយច្រើន ស្មារតីក៏តម្កល់នៅ មានសេចក្ដីស្លាប់ជាអារម្មណ៍ នីវរណធម៌ក៏ទ្រាមទៅ អង្គឈានសោតក៏កើតប្រាកដឡើង តែក្នុងមរណានុស្សតិកម្មដ្ឋាននេះ មានអំណាចឲ្យសម្រេចបានតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចឲ្យសម្រេចដល់អប្បនាឈានបានឡើយ ។

# កាយគតាសតិ

ទ្វត្តឹសាការកម្មដ្ឋាន គឺកម្មដ្ឋានដែលត្រូវតម្កល់ស្មារតីចុះក្នុងអាការ ៣២ ដែលមាននៅក្នុងកាយ ដោយធ្វើទុកក្នុងចិត្តថាជាបដិកូលមុខគួរឲ្យខ្ពើម ហៅថា “កាយគតាសតិកម្មដ្ឋាន” ។

កាលបើព្រះយោគី មានប្រាថ្នាដើម្បីបម្រើនូវកាយគតាសតិកម្មដ្ឋាននេះ គប្បីរៀនយកនូវឧគ្គហកោសល្ល គឺវិធីដែលឆ្លាសក្នុងឧគ្គហ ៧ យ៉ាង និងមនសិការកោសល្ល គឺវិធីដែលឆ្លាសក្នុងមនសិការ ១០ យ៉ាង ក្នុងសំណាក់នៃអាចារ្យដែលជាកល្យាណមិត្តជាមុន ។

ឧគ្គហកោសល្ល ៧ យ៉ាងនោះអ្វីខ្លះ? -អធិប្បាយដូចម្ដេច?

ឧគ្គហកោសល្ល ៧ យ៉ាងនោះ គឺៈ

១- **វចសា** ឆ្លាសដោយវាចាដែលស្វាធ្យាយក្នុងអាការទាំង ៣២ ។

២- **មនសា** ឆ្លាសដោយចិត្តដែលកំណត់ស្វាធ្យាយតាមក្នុងអាការទាំង ៣២ ។

៣- **វណ្ណតោ** ឆ្លាសដោយកំណត់ពណ៌របស់អាការ នោះៗ ។

៤- **សណ្ឋានតោ** ឆ្លាសដោយកំណត់សណ្ឋានរបស់ អាការនោះៗ ។

៥- **ទិសតោ** ឆ្លាសដោយកំណត់ទិសដែលអាការ នោះៗតម្កល់នៅ ។

៦- **ឱកាសតោ** ឆ្លាសដោយកំណត់ឱកាស ដែល អាការនោះៗតម្កល់នៅ ។

៧- **បរិច្ឆេទតោ** ឆ្លាសដោយកំណត់ទីជុំវិញរបស់ អាការនោះៗ និងភាពដែលអាការនោះៗ មិនប្រឡំគ្នា ។

អធិប្បាយ ត្រង់ឧគ្គហកោសល្លទី ១ ត្រូវហាត់ស្វាធ្យាយ ដោយវាចាឱ្យស្ទាត់ក្នុងអាការទាំង ៣២ ។

ក៏អាការទាំង ៣២ នោះលោកបាត់ទុកជា ៦ ពួកគឺៈ

ពួកទី ១ ឈ្មោះ តចបញ្ចកៈ មានអាការ ៥ គឺ **កេសា** សក់ទាំងឡាយ **លោមា** រោមទាំងឡាយ **នខា** ក្រចកទាំងឡាយ **ទន្តា** ធ្មេញទាំងឡាយ **តចោ** ស្បែក

ពួកទី ២ ឈ្មោះវក្កបញ្ចកៈ មានអាការ ៥ គឺ **មំសំ** សាច់ **ន្ហារូ** សរសៃទាំងឡាយ **អដ្ឋី** ឆ្អឹងទាំងឡាយ **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង **វក្កំ** ទាប ។

ពួកទី ៣ ឈ្មោះបប្ផាសបញ្ចកៈ មានអាការ ៥ គឺ **ហទយំ** បេះដូង **យកនំ** ថ្លើម **កិលោមកំ** វាវ **បិហកំ** សន្ទះខ្យល់ **បប្ផាសំ** សួត ។

ពួកទី ៤ ឈ្មោះមត្ថលុង្គបញ្ចកៈ មានអាការ ៥ គឺ **អន្តំ** ពោះវៀនធំ **អន្តគុណំ** ពោះវៀនតូច **ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ **មត្ថលុង្គំ** ខួរក្នុងក្បាល ។

ពួកទី ៥ ឈ្មោះមេទឆក្កៈ មានអាការ ៦ គឺ **បិត្តំ** ប្រមាត់ **សេម្ហំ** ស្លេស្ម **បុព្វោ** ខ្ទុះ **លោហិតំ** ឈាម **សេទោ** ញើស **មេទោ** ខ្លាញ់ខាប់ ។

ពួកទី ៦ ឈ្មោះមុត្តឆក្កៈ មានអាការ ៦ គឺ **អស្សុ** ទឹកភ្នែក **វសា** ខ្លាញ់រាវ **ខេឡោ** ទឹកមាត់ **សិង្ឃាណិកា** ទឹកសម្បោរ **លសិកា** ទឹករំអិល **មុត្តំ** ទឹកមូត្រ ។

ត្រូវហាត់ស្វាធ្យាយក្នុងពួកទី ១ ជាអនុលោមបដិលោមឲ្យបានស្ទាត់ជាមុន សន្សឹមឆ្លងចូលទៅក្នុងពួកទី ២ លុះបានស្ទាត់ក្នុងពួកទី ២ ហើយ ត្រូវស្វាធ្យាយភ្ជាប់មកនឹងពួកទី ១ ខាងដើមវិញ ជាអនុលោមបដិលោមដូចគ្នា ត្រាតែបានស្ទាត់ ហើយសន្សឹមឆ្លងចូលទៅក្នុងពួកខាងចុងៗទៀតជាលំដាប់តទៅ ។

ត្រង់ឧគ្គហកោសល្លទី ២ ត្រូវហាត់ស្វាធ្យាយដោយចិត្តឲ្យដូចជាស្វាធ្យាយដោយវាចា គឺថា ត្រូវលើកចិត្តឡើងកំណត់នូវអាការនោះៗ តាមលំអានដែលស្វាធ្យាយដោយវាចា ព្រោះថាស្វាធ្យាយដោយវាចា ជាបច្ច័យដល់កិរិយាស្វាធ្យាយដោយចិត្ត ។

ត្រង់ទី ៣ ត្រូវរៀនកំណត់នូវពណ៌របស់អាការនោះៗឲ្យដឹងថា "អាការនេះមានពណ៌ដូច្នេះៗ" គ្រប់អាការទាំងអស់ ។

ត្រង់ទី ៤ ត្រូវរៀនកំណត់នូវសណ្ឋានទ្រង់ទ្រាយរបស់

អាការទាំងនោះឲ្យដឹងថា “អាការនេះមានសណ្ឋានបែបនេះៗ” គ្រប់អាការទាំងអស់ ។

ត្រង់ទី ៥ ត្រូវរៀនកំណត់ឲ្យដឹងថា អាការណាតម្កល់នៅក្នុងទិសណា ទិសខាងលើ ឬខាងក្រោម ព្រោះក្នុងសរីរប្បទេសនេះ លោកចាត់ជាទិសមាន ២ គឺទិសខាងលើតាំងអំពីផ្ចិតឡើងទៅ ទិសខាងក្រោមតាំងអំពីផ្ចិតចុះមក ។

ត្រង់ទី ៦ ត្រូវរៀនកំណត់ឲ្យដឹងថា អាការណាតម្កល់នៅក្នុងទីឱកាសបន្លោះត្រង់ណាៗ គ្រប់អាការទាំង ៣២ ។

ត្រង់ទី ៧ ត្រូវរៀនកំណត់ឲ្យដឹងទីបំផុតជុំវិញរបស់អាការនោះៗ អាការណាមានទីបំផុតត្រឹមណា ទល់គ្នានឹងអាការណា ហើយនឹងរៀនកំណត់ឲ្យដឹងថា អាការទាំងនោះដោយឡែកៗ អំពីគ្នា មិនមានប្រទាំគ្នាឡើយ(១) ។

មនសិការកោសល្ល វិធីដែលឆ្លាសក្នុងមនសិការ ១០ យ៉ាងនោះ ដូចម្តេច?

---

១- ត្រង់ឧគ្គហកោសល្លទី ៧ នេះ លោកចែកចេញជា ២ គឺ កំណត់ថា “កោដ្ឋាសនេះខាងលើត្រឹមនេះ ខាងក្រោមត្រឹមនេះ ជុំវិញត្រឹមនេះ” ហៅថា សភាគបរិច្ឆេទ ១ កំណត់ភាពដែលមិនច្រឡំគ្នាថា “សក់មិនមែនជារោមៗ មិនមែនជាសក់ជាដើម” ហៅជា វិសភាគបរិច្ឆេទ ១ ។

មនសិការកោសល្ល វិធីដែលឆ្លាសក្នុងមនសិការ ១០ យ៉ាងនោះគឺ

១- **អនុបុព្វតោ** ត្រូវធ្វើទុកក្នុងចិត្តតាមលំដាប់នៃកោដ្ឋាស(១) តាំងអំពីស្វាធ្យាយជាដំបូងរៀងទៅ មិនត្រូវធ្វើទុកក្នុងចិត្តផ្លោះៗ ដោយអន្លើៗ ឡើយ ។

២- **នាតិសីឃតោ** ត្រូវធ្វើទុកក្នុងចិត្ត មិនឲ្យរហ័សរួសរាន់ពេក ។

៣- **នាតិសណិកតោ** ត្រូវធ្វើទុកក្នុងចិត្ត មិនឲ្យយឺតយូរពេក ។

៤- **វិក្ខេបបដិពាហនតោ** កាលបើចិត្តលះបង់នូវកម្មដ្ឋាន ហើយរាទៅរកអារម្មណ៍ដទៃជាខាងក្រៅ ត្រូវធ្វើទុកក្នុងចិត្តទប់មិនឲ្យចិត្តរាថយទៅវិញបាន ។

៥- **បណ្ណត្តិសមតិក្កមនតោ** ត្រូវធ្វើទុកក្នុងចិត្តកន្លងនូវបញ្ញត្តិដែលលោកហៅថា "សក់ រោម" ជាដើម ហើយតាំងចិត្តទុកថាជាបដិកូលៗ ប៉ុណ្ណោះ ។

---

១- ពាក្យថា "កោដ្ឋាស" និងពាក្យថា "អាការ" ដូចគ្នា ។

៦- **អនុបុព្វមុញ្ចនតោ** ត្រូវធ្វើទុកក្នុងចិត្តរៀងតាមលំដាប់នៃកោដ្ឋាស កាលបើកោដ្ឋាសណាមិនប្រាកដឡើង ត្រូវលះបង់បេញហើយធ្វើទុកក្នុងចិត្តតែកោដ្ឋាសណាដែលប្រាកដឡើង ។

៧- **អប្បនាតោ** ត្រូវឲ្យដឹងកោដ្ឋាសដែលនាំមកនូវអប្បនា គឺត្រូវឲ្យដឹងថា "អាការទាំង ៣២ មានសក់ជាដើមសុទ្ធតែមានអំណាចនឹងញុំាងអប្បនាចិត្ត ឲ្យកើតឡើងបានទាំងអស់" ។

៨- **អធិចិត្តតោ** ត្រូវឲ្យដឹងអធិចិត្តសូត្រ ដែលព្រះមានព្រះភាគទ្រង់សម្ដែងថា "ត្រូវឲ្យធ្វើទុកក្នុងចិត្តសព្វៗកាល(១) នូវនិមិត្ត ៣ យ៉ាងគឺ សមាធិនិមិត្ត ១ បគ្គហនិមិត្ត ១ ឧបេក្ខានិមិត្ត ១" ។

៩- **សីតិភាវតោ** ត្រូវឲ្យដឹងនូវសីតិភាវសូត្រ ដែលព្រះមានព្រះភាគទ្រង់សម្ដែងថា "ភិក្ខុដែលប្រកបដោយ

---

១- ធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តតែម្យ៉ាង ចិត្តនឹងបែរទៅរកកោសជ្ជ ធ្វើទុកក្នុងចិត្តនូវបគ្គហនិមិត្ត គឺផ្គងព្យាយាមតែម្យ៉ាង ចិត្តនឹងបែរទៅរកឧទ្ធច្ច ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តតែម្យ៉ាង ចិត្តនឹងមិនតម្កល់នៅមាំ ។

ធម៌ ៦ យ៉ាង(១) គួរធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបាន” ។

១០- **សត្តពោជ្ឈង្គកោសល្លសុត្តតោ** ត្រូវឲ្យដឹងនូវសត្តពោជ្ឈង្គកោសល្លសូត្រ ដែលព្រះមានព្រះភាគទ្រង់សម្តែងថា “ត្រូវឲ្យបម្រើនូវពោជ្ឈង្គទាំង ៧ ពោជ្ឈង្គណាមួយក្នុងពេលដែលចិត្តកំពុងរួញរាជាដើម” ។

ព្រះយោគី កាលបើបានរៀនយកនូវឧគ្គហកោសល្ល ៧ យ៉ាង និងមនសិការកោសល្ល ១០ យ៉ាង ដូចពោលមកនេះ បានកំណត់ ពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ គ្រប់កោដ្ឋាសមានសក់ជាដើមរួចហើយ ត្រូវធ្វើទុកក្នុងចិត្តថាជាបដិកូលដោយស្ថាន ៥ យ៉ាង កុំឲ្យរហ័សពេកនិងយឺតយូរពេកជាដើម ។

បដិកូលដោយស្ថាន ៥ យ៉ាងនោះដូចម្តេច?

បដិកូលដោយស្ថាន ៥ យ៉ាងនោះគឺ

១- ធម៌ ៦ យ៉ាងនោះគឺ សង្កត់ចិត្តក្នុងសម័យដែលគួរ ១ ផ្គងចិត្តក្នុងសម័យដែលគួរ ១ បង្អើលចិត្តក្នុងសម័យដែលគួរ ១ ស្ងង់ចិត្តក្នុងសម័យដែលគួរ ១ មានចិត្តយាងចុះស៊ប់ក្នុងមគ្គនិងផល ១ ត្រេកអរចំពោះក្នុងព្រះនិព្វាន ។

១- **វណ្ណតោ** បដិកូលដោយពណ៌ ។

២- **សណ្ឋានតោ** បដិកូលដោយសណ្ឋាន ។

៣- **គន្ធតោ** បដិកូលដោយក្លិន ។

៤- **អាសយតោ** បដិកូលដោយទីអាស្រ័យនៅ ។

៥- **ឱកាសតោ** បដិកូលដោយឱកាសដែលប្រតិស្ឋាននៅ ។

កាលបើព្រះយោគី បានធ្វើទុកក្នុងចិត្តថាជាបដិកូលដោយស្ថានទាំង ៥ យ៉ាងនេះ ដរាបដល់កោដ្ឋាស ដែលមាននៅក្នុងកាយទាំងប៉ុន្មាន តាំងឡើងប្រាកដស្មើគ្នា មិនមុនមិនក្រោយ គ្រាន់តែធ្វើមនសិការជាអនុលោមថា "**កេសា**" ប៉ុណ្ណោះ មនសិការនោះក៏រត់ទៅទល់ដល់ "**មុត្តំ**" ជាទីបំផុត ធ្វើមនសិការជាបដិលោមថា "**មុត្តំ**" ប៉ុណ្ណោះ មនសិការនោះក៏រត់ត្រឡប់មកទល់ដល់ "**កេសា**" ជាខាងដើមវិញ សូម្បីធ្វើមនសិការក្នុងកាយរបស់បុគ្គលដទៃ ជាខាងក្រៅក៏ប្រាកដឡើងដូចគ្នា បើមនុស្សនិងសត្វតិរច្ឆានជាដើម ដើរមកចំពោះមុខក៏លះបង់នូវអាការជាសត្វ ប្រាកដឡើងជាគំនរនៃកោដ្ឋាស

ទាំងអស់ ទឹកនិងភោជនដែលសត្វទាំងនោះផឹក បរិភោគចូលទៅ ក៏ប្រាកដឋហាក់ដូចជាដាក់ចុះទៅក្នុងគំនរនៃកោដ្ឋាសទាំង ៣២ ។

បើព្រះយោគីធ្វើទុកក្នុងចិត្តដោយបដិកូលឲ្យរឿយៗ តាមមនសិការកោសល្លវិធីទាំង ១០ យ៉ាង លំដាប់មក អប្បនាចិត្តក៏នឹងកើតឡើង ។

ក៏ក្នុងអនុស្សតិកម្មដ្ឋានទាំង ១០ ឧគ្គហនិមិត្តនិងបដិ-ភាគនិមិត្ត មិនបានកើតគ្រប់ទាំងអស់ឡើយ គឺកើតតែក្នុងកាយគតាសតិកម្មដ្ឋាននេះ និងអានាបានស្សតិកម្មដ្ឋានប៉ុណ្ណោះឯង ។

តែឧគ្គហនិមិត្តក្នុងកាយគតាសតិកម្មដ្ឋាននេះ ឃើញអាការទាំង ៣២ តាំងឡើងប្រាកដដោយ ពណ៌ សណ្ឋានទិស ឱកាស និង បរិច្ឆេទ ឯបដិភាគនិមិត្ត ប្រាកដឡើងដោយបដិកូលគ្រប់អាការទាំងអស់ ។

បើព្រះយោគី សេពនូវបដិភាគនិមិត្តនោះដោយច្រើនបម្រើនឲ្យរឿយៗទៅ អប្បនាចិត្តក៏នឹងកើតឡើង តែកើតបាន

តែត្រឹមបឋមជ្ឈានប៉ុណ្ណោះ ដូចក្នុងអសុភកម្មដ្ឋានដែរ ។

## អានាបានស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវអានាបានស្សតិកម្មដ្ឋាន គប្បីធ្វើនូវបុព្វកិច្ចមានជម្រះសីលរបស់ខ្លួនឲ្យបរិសុទ្ធជាដើម ហើយរៀនយកនូវកម្មដ្ឋានឲ្យប្រកបដោយសន្ធិ ៥ យ៉ាង ក្នុងសំណាក់នៃអាចារ្យដែលជាកល្យាណមិត្តជាមុន រួចហើយសឹ្សមចម្រើន ។

សន្ធិ ៥ យ៉ាងនោះដូចម្ដេច?

សន្ធិ ៥ យ៉ាងនោះដូច្នេះគឺ

១- **ឧគ្គហោ** ត្រូវរៀនយកនូវគម្ពីរដែលសម្ដែងអំពីកម្មដ្ឋាននេះឲ្យបានបេះដឹងសេចក្ដីអធិប្បាយសព្វគ្រប់ ។

២- **បរិបុច្ឆា** ត្រូវសាកសួរអាចារ្យឲ្យច្បាស់លាស់ត្រង់សេចក្ដីណាដែលនៅមានសង្ស័យ ។

៣- **ឧបដ្ឋានំ** ត្រូវតម្កល់ទុកនូវនិមិត្តដែលចម្រើនបានកើតឡើងហើយ ។

៤- **អប្បនា** ត្រូវរៀនឲ្យដឹងថា “ដែលនឹងដល់នូវ

អប្បនាឈានក្នុងកម្មដ្ឋាននេះនោះយ៉ាងនេះៗ” ។

៥- **លក្ខណំ** ត្រូវរៀនឲ្យដឹងនូវលក្ខណៈនៃកម្មដ្ឋាននេះថា “ដែលនឹងអាចបម្រើនបានដល់នូវអប្បនានោះ ដោយអំណាចនៃគណនាវិធី អនុពន្ធនាវិធី និងផុសនាវិធី” ។

លុះព្រះយោគីបានរៀនយកនូវកម្មដ្ឋាន ប្រកបដោយសន្ធិទាំង ៥ នេះស្ទាត់ហើយ ត្រូវប្ញូលទៅកាន់សេនាសនៈដ៏សមគួរអង្គុយនៅឲ្យស្រួល រឭកដល់គុណព្រះរតនត្រ័យញុាំងចិត្តឲ្យជ្រះថ្លាជាមុន ហើយសន្សំមធ្វើទុកក្នុងចិត្តតាមលំអានដែលរៀនមកអំពីសំណាក់នៃអាចារ្យកុំឲ្យភ្លេចត្រង់បទណានីមួយឡើយ ។

មនសិការវិធី គឺវិធីដែលត្រូវធ្វើទុកក្នុងចិត្តនូវអានាបានស្សតិកម្មដ្ឋាននេះមាន ៨ យ៉ាង ។

មនសិការវិធីទាំង ៨ យ៉ាងនោះអ្វីខ្លះ? -អធិប្បាយដូចម្ដេច?

មនសិការវិធីទាំង ៨ យ៉ាងនោះគឺ

១- **គណនា** កិរិយារាប់នូវខ្យល់អស្សាសៈ បស្សាសៈ(១)

១-ខ្យល់ដង្ហើមចេញ ចូល ។

២- **អនុពន្ធនា** កិរិយាចងក្រៀកស្មារតីបញ្ជូនទៅតាមខ្យល់អស្សាសៈ បស្សាសៈ ។

៣- **ផុសនា** ទីដែលខ្យល់អស្សាសៈ បស្សាសៈពាល់ត្រូវ ។

៤- **ឋបនា** កិរិយាតម្កល់ចិត្តទុកក្នុងអារម្មណ៍ដោយប្រពៃ បានដល់អប្បនា ។

៥- **សល្លក្ខណា** កិរិយាកំណត់នូវអនិច្ចាទិលក្ខណៈបានដល់វិបស្សនាបញ្ញា ។

៦- **វិវដ្ដនា** កិរិយាវិលត្រឡប់ចាកបវត្តធម៌និងនិមិត្ត-ធម៌ បានដល់មគ្គ ៤ ។

៧- **បារិសុទ្ធិ** ភាវៈស្អាតដោយជុំវិញ ចាកសង្កិលេស-ធម៌ បានដល់ផល ៤ ។

៨- **បដិបស្សនា** ប្រាជ្ញាដែលពិចារណាឃើញនូវលក្ខ-ណៈតាមលំដាប់នៃវិបស្សនា បានដល់បច្ចវេក្ខណញាណ ១៩[១]

---

១-បច្ចវេក្ខណញ្ញាណ ១៩ លោករាប់យកមគ្គ ៤ ផល ៤ និព្វាន ១ និងកិលេសដែលសល់នៅហើយលះបង់បាន ១០ (សំដៅយកញ្ញាណដែលគប្បីពិចារណាដឹងក្នុងធម៌ទាំង ១៩ នោះ) ។

ក្នុងមនសិការវិធីទាំង ៨ នេះ ពីត្រឹមទី ១ ដល់ទី ៤ សម្រាប់ព្រះយោគីដែលជាអាទិកម្មិកៈ ពីត្រឹមទី ៥ ដល់ទី ៨ សម្រាប់ព្រះយោគីដែលបានដល់ចតុក្កជ្ឈាន និងបញ្ចកជ្ឈានហើយ ។

ត្រង់គណនាវិធីទី ១ អធិប្បាយថា ព្រះយោគីដែលជាអាទិកម្មិកៈ កាលដែលធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននេះ គប្បីធ្វើទុកក្នុងចិត្តដោយកិរិយារាប់ជាមុន ។

ក៏វិធីដែលរាប់នោះ មិនត្រូវរាប់ឲ្យតិចជាង ៥ ព្រោះទីឱកាសបង្អៀតចិត្តនិងញាប់ញ័រមិនត្រូវរាប់ ឲ្យច្រើនលើសជាង ១០ ព្រោះចិត្តនឹងអាស្រ័យនៅតែក្នុងវិធីរាប់ប៉ុណ្ណោះ មិនត្រូវបង្អង់ត្រង់ចន្លោះៗ ព្រោះចិត្តប្រាប់ ត្រូវរាប់ដើមដម្បូងរង្វើលៗ គូបខ្យល់ចេញនិងខ្យល់ចូលរាប់ទៅជាគូៗ ខ្យល់ណាដែលប្រាកដនៅត្រង់ក្តោងប្រមុះ ត្រូវចាប់រាប់ខ្យល់នោះមុនគេថា "មួយៗ ពីរៗ ។ ល ។ ប្រាំបួនៗ ដប់ៗ" ដរាបដល់ខ្យល់អស្សាសៈ បស្សាសៈ ប្រាកដឡើង ។

លុះដល់ខ្យល់អស្សាសៈ បស្សាសៈ ប្រព្រឹត្តទៅកាន់តែរហ័សឡើង ត្រូវរាប់ក៏ឲ្យកាន់តែញាប់ឡើងទៀត ហើយ

មិនត្រូវចាប់យកខ្យល់ ដែលចេញមកអំពីខាងក្នុងនិងចូលទៅអំពីខាងក្រៅមករាប់ឡើយ ត្រូវចាប់យកតែខ្យល់ដែលប៉ះត្រូវដល់ទ្វារប្រមុះប៉ុណ្ណោះមករាប់ថា "មួយ ពីរ បី បួន ប្រាំ ។ មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ។ មួយ ពីរ ។ ល ។ ប្រាំមួយ ប្រាំពីរ ។ មួយ ពីរ ។ ល ។ ប្រាំពីរ ប្រាំបី ។ មួយ ពីរ ។ ល ។ ប្រាំបី ប្រាំបួន ។ មួយ ពីរ ។ ល ។ ប្រាំបួន ដប់" ។

កាលបើកម្មដ្ឋាន ជាប់នៅដោយកិរិយារាប់យ៉ាងនេះហើយ ចិត្តក៏នឹងតម្កល់នៅមាំ មានអារម្មណ៍តែមួយយ៉ាងឯក មិនតែប៉ុណ្ណោះ ដោយអំណាចដែលតម្កល់ទុកនូវស្មារតីបម្រើនត្រង់ឱកាសដែលខ្យល់អស្សាសៈ បស្សាសៈ ប៉ះពាល់ត្រូវយ៉ាងនេះភាវនាក៏នឹងបានសម្រេចមិនខាន ។

ត្រង់អនុពន្ធនាវិធីទី ២ អធិប្បាយថា : កាលបើព្រះយោគីធ្វើទុកក្នុងចិត្តដោយកិរិយារាប់រួចហើយ ត្រូវបញ្ឈប់ ហើយបញ្ជូនស្មារតីទៅតាមខ្យល់ អស្សាសៈ បស្សាសៈ ធ្វើទុកក្នុងចិត្តកុំឲ្យមានចន្លោះ តែមិនត្រូវធ្វើទុកក្នុងចិត្តដោយអំណាចខាងដើមនិងពាក់កណ្តាលនិងខាងចុងថា "ខ្យល់ដង្ហើម

បេញ ផ្ចិតជាខាងដើម បេះដូងជាកណ្តាល ចុងច្រមុះជាខាងចុង ខ្យល់ដង្ហើមចូល ចុងច្រមុះជាខាងដើម បេះដូងជាកណ្តាល ផ្ចិតជាខាងចុង" ដូច្នេះឡើយ ព្រោះជាហេតុនាំឲ្យចិត្តរាយមាយ ។

ត្រង់ផុសនាវិធីទី ៣ មិនមែនជាផ្សេងគ្នាបាកគណនាវិធី និងអនុពន្ធនាវិធីនោះឡើយ គឺសំដៅយកត្រង់បញ្ជូនស្មារតីទៅតាមវិធីនៃកិរិយារាប់ហើយស្ទង់ ពិចារណាធ្វើទុកក្នុងចិត្តមិនឲ្យមានចន្លោះ ត្រង់ឱកាសដែលខ្យល់អស្សាសៈ បស្សាសៈ ពាល់ត្រូវហើយនោះប៉ុណ្ណោះឯង ។

ត្រង់ឋបនាវិធីទី ៤ អធិប្បាយថា : កាលដែលព្រះយោគីរាប់នូវខ្យល់អស្សាសៈ បស្សាសៈ ត្រង់កន្លែងដែលប៉ះពាល់ត្រូវទ្វារហើយធ្វើទុកក្នុងចិត្តនូវខ្យល់នោះៗដោយរាប់ផង ដោយកំណត់តែត្រង់ទីដែលខ្យល់មកប៉ះពាល់ត្រូវផង រួចហើយបង្អង់រាប់ក្នុងទីនោះ តាំងបញ្ជូនស្មារតីទៅកាន់ខ្យល់អស្សាសៈ បស្សាសៈទាំងនោះ លើនិមិត្តណាប្រាកដឡើងគួរល្មមញុំាងអប្បនាចិត្តឲ្យកើតឡើងបាន ក៏តម្កល់ចិត្តទុកតែក្នុងនិមិត្តនោះប៉ុណ្ណោះ ។

ត្រង់ទី ៥-៦-៧-៨ អធិប្បាយថា : ព្រះយោគីដែលបានដល់ចតុក្កជ្ឈាននិងបញ្ចកជ្ឈានហើយ បើមានប្រាថ្នាដើម្បីបម្រើននូវកម្មដ្ឋាននេះដោយសល្លក្ខណាវិធី គឺវិធីនៃវិបស្សនាញាណនិងវិវដ្ដនាវិធីគឺវិធីនៃអរិយមគ្គទាំង ៤ ឲ្យបានដល់នូវបារិសុទ្ធិ គឺព្រះអរិយផលទាំង ៤ ហើយនិងតម្កល់នៅក្នុងភាវៈជាព្រះអរហន្ត ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ អ្នកដល់នូវទីបំផុតនៃបដិបស្សនា គឺបច្ចវេក្ខណញ្ញាណមានប្រភេទ ១៩ យ៉ាងនោះ ក៏គប្បីធ្វើឈាននោះឲ្យស្ទាត់ដោយវសីទាំង ៥ ហើយកំណត់នូវនាមនិងរូបបម្រើននូវវិបស្សនាតទៅទៀត នឹងបានសម្រេចដូចសេចក្ដីប្រាថ្នា ។

ក៏ក្នុងអានាបានស្សតិកម្មដ្ឋាននេះ បើព្រះយោគីជាអាទិកម្មិកៈ តម្កល់ចិត្តទុកក្នុងឱកាសដែលខ្យល់អស្សាសៈបស្សាសៈ ពាល់ត្រូវជាប្រក្រតី ញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅរឿយៗ ដោយឧបាយនៃប្រាជ្ញា តាមលំអាននៃមនសិការវិធីទាំង ៤ ខាងដើម មិនយូរប៉ុន្មានឡើយ ខ្យល់អស្សាសៈ

បស្សាសៈទាំងឡាយនោះក៏នឹងប្រាកដឡើង ហើយឧគ្គហ-និមិត្តនិងបដិភាគនិមិត្ត ក៏នឹងកើតឡើងផង តែជានិមិត្តទាំង ២ យ៉ាងនោះ ក្នុងកម្មដ្ឋាននេះ លោកសម្តែងគួបបូលជាមួយគ្នា ពុំបានញែកឲ្យឃើញដោយឡែកៗ អំពីគ្នាឡើយ ។

ព្រះយោគីអង្គខ្លះ ដែលញុំាងសុខសម្មស្សឲ្យកើតឡើងបាន និមិត្តតាំងឡើងប្រាកដដូចប៉ុយគក៏មាន ដូចប៉ុយកប្បាសក៏មាន ដូចទវខ្យល់ក៏មាន(១) ដូចដួងផ្កាយក៏មាន ដូចដួងកែវមណីក៏មាន ដូចដួងកែវមុក្តាក៏មាន បើព្រះយោគីអង្គខ្លះដែលញុំាងសម្មស្សឲ្យកើតឡើងរឹង និមិត្តតាំងឡើងប្រាកដដូចគ្រាប់កប្បាសក៏មាន ដូចដក់ធ្វើដោយឈើខ្លឹមក៏មាន ដូចសរសៃសង្វារកែវក៏មាន ដូចបង្គោមផ្កាក៏មាន ដូចសំណុំផ្សែងក៏មាន ដូចសរសៃពីងពាងក៏មាន ដូចផ្ទៃពលាហកក៏មាន ដូចផ្កាឈូកក៏មាន ដូចកង់នៃរថក៏មាន ដូចមណ្ឌលនៃព្រះបន្ទ្រក៏មាន ដូចមណ្ឌលនៃព្រះអាទិត្យក៏មាន(២) ។

---

១- នេះជាពាក្យ កេចិ អាចារ្យ ។ ២- នេះជាពាក្យវិនិច្ឆ័យក្នុងអដ្ឋកថា ។

ចាប់ដើមអំពីនិមិត្តកើតឡើងយ៉ាងនេះ នីវរណធម៌និងកិលេសរបស់ព្រះយោគីអង្គនោះក៏ទ្រោមស្ងប់ទៅ សតិក៏ប្រុងឡើង ហើយចិត្តសោតក៏តម្កល់នៅមាំដោយឧបចារសមាធិ ។

បើព្រះយោគីរក្សាទុកនូវនិមិត្តនោះ ឲ្យល្អដោយរក្ខណាវិធី ធ្វើទុកក្នុងចិត្តឲ្យរឿយៗ ដោយអប្បនាកោសល្លវិធី ហើយប្រកបព្យាយាមឲ្យស្មើ កុំតែធ្វើទុកក្នុងចិត្តដោយពណ៌ និងពិចារណាដោយលក្ខណៈ ក៏នឹងអាចញ៉ាំងអប្បនាឈានឲ្យកើតឡើងបានទាំងចតុក្កន័យនឹងបញ្ចកន័យ ដូចក្នុងកសិណទាំង ១០ ដែរ ។

## ឧបសមានុស្សតិ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវឧបសមានុស្សតិកម្មដ្ឋាន គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយរឭកដល់គុណរបស់ព្រះនិព្វានដែលជាគ្រឿងរម្ងាប់បង់នូវសំសារទុក្ខទាំងពួង តាមលំអានព្រះពុទ្ធដីកាដូច្នេះជាដើមថា **“យាវតា ភិក្ខវេ ធម្មា សង្ខតា វា អសង្ខតា វា វិរាគោ តេសំ ធម្មានំ អគ្គមក្ខាយតំ** ម្នាលភិក្ខុ

ទាំងឡាយ ធម៌ទាំងប៉ុន្មាន ទោះជាសង្ខតក្តី ជាអសង្ខតក្តី មានតែវិរាគធម៌គឺព្រះនិព្វានឯង ប្រាកដជាប្រសើរដោយវិសេស ជាងធម៌ទាំងឡាយនោះ **យទិទំ មទនិម្មទនោ បិបាសវិនយោ អាលយសមុគ្ឃាតោ វដ្ដុបច្ឆេទោ តណ្ហក្ខយោ វិរាគោ និរោធោ និព្វានំ** វិរាគធម៌នេះ ជាគ្រឿងញាំញីនូវសេចក្ដីស្រវឹង ជាគ្រឿងបណ្ដេញបង់នូវសេចក្ដីស្រេកឃ្លានក្នុងកាម ជាគ្រឿងដកឡើងនូវសេចក្ដីអាល័យក្នុងកាមគុណ ជាគ្រឿងកាត់បង់នូវតេភូមិកវដ្ដជាគ្រឿងអស់ទៅនៃតណ្ហា ជាគ្រឿងលាកបាកតណ្ហា ជាទីរលត់ទៅនៃតណ្ហា បេញរូបស្រឡះហើយចាកព្រៃស្បាតគឺតណ្ហា” ។

ឧបសមានុស្សតិកម្មដ្ឋាននេះ មានអំណាចឲ្យសម្រេចបានតែត្រឹមឧបចារជ្ឈានដូចក្នុងពុទ្ធានុស្សតិជាដើមដែរ ។

**អនុស្សតិកម្មដ្ឋាន ១០ ចប់**

## *ព្រហ្មវិហារ ៤*

# មេត្តាព្រហ្មវិហារ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវមេត្តាព្រហ្មវិហារ គប្បីចូលទៅកាន់ទីដែលស្ងាត់បាកអារម្មណ៍ផ្សេងៗ អង្គុយនៅឲ្យស្រួល ពិចារណានូវទោសក្នុងសេចក្តីប្រទុស្ត (ទោស) និងអានិសង្សក្នុងសេចក្តីអំណត់ (ខន្តី) ជាមុន ។

ទោសក្នុងសេចក្តីប្រទុស្តដូចម្តេចខ្លះ? អានិសង្សក្នុងសេចក្តីអំណត់ដូចម្តេចខ្លះ? ហេតុអ្វីទើបត្រូវពិចារណាជាមុន?

ទោសក្នុងសេចក្តីប្រទុស្តនោះលោកពោលទុកថា "បើបុគ្គលណាដែលទោសគ្របសង្កត់ហើយ បុគ្គលនោះអាចហ៊ានសម្លាប់សត្វជាដើមបាន" ឯអានិសង្សក្នុងសេចក្តីអំណត់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដូច្នេះជាដើមថា "ខន្តីគឺ សេចក្តីអំណត់បាត់ជាតបធម៌មួយយ៉ាងឧត្តម"[១] បានជា

---

១- សេចក្តីនេះសង្ខេបពេក លោកអ្នកត្រូវការ គប្បីស្វែងរកមើលក្នុងសេចក្តីដែលពិស្តារផងចុះ ។

ត្រូវពិចារណាជាមុន ព្រោះថាកម្មដ្ឋាននេះ ព្រះយោគីត្រូវចម្រើនដើម្បីនឹងលះបង់នូវទោស ហើយនឹងបាននូវខុន្តិប៉ុណ្ណោះ បើមិនបានពិចារណាឲ្យឃើញជាមុនហើយ ក៏មិនអាចដើម្បីនឹងលះបង់នូវទោសដែលមិនឃើញ ហើយបាននូវអានិសង្ស ដែលមិនដឹងនោះឡើយ ។

កាលដែលព្រះយោគីប្រារព្ធនឹងចម្រើនមុនដំបូង កុំអាលចម្រើនក្នុងបុគ្គលដែលជាទោស ៤ ពួកគឺ បុគ្គលដែលមិនជាទីស្រឡាញ់ ១ សំឡាញ់ដែលជាទីស្រឡាញ់ក្រៃពេក ១ បុគ្គលដែលជាកណ្តាល ១ បុគ្គលដែលមានពៀរដល់គ្នា ១ មិនតែប៉ុណ្ណោះសោត សូម្បីបុគ្គលដែលមិនមែនជាខេត្ត ២ ពួក គឺ បុគ្គលដែលមានភេទខុស(១)គ្នា ១ បុគ្គលដែលធ្វើមរណៈកាលកន្លងហើយ ១ ក៏មិនគប្បីចម្រើនមេត្តាព្រហ្មវិហារទៅរកជាដំបូងឡើយ ។

---

១- បុគ្គលដែលមានភេទខុសគ្នានោះ សំដៅយកភេទបុរសនិងស្ត្រី គឺបើព្រះយោគីជាបុរសមិនត្រូវចម្រើនមេត្តាព្រហ្មវិហារទៅរកស្ត្រីដោយចំៗ បើព្រះយោគីជាស្ត្រីវិញក៏មិនត្រូវចម្រើនទៅរកបុរសដោយចំៗ ឡើយ ។

បុគ្គលទាំងនោះ មានទោសដល់មេត្តាព្រហ្មវិហារដូចម្ដេច ទើបលោកហាមមិនឲ្យបម្រើនជាដំបូង?

បុគ្គលទាំងនោះមានទោសដូច្នេះគឺ បុគ្គលដែលមិនជាទីស្រឡាញ់ លំបាកនឹងទាញមកតម្កល់ទុកឲ្យជាទីស្រឡាញ់ សំឡាញ់ដែលជាទីស្រឡាញ់ក្រៃពេក លំបាកនឹងទាញមកតម្កល់ទុកឲ្យជាកណ្ដាល បុគ្គលដែលជាកណ្ដាល លំបាកនឹងទាញមកតម្កល់ទុកឲ្យជាទីគោរព និងជាទីស្រឡាញ់ បុគ្គលដែលមានពៀរដល់គ្នា បើបម្រើនមេត្តាព្រហ្មវិហារទៅរកនឹងកើតសេចក្ដីក្រោធ បុគ្គលដែលមានភេទខុសគ្នានឹងកើតសេចក្ដីតម្រេក បុគ្គលដែលធ្វើមរណកាលកន្លងហើយ នឹងមិនដល់នូវអប្បនានិងឧបចារៈ ហេតុនោះ ទើបលោកហាមមិនឲ្យបម្រើនមេត្តាទៅរកជាដំបូង ។

បើដូច្នោះត្រូវឲ្យបម្រើនបំពោះបុគ្គលដូចម្ដេចជាមុន?

ត្រូវឲ្យបម្រើនបំពោះខ្លួនព្រះយោគីជាមុន គឺត្រូវបម្រើនឲ្យរឿយៗ ថា “**អហំ សុខិតោ ហោមិ និទ្ទុក្ខោ** សូមឲ្យអញបានដល់នូវសេចក្ដីសុខ កុំមានទុក្ខឡើយ” ឬនឹងបម្រើនថា

**“អវេរោ អព្យាបជ្ឈោ អនីឃោ សុខី អត្តានំ បរិហរាមិ** សូមឲ្យអញជាបុគ្គលគ្មានពៀរ គ្មានទុក្ខ គ្មានទោស ឲ្យមានតែសេចក្តីសុខ សូមរក្សាខ្លួនឲ្យបានយ៉ាងនេះជាដរាបទៅ” ដូច្នេះក៏បាន ។

បើព្រះយោគី បម្រើនូវមេត្តាព្រហ្មវិហារបំពោះខ្លួនយ៉ាងនេះជារឿយៗ ហើយ អប្បនាចិត្តនៅមិនទាន់កើតឡើង ក៏គប្បីតម្កល់ទុកនូវខ្លួនឲ្យជាបន្ទាល់ ហើយទាញយកសត្វទាំងឡាយដទៃមកប្រៀបថា “អញប្រាថ្នានូវសេចក្តីសុខ ខ្ពើមរអើមទុក្ខ ប្រាថ្នាចង់រស់ មិនចង់ស្លាប់យ៉ាងណា សត្វទាំងឡាយដទៃ ក៏ប្រាថ្នានូវសេចក្តីសុខ ខ្ពើមរអើមទុក្ខ ប្រាថ្នាចង់រស់ មិនចង់ស្លាប់យ៉ាងនោះដែរ” រួចហើយត្រូវបម្រើនមេត្តាបំពោះបុគ្គល ដែលគួរគោរពមានអាចារ្យ និងឧបជ្ឈាយ៍ជាដើមឲ្យរឿយៗ ថា **“ឯស សប្បុរិសោ សុខិតោ ហោតុ និទ្ទុក្ខោ** សូមឲ្យលោកជាសប្បុរសនុ៎ះ បានដល់នូវសេចក្តីសុខ កុំបីមានទុក្ខឡើយ” ។

ដោយអំណាច ដែលព្រះយោគីបម្រើននូវមេត្តាព្រហ្មវិហារបំពោះបុគ្គលមានសភាពយ៉ាងនេះ អប្បនាចិត្តក៏នឹងកើតឡើងដោយពិត តែបើនៅមិនទាន់ដល់នូវសេចក្ដីត្រេកអរដោយព្យាយាមប៉ុណ្ណោះ គប្បីបម្រើនបំពោះបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាកណ្ដាល បុគ្គលដែលមានពៀរដល់គ្នាតទៅទៀត បម្រើនក្នុងកោដ្ឋាសនីមួយៗ ធ្វើចិត្តឲ្យគួរដល់កម្ម ទាញយកបុគ្គលដែលជាទីស្រឡាញ់ មកដាក់ត្រង់កន្លែងបុគ្គលដែលជាកណ្ដាលៗ មកដាក់ត្រង់កន្លែងបុគ្គលដែលមានពៀរដល់គ្នាបន្ទោបង់នូវបដិឃក្នុងបុគ្គល ដែលមានពៀរដល់គ្នា លំដាប់មកទៀត គប្បីបម្រើនឲ្យរឿយៗ ញុំាំងចិត្តឲ្យប្រព្រឹត្តទៅស្មើជាសីមសម្ភេទ(១) ក្នុងជនទាំង ៤ ពួកគឺ ខ្លួនព្រះយោគី ១ បុគ្គលដែលជាទីស្រឡាញ់ ១ បុគ្គលដែលជាកណ្ដាល ១ បុគ្គលដែលមានពៀរដល់គ្នា ១ មិនឲ្យមានធ្ងន់មានស្រាល

---

១- សីមា (ដែន) ក្នុងទីនេះមាន ៤ គឺ បុគ្គលជាទីស្រឡាញ់ដែន ១ បុគ្គលជាកណ្ដាលដែន ១ បុគ្គលដែលមានពៀរដែន ១ ខ្លួនព្រះយោគីដែន ១ ត្រង់ដែលផ្សាយមេត្តាចិត្តទៅស្មើក្នុងដែនទាំង ៤ ហៅថា “សីមសម្ភេទ” ។

ជាងគ្នា សីមសម្ភេទនេះហើយ ដែលលោកហៅថានិមិត្តក្នុងកម្មដ្ឋាននេះ ព្រោះថាក្នុងព្រហ្មវិហារទាំង ៤ មិនមានឧគ្គហនិមិត្តនិងបដិភាគនិមិត្តដូចក្នុងកសិណទាំង ១០ ជាដើមឡើយ មានតែសមថនិមិត្ត ដែលប្រព្រឹត្តទៅដោយអំណាចនៃសីមសម្ភេទប៉ុណ្ណោះ ។

បើព្រះយោគីសេពនូវនិមិត្តនោះដោយច្រើន បម្រើនឲ្យរឿយៗឡើងទៅ ក៏នឹងបានដល់នូវអប្បនាឈានដោយងាយមិនមានលំបាកឡើយ តែក្នុងកម្មដ្ឋាននេះឲ្យសម្រេចបានតែត្រឹមតតិយជ្ឈានក្នុងចតុក្កន័យ ឬចតុត្ថជ្ឈានក្នុងបញ្ចកន័យប៉ុណ្ណោះ តែបើព្រះយោគីផ្សាយមេត្តាព្រហ្មវិហារ ដោយអំណាចនៃឈាននីមួយៗ បំពោះសត្វដែលនៅក្នុងទិស ១ ទិស ២ ដរាបដល់គ្រប់ទិសទាំង ១០ ជាអនោធិសោផរណា(១) ដោយអាការ ៥(២)

១- ផ្សាយមេត្តាព្រហ្មវិហារមិនមានចំពោះពួកសត្វថា “សត្វទាំងអស់ ប្រាណទាំងអស់ ភូតទាំងអស់ បុគ្គលទាំងអស់ ដែលរាប់ថាមានអត្តភាពទាំងអស់ ចូរកុំឲ្យមានពៀរ កុំឲ្យមានទុក្ខ កុំឲ្យមានទោស ចូរឲ្យបានសេចក្ដីសុខ ចូររក្សាខ្លួនឲ្យបានយ៉ាងនេះដរាបទៅ” ។

២- អាការ ៥ នោះគឺ សត្វទាំងអស់ ១ ប្រាណទាំងអស់ ១ ភូតទាំងអស់ ១ បុគ្គលទាំងអស់ ១ ដែលរាប់ថាមានអត្តភាពទាំងអស់ ១ ។

ជាឱធិសោធរណា(១) ដោយអាការ ៧(២) ជាទិសាធរណាដោយអាការ ១០(៣) ក៏នឹងបាននូវអានិសង្ស ១១ យ៉ាង មានដេកនៅជាសុខជាដើម មានទៅកើតនៅក្នុងស្ថានព្រហ្មលោកជាទីបំផុត ។

## ករុណាព្រហ្មវិហារ

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវករុណាព្រហ្មវិហារ គប្បីចូលទៅកាន់ទីដែលស្ងាត់បាកអារម្មណ៍ផ្សេងៗ ពិចារណានូវទោសក្នុងសេចក្ដីបៀតបៀន (និក្ករុណា) និងអានិសង្សក្នុងករុណា (អវិហឹសា) ជាមុនថា "ផលរបស់និក្ករុណា (វិហឹសា) សេចក្ដីបៀតបៀន ធ្វើទុក្ខសត្វដោយដៃ ដុំដី និងដំបងជាដើមនេះ ដ៏លាមកក្រៃពេកទាំងក្នុងបច្ចុប្បន្ននេះ និងបរលោកនាយ ផលរបស់ករុណា

១- ផ្សាយមេត្តាព្រហ្មវិហារចំពោះសត្វដោយក្រុមៗ ថា "ស្ត្រីទាំងអស់ បុរសទាំងអស់ អរិយៈទាំងអស់ អនរិយៈទាំងអស់ ទេវតាទាំងអស់ មនុស្សទាំងអស់ វិនិបាតិកទាំងអស់ ចូរកុំឲ្យមានពៀរ ។ ល ។ ចូររក្សាខ្លួនឲ្យបានយ៉ាងនេះជាដរាបទៅ ។

២- អាការ ៧ នោះគឺ ស្ត្រីទាំងអស់ ១ ។ ល ។ វិនិបាតិកទាំងអស់ ១ ។

៣- ផ្សាយមេត្តាព្រហ្មវិហារទៅរកសត្វក្នុងទិសទាំង ១០ សត្វក្នុងទិសនីមួយៗ ចាត់ជាអាការៗ រួមត្រូវជាអាការ ១០ ។

សេចក្តីអាណិតអាសូរសត្វ ទើបប្រសើរទាំងក្នុងបច្ចុប្បន្ននេះ និងបរលោកនាយ” ។

កាលបើព្រះយោគី ប្រារព្ធនឹងចម្រើនន្ធវករុណាព្រហ្មវិហារនេះ កុំគប្បីបម្រើនចំពោះបុគ្គលដែលជាទោស ៤ ពួក និងបុគ្គលដែលមិនមែនជាខេត្ត ២ ពួក ដូចពោលមកហើយក្នុងមេត្តាភាវនានោះឡើយ, បើប្រទះឃើញបុគ្គលណាមួយដែលគួរឲ្យអាណិត ដូចមនុស្សពិកលពិការ កំសត់ទុរគត កំបុតដៃកំបុតជើងជាដើម ក៏គប្បីញ៉ាំងករុណាព្រហ្មវិហារឲ្យប្រព្រឹត្តទៅក្នុងបុគ្គលនោះថា “**កិច្ឆំ វតាយំ សត្តោ អាបន្នោ អប្បេវ នាម ឥមម្ហា ទុក្ខា មុច្ចេយ្យ** ឱហ្ន៎! សត្វនេះ ដល់នូវសេចក្តីលំបាក ធ្វើដូចម្តេចហ្ន៎! នឹងគប្បីឲ្យរួចចាកទុក្ខនេះបាន” ។

បើរកបុគ្គលដែលគួរអាណិតបែបនេះពុំបាន គប្បីទាញយកបុគ្គលដែលកំពុងបាននូវសេចក្តីសុខ តែប្រព្រឹត្តធ្វើនូវអំពើបាបជាប្រក្រតី មកប្រៀបនឹងមនុស្សទោសដែលរាជអាជ្ញាត្រូវឲ្យសម្លាប់បង់ ហើយញ៉ាំងករុណាព្រហ្មវិហារឲ្យប្រព្រឹត្តទៅថា “បុគ្គលនោះ បានសេចក្តីសុខតែក្នុងបច្ចុប្បន្នជាតិនេះទេ

តទៅទៀត មុខជាសោយនូវទុក្ខទោមនស្សជាពន្លឹក ក្នុងអបាយភូមិមិនខាន ព្រោះមិនមានធ្វើកល្យាណកម្មដោយទ្វារណាមួយសោះឡើយ ដូចជាមនុស្សទោសដែលរាជបុរសវាយក្លែងជើងក្អែកបណ្តើរទៅកាន់ទីដែលនឹងសម្លាប់ បើមានគេឱ្យនូវខាទនីយភោជនីយាហារបន្តិចបន្តួច ក៏បរិភោគសម្តែងអាការដូចជាបាននូវសេចក្តីសុខ ស្កប់ស្កល់ទៅដោយភោគតែមិនមានបុគ្គលណាមួយ គេសម្គាល់ថាបានសុខឡើយគេសម្គាល់ថាមុខជានឹងស្លាប់ដោយពិត" ។

តអំពីនោះមក គប្បីញុំាងករុណាព្រហ្មវិហារដោយឧបាយនេះឱ្យប្រព្រឹត្តទៅក្នុងបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាកណ្តាល បុគ្គលដែលមានពៀរដល់គ្នា រៀងជាលំដាប់មក សូម្បីបុគ្គលនោះៗ ជាអ្នកធ្វើនូវកុសលកម្មក្តី ក៏គប្បីឱ្យប្រព្រឹត្តទៅថា "បុគ្គលនោះៗ គង់ដល់នូវសេចក្តីទុក្ខដោយពិត ព្រោះកន្លងនូវវដ្តទុក្ខមិនទាន់ផុត" លំដាប់មកគប្បីឱ្យប្រព្រឹត្តទៅក្នុងជនទាំង ៤ ពួក ធ្វើចិត្តឱ្យស្មើជាសីមសម្ភេទដូចក្នុងមេត្តាព្រហ្មវិហារ ហើយសេពនូវនិមិត្ត គឺសីមសម្ភេទ

នោះដោយច្រើន បម្រើនឲ្យរឿយៗ ដរាបដល់ញុំាងអប្បនា ឲ្យបម្រើនឡើងបាន ដោយអំណាចនៃតិកជ្ឈានតិងចតុក្កជ្ឈាន ហើយបើព្រះយោគីផ្សាយករុណាព្រហ្មវិហារ ដោយអំណាចនៃឈានតីមួយៗ បំពោះទៅកាន់សត្វដែលនៅក្នុងទិសនោះៗ ជាអនោធិសោផរណា ឱធិសោផរណានិងទិសាផរណា ក៏នឹងបាននូវអានិសង្ស ១១ យ៉ាង ដូចក្នុងមេត្តាព្រហ្មវិហារ ។

## មុទិតាព្រហ្មវិហារ

កាលបើព្រះយោគាវចរកុលបុត្រ ប្រារព្ធដើម្បីបម្រើននូវមុទិតាព្រហ្មវិហារ(១) មុនដម្បូង កុំគប្បីបម្រើនក្នុងបុគ្គលដែលជាទោស មិនមែនជាបទដ្ឋាននៃមុទិតាព្រហ្មវិហារ ៣ ពួកគឺ បុគ្គលដែលជាទីស្រឡាញ់ ១ បុគ្គលដែលជាកណ្តាល ១ បុគ្គលដែលមានពៀរដល់គ្នា ១ និងបុគ្គលដែលមិនមែនជាខេត្តនៃមុទិតាព្រហ្មវិហារ ២ ពួក គឺបុគ្គលដែលមានភេទខុស

---

១- គួរដាក់ថា: ឃើញទោសក្នុងឥស្សាសេចក្តីច្រណែន ឬអរតិ សេចក្តីមិនត្រេកអរ ឃើញអានិសង្សក្នុងមុទិតា ព្រោះធម៌ទាំងនេះជាសត្រូវដល់គ្នានិងគ្នា តែច្បាប់ដើមលោកមិនបាលពោលដល់ ។

គ្នា និងបុគ្គលដែលធ្វើមរណកាលកន្លងហើយនោះឡើយ គប្បីបម្រើនក្នុងបុគ្គលជាទីស្រឡាញ់ក្រៃពេក(១) ជាមុន ។

កាលបើបានឃើញ បានឮបុគ្គលដែលជាទីស្រឡាញ់ក្រៃពេកនោះ កំពុងរីករាយបានដល់នូវសេចក្ដីសុខ គប្បីញ៉ាំងមុទិតាព្រហ្មវិហារឱ្យកើតឡើងថា "**មោទតិ វតាយំ សត្តោ អហោ សាធុ អហោ សុដ្ឋុ** ឱហ្ន៎! សត្វនេះរីករាយ ល្អពេកប្រពៃពេក" ។ សូម្បីបុគ្គលនោះបានដល់នូវសេចក្ដីសុខ តែអំពីអតីតជាតិ ដល់មកក្នុងបច្ចុប្បន្នជាតិនេះ ជាអ្នកកំសត់ទុរគត ក៏គប្បីរឭកដល់ភាពដែលបុគ្គលនោះដល់នូវសេចក្ដីសុខ អំពីអតីត កាន់យកនូវអាការដែលបុគ្គលនោះរីករាយកន្លងទៅហើយ មកញ៉ាំងមុទិតាព្រហ្មវិហារឱ្យកើតឡើងថា "**ឯស អតីតេ ឯវំ មហាភោគោ មហាបរិវារោ និច្ច-មុទិតោ អហោសិ** បុគ្គលនុ៎ះ អំពីអតីត ជាអ្នកមានភោគច្រើនយ៉ាងនេះ មានបរិវារច្រើនយ៉ាងនេះ ជាអ្នករីករាយជានិច្ច

១- សំឡាញ់ដែលប្រាកដស្មើដោយអ្នកលេង កាលបើប្រទះគ្នាសើចមុនទើបនិយាយស្ដីជាខាងក្រោយ (សោណ្ឌសហាយ) ។

យ៉ាងនេះ” ។ ខាងអនាគតក៏គប្បីញ៉ាំងមុទិតាព្រហ្មវិហារឲ្យកើតឡើងដូចគ្នា ។

តអំពីនោះមក គប្បីញ៉ាំងមុទិតាព្រហ្មវិហារឲ្យប្រព្រឹត្តទៅតាមន័យនេះក្នុងបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាកណ្តាល បុគ្គលដែលមានពៀរដល់គ្នា រៀងជាលំដាប់មក ដរាបដល់រម្ងាប់នូវបដិឃៈក្នុងបុគ្គលដែលមានពៀរបាន ហើយញ៉ាំងមុទិតាព្រហ្មវិហារ ឲ្យប្រព្រឹត្តទៅក្នុងជនទាំង ៤ ពួក ធ្វើចិត្តឲ្យស្មើជាសីមសម្ភេទ ដែលជាតួសមថ-និមិត្តក្នុងកម្មដ្ឋាននេះ រួចហើយគប្បីសេពនូវសមថនិមិត្តនោះឲ្យច្រើន បម្រើនឲ្យរឿយៗ ដរាបដល់ញ៉ាំងអប្បនាឲ្យចម្រើនឡើងដោយអំណាចនៃតិកជ្ឈាននិងចតុក្កជ្ឈានបាន ហើយបើព្រះយោគីផ្សាយមុទិតាព្រហ្មវិហារ ដោយអំណាចនៃឈាននីមួយៗ បំពោះទៅកាន់សត្វដែលនៅក្នុងទិសនោះៗ ជាអនោធិសោ-ផរណា ឱធិសោផរណា និងទិសាផរណា ក៏នឹងបាននូវអានិសង្ស ១១ យ៉ាងដូចក្នុងមេត្តាព្រហ្មវិហារ ។

# ឧបេក្ខាព្រហ្មវិហារ

កាលបើព្រះយោគាវចរកុលបុត្រ ប្រារព្ធដើម្បីចម្រើននូវឧបេក្ខាព្រហ្មវិហារ គប្បីហាត់នូវតិកជ្ឈាន និងចតុក្កជ្ឈានដែលខ្លួនបានក្នុងមេត្តាព្រហ្មវិហារជាដើមនោះ ឲ្យប៉ិនប្រសប់ដោយវសីទាំង ៥ ជាមុន លុះដល់ពេលដែលចេញចាកឈានទាំងនោះ គប្បីឃើញនូវទោសក្នុងព្រហ្មវិហារ ៣ ខាងដើម ព្រោះនៅប្រកបដោយមនសិការរាប់អានក្នុងសត្វ ប្រព្រឹត្តទៅក្នុងទីជិតនៃសេចក្តីថ្នាំងថ្នាក់និងសេចក្តីត្រេកអរ នៅគ្រោតគ្រាតដោយហេតុដែលប្រកបដោយសោមនស្ស និងឃើញនូវអានិសង្សក្នុងឧបេក្ខា ដោយភាពដែលស្ងប់ល្អិតយ៉ាងឧត្តមដោយវិសេស ហើយគប្បីញ៉ាំងឧបេក្ខាព្រហ្មវិហារឲ្យកើតឡើងក្នុងបុគ្គលដែលជាកណ្តាល មិនស្អប់មិនស្រឡាញ់ជាដំបូងលំដាប់មក សន្សឹមឲ្យកើតឡើងក្នុងបុគ្គលដែលជាទីស្រឡាញ់យ៉ាងមធ្យម បុគ្គលដែលជាទីស្រឡាញ់ក្រៃពេក បុគ្គលដែលមានពៀរដល់គ្នា ដរាបដល់ខ្លួនព្រះយោគីជាគម្រប់ ៤ ធ្វើឲ្យជា

សីមសម្តេទ ដោយភាពជាកណ្តាលៗ ហើយគប្បីសេពនូវនិមិត្តនោះដោយច្រើន បម្រើនឲ្យរឿយៗ ឡើងទៅ ។

ដោយអំណាច ដែលព្រះយោគីសេពនូវនិមិត្តនោះដោយច្រើនយ៉ាងនេះ បតុត្ថជ្ឈានក្នុងបតុក្កន័យ ឬបញ្ចមជ្ឈានក្នុងបញ្ចកន័យក៏នឹងកើតឡើង ហើយបើព្រះយោគីផ្សាយឧបេក្ខា-ព្រហ្មវិហារ ដោយអំណាចនៃឈាននោះទៅកាន់សត្វ ដែលនៅក្នុងទិសនោះៗ ជាអនោធិសោផរណា ឱធិសោផរណា និងទិសាផរណា ក៏នឹងបាននូវអានិសង្ស ១១ យ៉ាង ដូចក្នុងមេត្តាព្រហ្មវិហារ ។

ឧបេក្ខាព្រហ្មវិហារនេះ ព្រះយោគីដែលជាអាទិកម្មិកៈមិនត្រូវបម្រើនឡើយ ព្រោះដែលនឹងគប្បីបម្រើនបាន ត្រាតែឃើញទោសក្នុងមេត្តាព្រហ្មវិហារជាដើមដូចពោលមកហើយ ។

ព្រហ្មវិហារ ៤ ចប់

---

## *អារុប្បកម្មដ្ឋាន ៤*

# អាកាសានញ្ចាយតន

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវអារុប្បកម្មដ្ឋានទាំង ៤ គប្បីចម្រើនក្នុងអាកាសានញ្ចាយតន-កម្មដ្ឋានជាមុន មិនត្រូវចម្រើនរាយរាយតាមតែបាននោះឡើយ ។

ហេតុដូចម្ដេច ក្នុងអារុប្បកម្មដ្ឋានទាំង ៤ នេះបានជាត្រូវឲ្យចម្រើនរៀងតាំងអំពីអារុប្បទី ១ ទៅជាលំដាប់មិនត្រូវឲ្យចម្រើនរាយរាយតាមសេចក្ដីពេញចិត្តដូចក្នុងកម្មដ្ឋានឯទៀត ។

ព្រោះក្នុងអារុប្បកម្មដ្ឋានទាំង ៤ នេះ អារុប្បទី ១ ប្រព្រឹត្តកន្លងនូវអារម្មណ៍របស់រូបាវចរបតុត្ថជ្ឈាន(១) ឯអារុប្ប ៣ ខាងចុង ប្រព្រឹត្តកន្លងនូវអារម្មណ៍របស់អារុប្បជាន់ក្រោមៗឡើងទៅ ហេតុនោះ ទើបត្រូវចម្រើនរៀងតាមលំដាប់ នឹងចម្រើនរាយរាយតាមពេញចិត្តដូចកម្មដ្ឋានឯទៀតពុំបាន ។

ក្នុងកាលដែលប្រារព្ធដើម្បីចម្រើន នូវអាកាសានញ្ចាយតន-កម្មដ្ឋាននោះសោត គប្បីឃើញទោសក្នុងករជរូប(២) និង

---

១- នេះជាឈានចតុក្កន័យ បើជាបញ្ចកន័យវិញនោះជាតួបញ្ចមជ្ឈាន ។

២- រូបដែលគ្រោតគ្រាតក្នុងករជកាយ ។

អានិសង្សក្នុងអារុប្បកម្មដ្ឋានជាមុនថា "កិរិយាកាន់យកនូវដំបង នូវគ្រឿងសស្ត្រា និងជម្លោះប្រកែកផ្សេងៗក្តី ជំងឺអាពាធដ៏ច្រើនមានជំងឺក្នុងភ្នែកជាដើមក្តី ដែលកើតមានឡើងព្រោះហេតុតែរូប ឯក្នុងអារុប្បមិនមានសភាពទាំងអស់នេះឡើយ" ហើយគប្បីញុំាងរូបាវចរបតុត្ថជ្ឈានឲ្យកើតឡើងក្នុងកសិណទាំង ៩ ក្រៅអំពីអាកាសកសិណ(១) ហាត់សន្សំធ្វើបតុត្ថជ្ឈាននោះឲ្យថ្នឹកដោយវសីទាំង ៥ គប្បីមានចិត្តនឹករអាដល់រូបអស់កាលជានិច្ច ដល់ពេលដែលចូលកាន់បតុត្ថជ្ឈាននោះ ហើយចេញមកវិញ ត្រូវឃើញទោសក្នុងបតុត្ថជ្ឈាននោះថា "ឈាននេះយករូបកសិណដែលអញធ្លាប់រអានោះមកធ្វើជាអារម្មណ៍ផង មានសត្រូវគឺសោមនស្សស្ថិតនៅជិតផង គ្រោតគ្រាតជាងសន្តវិមោក្ខផង(២)" ហើយគប្បីបង្កន់នូវសេចក្តីត្រេកអរក្នុងបតុត្ថជ្ឈាននោះ ធ្វើទុកក្នុងចិត្តនូវអាកាសានញ្ចាយតន ដោយភាពដែលស្ងប់ល្អិតយ៉ាងឧត្តមវិសេស

---

១- ពាក្យកេចិអាចារ្យថា "កសិណ៨ ក្រៅអំពីអាកាសកសិណ និងអាលោកកសិណ" ។

២- អរុប្បជ្ឈានលោកហៅថា "សន្តវិមោក្ខ" ព្រោះល្អិតសុខុមស្ងប់ផុតចាករូប ។

ហើយបើត្រូវការទីឱកាសត្រឹមណា ក៏គប្បីលាតក្រាលនូវកសិណផ្សាយទៅកាន់ទីឱកាសត្រឹមនោះ សូម្បីដល់ទីបំផុតជុំវិញនៃបក្រវាឡក្តី ហើយគប្បីធ្វើទុកក្នុងចិត្តនូវទីឱកាសដែលកសិណពាល់ត្រូវនោះថា **“អាកាសោ អាកាសោ** អាកាសៗ” ដូច្នេះក៏បាន ឬថា **“អនន្តោ អាកាសោ អនន្តោ អាកាសោ** អាកាសមិនមានទីបំផុតៗ” ដូច្នេះក៏បាន ។

គ្រាន់តែព្រះយោគីមិននឹករក មិនធ្វើទុកក្នុងចិត្ត មិនពិចារណានូវកសិណនោះ ហើយធ្វើទុកក្នុងចិត្តថា **“អាកា-សោ អាកាសោ** ត្រង់ទីឱកាសដែលកសិណពាល់ត្រូវប៉ុណ្ណោះក៏បានឈ្មោះថាព្រះយោគីបើកនូវកសិណ” ។

ដោយអំណាច ដែលព្រះយោគីស្រាវយក នូវអាកាសនិមិត្តដែលបើកកសិណហើយនោះ មកត្រិះរិះបាត់បង្វឹកឲ្យរឿយៗថា **“អាកាសោ អាកាសោ** អាកាសៗ” ដូច្នេះ នីវរណធម៌ទាំងឡាយ(១) ក៏ទ្រោមទៅ សតិក៏ប្រុងឡើងដោយប្រពៃមាន

---

**១- នីវរណធម៌ត្រង់នេះ អាចារ្យខ្លះថា“នីវរណធម៌យ៉ាងល្អិត ដែលត្រូវលះដោយអរូបជ្ឈាន” តែលោកបដិសេធពាក្យនេះចេញ លោកកែថា: គ្រាន់តែសរសើរគុណតែរូបជ្ឈានខាងដើមប៉ុណ្ណោះ ។**

អាកាសនិមិត្តជាអារម្មណ៍ ចិត្តក៏តម្កល់នៅមាំដោយឧបចារជ្ឈាន លុះព្រះយោគីសេពនូវនិមិត្តនោះដោយច្រើន ចម្រើនឲ្យរឿយៗ ទៅទៀត អាកាសានញ្ចាយតនចិត្ត ក៏ប្រព្រឹត្តទៅដោយអំណាចនៃអប្បនា គឺចូលទៅអែបនៅក្នុងអាកាសដែលបើកកសិណហើយនោះ ដូចជារូបាវចរចិត្តដែលចូលទៅអែបនៅក្នុងបឋវីកសិណជាដើម ។

ក្នុងបឋមារុប្បជ្ឈាននេះ មានកាមាវចរជវន ៣ ឬ ៤ ដែលសម្បយុត្តដោយឧបេក្ខាវេទនា សឿនទៅក្នុងចំណែកខាងដើម ជវនទី ៤ ឬទី ៥ ជាអរូបាវចរគឺជាតួបឋមារុប្បចិត្ត ។

គ្រាកាលអរូបាវចរចិត្តកើតឡើងយ៉ាងនេះហើយ ព្រះយោគីអង្គនោះ ក្នុងពេលមុនសម្លឹងយកនូវមណ្ឌលរបស់កសិណដោយឈានចក្ខុ ដល់មកបរិកម្មធ្វើទុកក្នុងចិត្តថា “អាកាសោ អាកាសោ” ដូច្នេះ ក៏សម្លឹងយកតែអាកាសក្នុងនិមិត្តនោះប៉ុណ្ណោះឯង ។

ដោយលំដាប់នៃព្យាយាមប៉ុណ្ណោះ ព្រះយោគីអង្គនោះ ក៏បានឈ្មោះថា “ប្រព្រឹត្តកន្លងនូវរូបសញ្ញា(១) ដោយសព្វគ្រប់ លះបង់នូវបដិឃសញ្ញា(២) មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា(៣) ហើយចូលដល់នូវអាកាសានញ្ចាយតនជ្ឈាន មានអាកាសមិនមានទីបំផុតជាទីលំនៅ” ។

## វិញ្ញាណញ្ចាយតន

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវវិញ្ញាណញ្ចាយតនកម្មដ្ឋាន គប្បីហាត់សន្សំវសី ទាំង ៥ ឲ្យប៉ិនក្នុងអាកាសានញ្ចាយតនសមាបត្តិជាមុន គប្បីឃើញទោសក្នុងអាកាសានញ្ចាយតនសមាបត្តិថា “សមាបត្តិនេះមានសត្រូវគឺរូបាវចរជ្ឈានស្ថិតនៅជិតជិត មិនមែនជាស្ងប់ល្អិតយ៉ាងឧត្តមវិសេស ដូចជាវិញ្ញាណញ្ចាយតនសមាបត្តិឡើយ”

---

១- សញ្ញាដែលប្រព្រឹត្តទៅក្នុងរូបជ្ឈាន ។ ពាក្យថា “រូបសញ្ញា” នេះជាឈ្មោះនៃរូបជ្ឈានផង ជាឈ្មោះនៃអារម្មណ៍របស់រូបជ្ឈាន មានបឋវីកសិណជាដើមផង ។

២- សញ្ញាដែលកើតឡើងដោយចក្ខុវត្ថុជាដើម និងរូបារម្មណ៍ជាដើមខ្ទប់គ្នា ។

៣- សញ្ញាដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ មានសភាពផ្សេងៗ មានរូបារម្មណ៍ និងសទ្ទារម្មណ៍ជាដើម ។

ហើយគប្បីលះបង់នូវសេចក្ដីត្រេកអរ ក្នុងអាកាសានញ្ចាយ-តនសមាបត្តិ ធ្វើទុកក្នុងចិត្តនូវវិញ្ញាណញ្ចាយតន-សមាបត្តិ ដោយភាពដែលស្ងប់ស្ងៀមយ៉ាងឧត្តម ហើយគប្បីនឹករំពឹងស្រាវយកនូវបឋមារុប្បវិញ្ញាណ ដែលផ្សាយទៅកាន់អាកាសមិនមានទីបំផុតនោះមកធ្វើទុកក្នុងចិត្ត ពិចារណាត្រិះរិះបាត់បង្វឹកឲ្យរឿយៗ ឡើងទៅថា **អនន្តំ វិញ្ញាណំ អនន្តំ វិញ្ញាណំ** បឋមារុប្បវិញ្ញាណមិនមានទីបំផុត ។

ដោយអំណាច ដែលព្រះយោគីញុំាងភាវនាចិត្ត ឲ្យប្រព្រឹត្តទៅរឿយៗក្នុងនិមិត្ត គឺបឋមារុប្បវិញ្ញាណយ៉ាងនេះ នីវរណ-ធម៌ទាំងឡាយ ក៏ទ្រោមទៅ សតិក៏តម្កល់នៅដោយប្រពៃមានវិញ្ញាណនិមិត្តជាអារម្មណ៍ ចិត្តក៏តម្កល់នៅមាំដោយឧបចារជ្ឈាន ។

បើព្រះយោគីសេពនូវនិមិត្តនោះដោយច្រើន បម្រើនឲ្យរឿយៗ ឡើងទៅទៀត វិញ្ញាណញ្ចាយតនចិត្ត ក៏នឹងប្រព្រឹត្តទៅដោយអំណាចនៃអប្បនា គឺថាចូលទៅអែបនៅក្នុងបឋ-មារុប្បវិញ្ញាណ ត្រង់ដែលពាល់ត្រូវនូវអាកាសដែលបើក

កសិណហើយ ដូចជាអាកាសានញ្ចាយតនចិត្ត កាលដែលចូលទៅអែបនៅក្នុងអាកាស ។

ក្នុងទុតិយារុប្បជ្ឈានេះ មានកាមាវចរជវន ៣ ឬ ៤ ដែលសម្បយុត្តដោយឧបេក្ខាវេទនា លឿនទៅក្នុងបំណែកខាងដើម ជវនទី ៤ ឬទី ៥ ជាអរូបាវចរគឺជាតួទុតិយារុប្បចិត្ត ។

ដោយលំដាប់នៃព្យាយាមប៉ុណ្ណោះ ព្រះយោគីអង្គនោះក៏បានឈ្មោះថា "ប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនជ្ឈានដោយសព្វគ្រប់ ហើយចូលដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន មានវិញ្ញាណមិនមានទីបំផុត ជាទីលំនៅ ។

## អាកិញ្ចញ្ញាយតន

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវអាកិញ្ចញ្ញាយតនកម្មដ្ឋាន គប្បីហាត់សន្សំនូវវសីទាំង ៥ ឲ្យប្ញឹកក្នុងវិញ្ញាណញ្ចាយតនសមាបត្តិជាមុន គប្បីឃើញទោសក្នុងវិញ្ញាណញ្ចាយតនសមាបត្តិថា "សមាបត្តិនេះ មានសត្រូវគឺអាកាសានញ្ចាយតនៈ ស្ថិតនៅជិតមិនមែនស្ងប់ល្អិតយ៉ាងឧត្តមវិសេស ដូចជាអាកិញ្ចញ្ញាយតនសមាបត្តិឡើយ" ហើយ

គប្បីលះបង់នូវសេចក្ដីត្រេកអរ ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនសមាបត្តិ ដោយភាពដែលស្ងប់ល្អិតយ៉ាងឧត្តម ហើយគប្បីនឹករំពឹងស្រាវយកនូវភាពដែលមិនមាន (នត្ថិភាវ) ក្ដី ភាពដែលសូន្យ (សុញ្ញភាវ) ក្ដី ភាពដែលស្ងាត់ (វិវិត្តភាវ) ក្ដី របស់បឋមារុប្បវិញ្ញាណ ដែលជាអារម្មណ៍របស់ទុតិយារុប្បវិញ្ញាណនោះ មកធ្វើទុកក្នុងចិត្តពិចារណាត្រិះរិះបង្វឹកឲ្យរឿយៗ ឡើងទៅថា “**នត្ថិ កិញ្ចិ** អ្វីតិចតួច មិនមាន” ឬថា “**នត្ថិ នត្ថិ** មិនមានៗ” ដូច្នេះក្ដី “**សុញ្ញំ សុញ្ញំ** សូន្យៗ” ដូច្នេះក្ដី “**វិវិត្តំ វិវិត្តំ** ស្ងាត់ៗ” ដូច្នេះក្ដី តាមទំនងនៃអាការដែលចម្រើន ។

ដោយអំណាចដែលព្រះយោគីញុំាងភាវនាចិត្ត ឲ្យប្រព្រឹត្តទៅរឿយៗ ក្នុងឈានុប្បត្តិនិមិត្ត គឺនត្ថិភាព សុញ្ញភាព វិវិត្តភាព របស់បឋមារុប្បវិញ្ញាណនោះ នីវរណធម៌ទាំងឡាយក៏ទ្រោមទៅ សតិក៏តម្កល់នៅដោយប្រពៃ មានឈានុប្បត្តិនិមិត្តជាអារម្មណ៍ ចិត្តក៏តម្កល់នៅមាំដោយឧបចារជ្ឈាន ។

បើព្រះយោគីសេពនូវនិមិត្តនោះដោយច្រើន បម្រើនឲ្យរឿយៗទៅទៀត អាកិញ្ចញ្ញាយតនបិត្ត ក៏នឹងប្រព្រឹត្តទៅដោយអំណាចនៃអប្បនា គឺថាចូលទៅអែបនៅក្នុងសុញ្ញភាព វិវិត្ត-ភាព ឬ នត្ថិភាព របស់មហគ្គតវិញ្ញាណ (បឋមារុប្បវិញ្ញាណ) ដែលផ្សាយទៅកាន់អាកាស ហើយប្រព្រឹត្តនៅ ដូចជាវិញ្ញាណ-ញ្ចាយតនបិត្ត កាលដែលចូលទៅអែបនៅក្នុងមហគ្គតវិញ្ញាណ (បឋមារុប្បវិញ្ញាណ) ដែលផ្សាយទៅពាល់ត្រូវនូវអាកាស ។

ក្នុងតតិយារុប្បជ្ឈាននេះ មានកាមាវចរជវន ៣ ឬ ៤ ដែលសម្បយុត្តដោយឧបេក្ខាវេទនា សឿនទៅក្នុងបំណែកខាងដើមជវន ទី ៤ ឬទី ៥ ជាអរូបាវចរ គឺជាតួតតិយារុប្បបិត្ត ។

គ្រាកាលអប្បនាបិត្ត កើតឡើងយ៉ាងនេះហើយ ព្រះយោគីអង្គនោះ ក្នុងពេលមុនបានឃើញនូវវិញ្ញាណដែលប្រព្រឹត្តទៅពួដ៏អាកាស ដោយវិញ្ញាណញ្ចាយតនជ្ឈានបក្ខុ ដល់វិញ្ញាណនោះប្រាសបាត់ទៅ ដោយកិរិយាបរិកម្មធ្វើទុកក្នុងបិត្តថា "មិនមានៗ" ដូច្នេះជាដើម ក៏ឃើញតែភាពដែលមិនមាន គឺសំណាមរបស់វិញ្ញាណនោះប៉ុណ្ណោះ ។

ដោយលំដាប់នៃព្យាយាមប៉ុណ្ណោះ ព្រះយោគីអង្គនោះក៏បានឈ្មោះថា "ប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយសព្វគ្រប់ ហើយចូលដល់នូវអាកិញ្ចញ្ញាយតនជ្ឈានមានអ្វីតិចតួចមិនមានជាទីលំនៅ ។

## នេវសញ្ញានាសញ្ញាយតន

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវនេវសញ្ញានាសញ្ញាយតនកម្មដ្ឋាន គប្បីហាត់សន្សំនូវវសីទាំង ៥ ឲ្យប្រឹកក្នុងអាកិញ្ចញ្ញាយតនសមាបត្តិជាមុន គប្បីឃើញទោសក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ និងអានិសង្សក្នុងនេវ-សញ្ញានាសញ្ញាយតនសមាបត្តិថា "សមាបត្តិនេះ មានសត្រូវគឺវិញ្ញាណញ្ចាយតនស្ថិតនៅជិតជិត មិនមែនស្ងប់ស្ងៀតយ៉ាងឧត្តមដូចជានេវសញ្ញានាសញ្ញាយតនសមាបត្តិឡើយ ព្រោះសញ្ញាជារោគ សញ្ញាជាពក សញ្ញាជាសរ នេវសញ្ញានា-សញ្ញាយតនៈ ដែលមានសញ្ញាបន្តិចបន្តួចយ៉ាងសុខុម ស្មើរតែនឹងមិនមាន ទើបស្ងប់ស្ងៀតយ៉ាងឧត្តមក្រៃពេក" ហើយ

ក៏គប្បីលះបង់នូវសេចក្តីត្រេកអរ ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ធ្វើទុកក្នុងចិត្តនូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដោយភាពដែលស្ងប់ល្អិតយ៉ាងឧត្តម ហើយនឹករំពឹងស្រាវយកនូវអាកិញ្ចញ្ញាយតនសមាបត្តិ ត្រង់ដែលធ្វើនូវនត្ថិភាពឲ្យជាអារម្មណ៍ហើយប្រព្រឹត្តនៅនោះ មកធ្វើទុកក្នុងចិត្តពិចារណាត្រិះរិះបង្ហឹកឲ្យរឿយៗថា "អាកិញ្ចញ្ញាយតនសមាបត្តិ ដែលធ្វើនូវនត្ថិភាពឲ្យជាអារម្មណ៍ ហើយប្រព្រឹត្តនៅនោះឯង ទើបស្ងប់ល្អិតយ៉ាងឧត្តមក្រៃពេក" ។

ដោយអំណាចដែលព្រះយោគី ញុំាំងភាវនាចិត្តឲ្យប្រព្រឹត្តទៅរឿយៗ ក្នុងឈានគិមិត្ត គឺតតិយារុប្បសមាបត្តិនោះ នីវរណធម៌ទាំងឡាយក៏ទ្រោមទៅ សតិក៏តម្កល់នៅដោយប្រពៃ មានឈាននិមិត្តជាអារម្មណ៍ ចិត្តក៏តម្កល់នៅមាំដោយឧបចារជ្ឈាន ។

បើព្រះយោគីសេពនូវនិមិត្តនោះដោយច្រើន បម្រើនឲ្យរឿយៗឡើងទៅទៀត នេវសញ្ញានាសញ្ញាយតនចិត្តក៏ប្រព្រឹត្តទៅ ដោយអំណាចនៃអប្បនា គឺថាចូលទៅអែបនៅ

ក្នុងខន្ធទាំងឡាយ ៤(១) ដែលជាតួអាកិញ្ចញ្ញាយតនសមាបត្តិ ដូចជាអាកិញ្ចញ្ញាយតនចិត្ត កាលដែលចូលទៅអែបនៅក្នុងនត្ថិភាពជាដើម របស់បឋមារុប្បវិញ្ញាណ ។

ក្នុងចតុត្ថារុប្បជ្ឈាននេះ មានកាមាវចរជវន ៣ ឬ ៤ ដែលសម្បយុត្តដោយឧបេក្ខាវេទនា លឿនទៅក្នុងចំណែកខាងដើម ជវនទី ៤ ឬ ៥ ជាអរូបាវចរគឺជាតួចតុត្ថារុប្បចិត្ត ។

ដោយលំដាប់នៃព្យាយាមប៉ុណ្ណោះ ព្រះយោគីអង្គនោះក៏បានឈ្មោះថា "ប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈានដោយសព្វគ្រប់ ហើយចូលដល់នូវនេវសញ្ញានាសញ្ញាយ-តនជ្ឈាន មានសញ្ញាដ៏ល្អិតសុខុមក្រៃពេក ស្ទើរតែនឹងមិនមានជាទីលំនៅ" ។

អារុប្បកម្មដ្ឋាន ៤ ចប់

---

១- អរូបក្ខន្ធ ៤ ដែលជាតួចិត្តនិងចេតសិកសម្បយុត្តដោយឈានដែលជាអារម្មណ៍របស់ចតុត្ថារុប្បជ្ឈាន ។

# អាហារេបដិក្កូលសញ្ញា

សញ្ញាដែលកើតឡើង ដោយអំណាចកាន់យកនូវអាការជាបដិក្កូលក្នុងកពលិង្ការាហារ(១) គឺអាហារដែល ស៊ី ផឹក ទំពា ស្រូបចូលទៅ ហៅថា "អាហារេបដិក្កូលសញ្ញា-កម្មដ្ឋាន" ។

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវអាហារេបដិក្កូលសញ្ញាកម្មដ្ឋាននេះ គប្បីរៀនយកនូវវិធីទាំងពួងក្នុងសំណាក់នៃអាចារ្យជាកល្យាណមិត្តជាមុន ហើយចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ពិចារណានូវភាពជាបដិក្កូលក្នុងកពឡិង្ការាហារ ដោយអាការ ១០ យ៉ាង

---

១- អាហារសព្ទប្រែថា "សភាពដែលនាំមក" ។ អាហារមាន ៤ គឺ កពឡិង្ការា-ហារ ១ ផស្សាហារ ១ មនោសញ្ចេតនាហារ ១ វិញ្ញាណាហារ ១ ។ កពឡិង្ការាហារ នាំមកនូវឱជដ្ឋមករូបៈ ផស្សាហារ នាំមកនូវវេទនា ៣ មនោសញ្ចេតនាហារ នាំមកនូវបដិសន្ធិក្នុងភព ៣ វិញ្ញាណាហារ នាំមកនូវនាមរូប ក្នុងបដិសន្ធិក្ខណៈ ។ និកន្តិភយ កើតក្នុងកព-ឡិង្ការាហារ ឧបគមនភយ កើតក្នុងផស្សាហារ, ឧបបត្តិភយ កើតក្នុងមនោសញ្ចេតនាហារ បដិសន្ធិភយ កើតក្នុងវិញ្ញាណាហារ ។ កពឡិង្ការាហារ ប្រៀបដោយសាច់របស់កូន ផស្សាហារ ប្រៀបដោយមេគោឥតស្បែក មនោសញ្ចេតនាហារ ប្រៀបដោយរណ្តៅរងើកភ្លើង វិញ្ញាណាហារ ប្រៀបដោយមុខនៃលំពែង ។ (ក្នុងទីនេះសំដៅយកតែកពឡិង្ការាហារ) ។

កុំឲ្យល្អៀងចាកវិធីដែលខ្លួនរៀនមក អំពីសំណាក់នៃអាចារ្យ ត្រង់បទណានីមួយឡើយ ។

ដែលថាគប្បីពិចារណា នូវភាពជាបដិកូលក្នុងកពឡិង្ការាហារដោយអាការ ១០ យ៉ាងនោះ តើអាការអ្វីខ្លះ? - អធិប្បាយដូចម្ដេច?

ភាពជាបដិកូលដោយអាការ ១០ យ៉ាងនោះដូច្នេះគឺ

១- **គមនតោ** បដិកូលដោយដំណើរដើរ ។

អធិប្បាយថា : គប្បីពិចារណាឲ្យឃើញថា "អាហារនោះជាបដិកូលគួរខ្ពើម តាំងតែអំពីចុះចាកទីសេនាសនៈឆ្ពោះទៅកាន់ស្រុកជាទីគោចរ ដើរលុយកាត់ភក់ជ្រាំ ជាន់លើវត្ថុមិនស្អាតផ្សេងៗ មានមូត្រនិងករីសជាដើម" ។

២- **បរិយេសនតោ** បដិកូលដោយស្វែងរក ។

អធិប្បាយថា : គប្បីពិចារណាឲ្យឃើញថា "អាហារនោះជាបដិកូលគួរខ្ពើមដោយដើរស្វែងរកតត្រុករុករាន សព្វសំយាបផ្ទះអ្នកស្រុក ប្រទះឆ្កែដេញខាំ គោក្របី ដេញផល់រុយខៀវហើរមកទំលើក្បាលក៏មាន មនុស្សខ្លះឲ្យ ខ្លះមិនឲ្យ

ខ្លះឲ្យតិច ខ្លះឲ្យច្រើន ខ្លះឲ្យបាយផ្អូម បង្អែមបាស់ ខ្លះធ្វើជាមិនឃើញ ខ្លះពោលពាក្យទ្រគោះបោះបោកផ្សេងៗ ជាដើម" ។

៣- **បរិភោគតោ** បដិកូលដោយបរិភោគ ។

អធិប្បាយថា : គប្បីពិចារណាឲ្យឃើញថា "អាហារនោះ ជាបដិកូលគួរខ្ពើម ដោយបរិភោគចាប់កាន់ដោយម្រាមដៃ ញើសក្អែលហូរស្រក់ចូលទៅ ដល់ដាក់មកក្នុងមាត់ទោះបីអាហារនោះប៉ុន្មានមុខក្តី ក៏ប្រឡប់ល្បាយគ្នាទាំងអស់ ហើយទំពាលម្អិតដោយធ្មេញ គ្រលេវប្រមូលដោយអណ្តាតផ្សើមដោយទឹកមាត់ មានសណ្ឋានដូចជាកម្អួតឆ្កែ ប្រឡាក់ប្រឡូសជាប់នៅដោយជើងធ្មេញជាដើម គួរឲ្យខ្ពើមរអើមក្រៃពេក" ។

៤- **អាសយតោ** បដិកូលដោយទីអាស្រ័យ ។

អធិប្បាយថា : ទីអាស្រ័យ (អាសយ) មាន ៤ គឺ បិត្តាសយៈ ទីអាស្រ័យរបស់ប្រមាត់ ១ សេម្ហាសយៈ ទីអាស្រ័យរបស់ស្លេស្ម ១ បុព្វាសយៈ ទីអាស្រ័យរបស់ខ្ទុះ ១ លោហិតាសយៈ ទីអាស្រ័យរបស់ឈាម ១ ។

ក្នុងអាសយៈទាំង ៤ យ៉ាងនេះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងស្តេចចក្រពត្តិ មានតែមួយៗ ឯបុគ្គលដែលមានបុណ្យតិច មានប្រាជ្ញាទន់ មានគ្រប់ទាំង ៤ ហេតុនោះបើបុគ្គលណា ដែលមានទីអាស្រ័យរបស់ប្រមាត់ច្រើន អាហារដែលបុគ្គល នោះលេបចូលទៅ ដូចជាប្រឡាក់ដោយប្រេងស្រគំយ៉ាងខាប់ គួរខ្ពើមក្រៃពេក បុគ្គលដែលមានទីអាស្រ័យរបស់ស្លេស្ម ច្រើន ដូចជាប្រឡាក់ដោយរសនៃផ្លែខ្ទឹងឬស្លឹកខ្ទឹង បុគ្គល ដែលមានទីអាស្រ័យរបស់ខ្ទុះច្រើន ដូចជាប្រឡាក់ដោយតក្កៈ(១) ផ្អូម បុគ្គលដែលមានទីអាស្រ័យរបស់ឈាមច្រើន ដូចជា ប្រឡាក់ដោយទឹកជ្រលក់ គួរខ្ពើមក្រៃពេក ព្រះយោគីគប្បី ពិចារណាឲ្យឃើញថា អាហារជាបដិក្កូលគួរខ្ពើម ដោយទី អាស្រ័យដូចន័យដែលពោលមកនេះ ។

៥- **និធានតោ** បដិក្កូលដោយកន្លែងដែលតម្កល់ នៅក្នុងផ្ទៃ ។

អធិប្បាយថា : ព្រះយោគីគប្បីពិចារណានូវភាពជាបដិ-

---

១- ទឹកដោះគោមួយបែបដែលគេដាំមួយភ្លើងហើយយកមកតម្កល់ទុក (ទឹកដោះ..)

កូលរបស់អាហារដោយកន្លែងដែលតម្កល់នៅថា "អាហារដែលប្រឡាក់ដោយអាសយៈទាំង ៤ ណាមួយ ហើយចូលទៅក្នុងផ្ទៃនោះ មិនមែនទៅតម្កល់នៅក្នុងភាជន៍មាសជាដើមឡើយ គឺបើបុគ្គលអ្នកលេបចូលទៅនោះអាយុបាន ១០ ឆ្នាំ ២០ ឆ្នាំ ។ ល ។ ១ រយឆ្នាំ ក៏ទៅតម្កល់នៅក្នុងឱកាសប្រាកដស្មើដោយរណ្ដៅវច្ចដែលគេខានលាងអស់ ១០ ឆ្នាំ ២០ ឆ្នាំ ។ ល ។ ១ រយឆ្នាំ មុខគួរឲ្យខ្ពើមរអើមក្រៃពេក" ។

៦- **អបរិបក្កតោ** បដិកូលដោយភាពដែលមិនទាន់រលួយ ។

អធិប្បាយថា : ព្រះយោគីគប្បីពិចារណានូវភាពជាបដិកូលរបស់អាហារដែលមិនទាន់រលួយថា អាហារដែលចូលទៅតម្កល់នៅក្នុងទីឱកាសគួរខ្ពើមបែបនេះហើយ កាលដែលមិនទាន់រលួយនៅឡើយ សូម្បីអាហារនោះទើបបរិភោគក្នុងថ្ងៃនោះក្ដី បរិភោគក្នុងថ្ងៃម្សិលក្ដី ក្នុងថ្ងៃមុនៗ មកក្ដីក៏ទៅផ្ដុំនៅជាមួយគ្នាទាំងអស់ រួបរឹតទៅដោយដុំស្លេស្ម ភ្លើងធាតុក្នុងកាយបំបាយកម្ដៅបែកទៅជាពពុះតូប-ធំ អាប់អួរ

ដោយក្លិនអសុភផ្សេងៗ មុខគួរឱ្យខ្ពើមរអើមក្រៃពេក”។

៧- **បរិបក្កតោ** បដិក្កូលដោយភាពដែលរលួយហើយ ។

អធិប្បាយថា : ព្រះយោគីគប្បីពិចារណា នូវភាពជាបដិ-ក្កូលរបស់អាហារដែលរលួយហើយថា “អាហារដែលភ្លើងធាតុក្នុងកាយដុតកម្តៅឱ្យរលួយហើយនោះ ក៏មិនមែនក្លាយទៅជាមាសឬប្រាក់ជាដើមឡើយ គ្រាន់តែបញ្ចេញនូវពពុះ និងក្រពេញតូច-ធំ ហើយណាដែលដល់នូវភាពជាអាហារចាស់ ក៏ចូលទៅតម្កល់នៅក្នុងទីលំនៅនៃអាហារចាស់ ហាក់ដូចជាដីស្អិតមានពណ៌លឿង ដែលគេកិនឱ្យជ្រាយហើយដាក់ចុះទៅក្នុងបំពង់ ណាដែលដល់នូវភាពជាទឹកមូត្រ ក៏ជ្រាបចូលទៅដក់នៅក្នុងថ្លោកមូត្រប៉ុណ្ណោះ មុខគួរឱ្យខ្ពើមរអើមក្រៃពេក” ។

៨- **ផលតោ** បដិក្កូលដោយផល ។

អធិប្បាយថា : ព្រះយោគីគប្បីពិចារណានូវភាពជាបដិ-ក្កូលរបស់អាហារដែលឱ្យផលមកថា “អាហារនេះ ណាដែលរលួយទៅដោយល្អ ក៏ញុំាងសាកអសុភទាំងឡាយមានសក់

និងរោមជាដើមឲ្យបម្រើនស្រស់ស្រោងឡើង ឈាដែលមិនរលួយល្អ ក៏បណ្ដាលឲ្យកើតទៅជារោគច្រើនប្រការមានកមនិងរមាស់ជាដើម” ។

៩- **និស្សន្ទតោ** បដិកូលដោយហូរបេញ ។

អធិប្បាយថា : ព្រះយោគីគប្បីពិចារណានូវភាពជាបដិ-កូល របស់អាហារដោយហូរបេញមកវិញថា “អាហារនេះកាលដែលលេបចូលទៅតែតាមទ្វារ ១ ដល់ហូរបេញមកវិញតាមទ្វារច្រើនជាអនេក ឈាដែលបេញមកតាមភ្នែក ហៅថាព-ពឹកភ្នែក ដែលបេញមកតាមត្រចៀក ហៅថាអាចម៍ត្រចៀកជាដើម” ពុំនោះសោតគប្បីពិចារណាឲ្យឃើញជាបដិកូលថា “អាហារនេះកាលដែលលេបចូលទៅ អំពាវនាវរកគ្នាច្រើនមកជួបជុំបរិភោគរីករាយសប្បាយបិត្ត ដល់ក្លាយទៅជាឧច្ចារៈនិងបស្សាវៈជាដើម ហើយហូរបេញមកវិញ ក៏ទៅជាពួនសម្ងំបញ្ចេញម្នាក់ឯងក្នុងទីស្ងាត់ មុខគួរឲ្យអៀនខ្មាសក្រៃពេក” ។

១០- **សម្មក្ខនតោ** បដិកូលដោយប្រឡាក់ប្រឡូស ។

អធិប្បាយថា : ព្រះយោគីគប្បីពិចារណានូវភាពជា

បដិកូលរបស់អាហារដោយប្រទ្បាក់ប្រឡូសថា “អាហារនេះកាលដែលបរិភោគក៏ប្រឡាក់ដៃនិងបបូរមាត់ជាដើម ដល់បរិភោគរួចហើយ ភ្លើងធាតុក្នុងកាយ ផាត់ប្រាណទៅសព្វសរីរៈទាំងមូល ក៏ទៅប្រឡាក់នៅត្រង់ធ្មេញត្រង់អណ្តាត ទ្វារតូច ទ្វារធំ ជាដើម មុខគួរឲ្យខ្ពើមរអើមក្រៃពេក” ។

កាលបើព្រះយោគី ពិចារណាត្រិះរិះនូវភាពជាបដិកូលរបស់អាហារដោយអាការទាំង ១០ ដូចពោលមកយ៉ាងនេះហើយ កពឡិង្ការាហារ ក៏នឹងប្រាកដឡើងដោយអាការជាបដិកូល ។

បើព្រះយោគីសេពនូវនិមិត្តនោះ ដោយច្រើន បម្រើនឲ្យរឿយៗ ឡើងទៅ នីវរណធម៌ទាំងឡាយក៏ទ្រោមទៅ ចិត្តក៏តម្កល់នៅមាំដោយឧបចារសមាធិ តែក្នុងកម្មដ្ឋាននេះឲ្យសម្រេចបានតែត្រឹមឧបចារជ្ឈានប៉ុណ្ណោះ មិនអាចឲ្យសម្រេចដល់អប្បនាឈានបានឡើយ ព្រោះកពឡិង្ការាហារជាគម្ភីរភាពជ្រាលជ្រៅតាមសភាពជាធម្មតា ។

**អាហារេបដិកូលសញ្ញា ចប់**

# ចតុធាតុវវដ្ឋានកម្មដ្ឋាន

កិរិយាកំណត់នូវលក្ខណៈរបស់ធាតុទាំង ៤ ហៅថា “ចតុធាតុវវិដ្ឋានកម្មដ្ឋាន” ។

ធាតុទាំង ៤ នោះគឺ បឋវីធាតុ (ធាតុដី) ១ អាបោធាតុ (ធាតុទឹក) ១ តេជោធាតុ (ធាតុភ្លើង១) វាយោធាតុ (ធាតុខ្យល់ ១) ។

ធាតុទាំង ៤ នេះលោកសម្ដែងឲ្យពិស្ដារដោយអាការមាន ៤២ យ៉ាងគឺ បឋវីធាតុមានអាការ ២០, អាបោធាតុមានអាការ ១២, តេជោធាតុ មានអាការ ៤, វាយោធាតុមានអាការ ៦ ។

អាការទាំង ៤២ ក្នុងធាតុទាំង ៤ នោះអ្វីខ្លះ?

អាការ ២០ ក្នុងបឋវីធាតុ និងអាការ ១២ ក្នុងអាបោធាតុ គប្បីដឹងក្នុងបញ្ចកៈ ៤ ខាងដើមនិងឆក្កៈ ២ ខាងចុងនៃកាយគតាសតិកម្មដ្ឋាន ។

អាការ ៤ ក្នុងតេជោធាតុនោះគឺ(១)

១- **សន្តប្បតិ** ភ្លើងដែលញ៉ាំងកាយឲ្យក្ដៅសព្វ ។

១- ភ្លើងធាតុទាំង ៤ នេះមិនមានឈ្មោះជានាមសព្ទទើបសន្មតហៅថា កិរិយាស័ព្ទដូច្នេះ ។

២- **ជីរិយតិ** ភ្លើងដែលញុំាងកាយឲ្យចាស់គ្រាំគ្រា ។

៣- **បរិឌយ្ហតិ** ភ្លើងដែលញុំាងកាយឲ្យក្ដៅរោលរាល ។

៤- **សម្មាបរិណាមំ គច្ឆតិ** ភ្លើងដែលញុំាងអាហារឲ្យ ទ្រោមទៅដោយល្អ ។

អាការ ៦ ក្នុងវាយោធាតុគឺ

១- **ឧទ្ធង្គមា វាតា** ខ្យល់ដែលផាត់ឡើងទៅ ខាងលើ ។

២- **អធោគមា វាតា** ខ្យល់ដែលផាត់ចុះទៅ ខាងក្រោម ។

៣- **កុច្ឆិសយា វាតា** ខ្យល់ដែលផាត់នៅខាងក្រៅ ពោះវៀន ។

៤- **កោដ្ឋាសយា វាតា** ខ្យល់ដែលផាត់នៅខាងក្នុង ពោះវៀន ។

៥- **អង្គមង្គានុសារិនោ វាតា** ខ្យល់ដែលផាត់ផ្សាយទៅ សព្វសាពាង្គកាយ ។

៦- **អស្សាសបស្សាសា** ខ្យល់ដង្ហើមចេញចូល ។

លក្ខណៈរបស់ធាតុទាំង ៤ នោះដូចម្ដេច?

លក្ខណៈរបស់ធាតុទាំង ៤ នោះដូច្នេះគឺ

បឋវីធាតុ មានលក្ខណៈរឹងគ្រោតគ្រាត អាបោធាតុមានលក្ខណៈរាវសម្រាប់ផ្សារទុកនូវកាយ តេជោធាតុ មានលក្ខណៈក្ដៅសម្រាប់ចម្អិនទុកនូវកាយ វាយោធាតុ មានលក្ខណៈរហើយៗសម្រាប់បក់ផាត់នូវកាយ ។

កាលបើព្រះយោគាវចរកុលបុត្រ មានប្រាថ្នាដើម្បីចម្រើននូវកម្មដ្ឋាននេះ គប្បីចូលទៅកាន់ទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយសន្សឹមពិចារណាធ្វើទុកក្នុងចិត្ត តាមវិធីដែលនឹងពោលទៅក្នុងខាងមុខ ។

តែកម្មដ្ឋាននេះ មានវិធីចម្រើន ២ បែប តាមសមគួរដល់ព្រះយោគីដែលមានប្រាជ្ញាក្លា និងមានប្រាជ្ញាទន់ ។

បើព្រះយោគីដែលមានប្រាជ្ញាក្លា គប្បីនឹករំពឹងស្រាវយកនូវកាយរបស់ខ្លួនទាំងមូល មកពិចារណាធ្វើទុកក្នុងចិត្តរឿយៗ ឲ្យឃើញថាគ្រាន់តែជាធាតុ ៤ មិនមែនជាសត្វ មិនមែនជាជីវិត តាមន័យយ៉ាងសង្ខេបដូច្នេះថា “នៅក្នុងកាយ

នេះ របស់ណាដែលមានលក្ខណៈរឹង មានអាការគ្រោតគ្រាត បាត់ទុកជាធាតុដី ដែលមានលក្ខណៈសម្រាប់ផ្សារទុកនូវកាយ មានអាការរាវ បាត់ទុកជាធាតុទឹក ដែលមានលក្ខណៈសម្រាប់បម្រុងនូវកាយ មានអាការក្ដៅ បាត់ទុកជាធាតុភ្លើង ដែលមានលក្ខណៈសម្រាប់បក់ផាត់នូវកាយ មានអាការរហើយៗ បាត់ទុកជាធាតុខ្យល់” គ្រាន់តែព្រះយោគីព្យាយាមធ្វើទុកក្នុងចិត្តប៉ុណ្ណោះ ឧបចារសមាធិ ក៏នឹងកើតឡើង តែមិនដល់នូវអប្បនាឡើយ ព្រោះកម្មដ្ឋាននេះមានអារម្មណ៍ជាសភាវធម៌ ។

បើព្រះយោគីមានប្រាជ្ញាទន់ គប្បីរៀនយកនូវធាតុទាំង ៤ ឲ្យពិស្ដារអំពីសំណាក់នៃអាចារ្យ ដោយអាការ ៤២ ដូចបាន ពោលមកក្នុងខាងដើមហើយគប្បីចម្រើនដោយអាការ ៤ យ៉ាង ។

អាការទាំង ៤ យ៉ាងនោះអ្វីខ្លះ? -អធិប្បាយដូចម្ដេច?

អាការទាំង ៤ យ៉ាងនោះដូច្នេះគឺ

១- **សសម្ភារសង្ខេបតោ** ចម្រើនដោយបំប្រួញតាមសម្ភាររបស់ខ្លួន ។

អធិប្បាយថា : គប្បីកំណត់នូវអាការដែលរឹងក្នុងកោដ្ឋាសៈ ២០ ថាជា “ធាតុដី” អាការដែលរាវសម្រាប់ផ្សារទុកនូវកាយក្នុងកោដ្ឋាសៈ ១២ ថាជា “ធាតុទឹក” អាការដែលក្ដៅសម្រាប់បម្អិននូវកាយក្នុងកោដ្ឋាសៈ ៤ ថាជា “ធាតុភ្លើង” អាការដែលរហើយៗ សម្រាប់បក់ផាត់នូវកាយក្នុងកោដ្ឋាសៈ ៦ ថាជា “ធាតុខ្យល់” ។

២- **សសម្ភារវិភត្តិតោ** ចម្រើនដោយកិរិយាបែកតាមសម្ភាររបស់ខ្លួន ។

អធិប្បាយថា : គប្បីចម្រើនតាមវិធីឧគ្គហកោសល្ល ៧ យ៉ាង និងអប្បនាកោសល្ល ១០ យ៉ាង ដូចពោលមកហើយក្នុងកាយគតាសតិកម្មដ្ឋាន ប្លែកគ្នាខ្លះតែក្នុងកាយគតាសតិកម្មដ្ឋាន ត្រូវធ្វើទុកក្នុងចិត្តដោយបដិកូល ឯក្នុងកម្មដ្ឋាននេះ ត្រូវធ្វើទុកក្នុងចិត្តដោយធាតុ និងក្នុងកាយគតាសតិកម្មដ្ឋានមានអាការតែ ៣២ ឯក្នុងកម្មដ្ឋាននេះ មានអាការ ៤២ ។

៣- **សលក្ខណសង្ខេបតោ** ចម្រើនដោយបំប្រួញតាមលក្ខណៈរបស់ខ្លួន ។

សេចក្ដីអធិប្បាយ ដូចក្នុងអាការទី ១ ប្លែកគ្នាតែថា "អាការនិងលក្ខណៈ" ប៉ុណ្ណោះ គឺថាក្នុងអាការទី ១ ត្រូវកំណត់នូវអាការរឹងជាដើម ក្នុងកោដ្ឋាសៈនោះៗ ថាជាធាតុនោះៗ ឯក្នុងអាការទី ៣ នេះ ត្រូវកំណត់នូវលក្ខណៈរឹងជាដើម ក្នុងកោដ្ឋាសៈនោះៗ ថាជាធាតុនោះៗ ។

៤- **សលក្ខណវិភត្តិតោ** បម្រើនដោយកិរិយាបែកតាមលក្ខណៈរបស់ខ្លួន ។

អធិប្បាយថា : គប្បីកំណត់នូវលក្ខណៈដែលរឹងលក្ខណៈដែលរាវ សម្រាប់ផ្សារទុកនូវកាយ លក្ខណៈដែលក្ដៅសម្រាប់បម្អិនទុកនូវកាយ លក្ខណៈដែលរហើយៗ សម្រាប់បក់ផាត់នូវកាយ ក្នុងកោដ្ឋាសៈទាំង ៣២ មានសក់ជាដើមគ្រប់កោដ្ឋាសៈនីមួយៗ ថាជា "ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់(១)" ។

កាលបើព្រះយោគី បានបម្រើនដោយអាការទាំង ៤ យ៉ាងដូចពោលមកនេះហើយ ជួនកាលតែដោយអាការមួយៗក៏ឧបចារសមាធិកើតឡើងបាន តែបើនៅមិនទាន់កើតឡើងទេ

១- គឺកំណត់តែក្នុងកោដ្ឋាសៈនីមួយៗឲ្យឃើញថាមានធាតុបួនៗ គ្រប់កោដ្ឋាសៈទាំង ៣២ ។

ក៏គប្បីធ្វើទុកក្នុងចិត្តនូវធាតុទាំង ៤ ដោយអាការ ១៣ យ៉ាង តទៅទៀត ។

អាការ ១៣ យ៉ាងនោះអ្វីខ្លះ? អធិប្បាយដូចម្តេច?

អាការ ១៣ យ៉ាងនោះដូច្នេះគឺ

១- **វចនត្ថតោ** ត្រូវធ្វើទុកក្នុងចិត្តដោយកែអត្ថរបស់ពាក្យ ។

អធិប្បាយថា : ធាតុទាំង ៤ បានសេចក្តីដោយឡែកៗអំពីគ្នាដូច្នេះគឺ ភាពដែលក្រាស់ឬលាតត្រដាង ហៅថា "**បឋវី**" សភាពដែលជ្រាបសើមទូទៅ ហៅថា "**អាបោ**" សភាពដែលក្តៅ ហៅថា "**តេជោ**" សភាពដែលបក់ផាត់ ហៅថា "**វាយោ**" ធម្មជាតិដែលទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ដែលតាក់តែងនូវសំសារទុក្ខឬបង្ហូរមកនូវទុក្ខប្រមាណមិនបាន ហៅថា "ធាតុ" ត្រូវធ្វើទុកក្នុងចិត្តដោយកែអត្ថរបស់ពាក្យយ៉ាងនេះ ។

២- **កលាបតោ** ត្រូវធ្វើទុកក្នុងចិត្តដោយកលាបៈ ។

អធិប្បាយថា : គ្រប់កោដ្ឋាសៈ ទាំងអស់ដែលលោកសន្មត

ឲ្យហៅថា “សក់ រោម” ជាដើម សុទ្ធតែសន្មតដោយប្រជុំនៃធម៌ ៨ យ៉ាង គឺ វណ្ណ ១ គន្ធ ១ រស ១ ឱជា ១ ធាតុ ៤ ដូចគ្នាទាំងអស់ តកោដ្ឋាសៈណាដែលជាកម្មសមុដ្ឋាននោះ លោកសន្មតដោយប្រជុំនៃធម៌ ១០ គឺថែមជីវិតិន្ទ្រិយ ១ បុរិសភាវឬឥត្ថីភាវ ១ ទៀត ហើយដែលលោករាប់ថាជា “បឋវីធាតុ អាបោធាតុ”នោះ តាមដោយធាតុដែលផ្សាយឡើងច្រើន ត្រូវធ្វើទុកក្នុងចិត្តដោយកលាបៈយ៉ាងនេះ ។

៣- **បុណ្ណតោ** ត្រូវធ្វើទុកក្នុងចិត្តដោយលំអិត ។

អធិប្បាយថា : បឋវីធាតុក្នុងសរីរៈនេះ បើកំណាត់ត្រឹមពាក់កណ្ដាលមកខាងលើ ហើយលម្អិតឲ្យម៉ត់ជាផង់ធូលីជាបរមាណុ(១) ទៅទៀត ប្រមាណបាន ១ ទោណា(២) ប៉ុណ្ណោះ

១- ពាក្យថា “បរមាណុ” នេះជាវិធីរាប់មួយបែប ។ កេចិអាចារ្យពោលថា “ភាគទី ៨ នៃអង្គុលីជាយវ ១ ភាគទី ៨ នៃយវជាឱកា ១ ភាគទី ៨ នៃ ឱកាជាលិក្ខា ១ ភាគទី ៨ នៃលិក្ខាជារថរេណុ ១ ភាគទី ៨ នៃរថរេណុជាតជ្ជារិ ១ ភាគទី ៨ នៃតជ្ជារិជាអណុ ១ ភាគទី ៨ នៃអណុជាបរមាណុ ១” ។ តែអដ្ឋកថាចារ្យពោលថា “អង្គុលី ១ មានធញ្ញមាស ៧ ធញ្ញមាស ១ មានឱកា ៧ ឱកា ១ មានលិក្ខា ៧ លិក្ខា ១ មានរថរេណុ ៣៦ រថរេណុ ១ មានតជ្ជារិ ៣៦ តជ្ជារិ ១ មានអណុ ៣៦ អណុ ១ មានបរមាណុ ៣៦ ។ ២- “ទោណា” នេះជាវិធីវាល់ ឬថ្លឹងមួយបែបមានប្រមាណ ១៦ នាឡិប្រក្រតី ឬ ១២នាឡិអ្នកមគធៈ ។ វិធីជិតប្រមាណដូចនេះជា ៤ ក្ដាប់ដោយប្រក្រតីជា ១ កុឌុវ, ៤ កុឌុវជា ១ នាឡិ, ១៦ នាឡិជា ១ ទោណា ។

ហើយមានអាបោធាតុប្រមាណកន្លះទោណជួយប្រុងទុក តេជោ-ធាតុជួយរក្សាទុក វាយោធាតុជួយបក់ផាត់ទុកមិនឲ្យខ្ចាយទៅបាន អាបោធាតុ តេជោធាតុ និងវាយោធាតុតម្កល់នៅក្នុងបឋវីធាតុ ជួយប្រុងទុក រក្សាទុក បក់ផាត់ទុកនូវគ្នានិងគ្នា មិនឲ្យជ្រាបហូរទៅបាន ឲ្យបម្អិនបក់ផាត់នូវកាយមិនឲ្យរលួយទៅបាន ត្រូវធ្វើទុកក្នុងចិត្តដោយលំអិតយ៉ាងនេះ ។

៥- **លក្ខណាទិតោ** ត្រូវធ្វើទុកក្នុងចិត្តដោយលក្ខណៈជាដើម ។

អធិប្បាយថា : បឋវីធាតុ មានភាពដែលរឹងគ្រោតគ្រាតជាលក្ខណៈ មានភាពដែលជាទីតម្កល់នៃសហជាតធម៌ជាកិច្ច មានកិរិយាទទួលរងទុកនូវសហជាតធម៌ជាផល អាបោធាតុមានកិរិយាហូរទៅជាលក្ខណៈ មានកិរិយាចម្រើននូវសហជាត-ធម៌ជាកិច្ច មានកិរិយាប្រុងទុកនូវសហជាតធម៌ជាផល តេជោ-ធាតុ មានភាពដែលក្តៅជាលក្ខណៈ មានកិរិយាបម្អិនទុកនូវសហជាតធម៌ជាកិច្ច មានកិរិយាប្រគល់ឲ្យនូវភាពដែលទន់របស់សហជាតធម៌ជាផល វាយោធាតុ មានភាពដែល

រហើយៗ ជាលក្ខណៈ មានកិរិយាបក់ផាត់នូវសហជាតធម៌ ជាកិច្ច មានកិរិយានាំទៅនូវសហជាតធម៌ជាផល ត្រូវធ្វើទុកក្នុងចិត្តដោយលក្ខណៈជាដើមយ៉ាងនេះ ។

៥- **សមុដ្ឋានតោ** ត្រូវធ្វើទុកក្នុងចិត្តដោយសមុដ្ឋាន ។

អធិប្បាយថា : ក្នុងកោដ្ឋាសៈទាំង ៤២ មានសក់ជាដើម មានខ្យល់ដង្ហើមចេញចូលជាទីបំផុតនោះ អាហារថ្មី ១ អាហារចាស់ ១ ខ្ទុះ ១ ទឹកមូត្រ ១ ទាំង ៤ នេះ មានរដូវជាដែនកើត ទឹកភ្នែក ១ ញើស ១ ទឹកមាត់ ១ ទឹកសំបោរ ១ ទាំង ៤ នេះ ជួនកាលមានរដូវជាដែនកើត ជួនកាលមានចិត្តជាដែនកើត តេជោធាតុ ដែលចម្អិននូវអាហារដែលបុគ្គលបរិភោគចូលទៅ មានកម្មជាដែនកើត ខ្យល់ដង្ហើមចេញ-ចូល មានចិត្តជាដែនកើត កោដ្ឋាសៈសល់អំពីនោះ ៣២ មានរដូវ ចិត្ត កម្ម អាហារ គ្រប់ទាំង ៤ ជាដែនកើត ត្រូវធ្វើទុកក្នុងចិត្តដោយសមុដ្ឋានយ៉ាងនេះ ។

៦- **នានត្តេកត្តតោ** ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលផ្សេងគ្នា និងភាពដែលត្រូវគ្នា ។

អធិប្បាយថា : ធាតុទាំងនោះមានលក្ខណៈនិងកិច្ចនិងផលផ្សេងៗ គ្នាក៏ពិត តែថាសុទ្ធតែបានឈ្មោះថា "រូប" ដូចគ្នា ព្រោះមិនកន្លងនូវលក្ខណៈដែលវិនាស បានឈ្មោះថា "មហាភូត" ដូចគ្នា ព្រោះហេតុដែលប្រាកដឡើងធំៗជាដើម(១) បានឈ្មោះថា "ធាតុ" ដូចគ្នា ព្រោះមិនកន្លងនូវធាតុលក្ខណៈ ដែលទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួននិងតាក់តែងនូវសំសារទុក្ខ ឬបង្ករមកនូវទុក្ខប្រមាណមិនបាន បានឈ្មោះថា "ធម៌" ដូចគ្នា ព្រោះទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ហើយទ្រទ្រង់ទុកតាមសមគួរដល់ខណៈរបស់ខ្លួន សុទ្ធតែមិនទៀងដូចគ្នា ព្រោះតែងតែអស់ទៅ ពុកផុយទៅ សុទ្ធតែជាទុក្ខដូចគ្នា ព្រោះតែងតែប្រកបដោយភ័យ សុទ្ធតែមិនមែនជារបស់ខ្លួនដូចគ្នា ព្រោះមិនមានខ្លឹមសារសោះឡើយ

១- ធាតុទាំង ៤ បានឈ្មោះថា "មហាភូត" ដោយហេតុ ៥ យ៉ាងគឺ មហន្តបាតុភាវតោ កើតប្រាកដឡើងធំៗ ១ មហាភូតសាមញ្ញតោ ទូទៅដោយហេតុដែលមិនពិតច្រើនប្រការ ១ មហាបរិហារតោ ត្រូវរក្សាដោយបច្ច័យដ៏ច្រើន ១ មហាវិការតោ មានពិការច្រើន ១ មហត្តា ភូតត្តា ហៅថា "មហា" ព្រោះព្រះយោគីត្រូវកំណត់ដោយព្យាយាមដ៏ធំ ហៅថា "ភូត" ព្រោះជារបស់មាននៅ ១ ។

ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលផ្សេងគ្នា និងភាពដែលត្រូវគ្នាយ៉ាងនេះ ។

៧- **វិនិព្ភោគាវិនិព្ភោគតោ** ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលបែកបាកគ្នានិងមិនបែកបាកគ្នា ។

អធិប្បាយថា : ធាតុទាំង ៤ នេះកាលកើតឡើងក៏កើតឡើងព្រមគ្នា កាលប្រព្រឹត្តទៅក៏ប្រព្រឹត្តទៅព្រមគ្នា មិនដែលបែកបាកគ្នាក្នុងកលាបៈ ណាមួយឡើយ តែទុកណាជាដូច្នោះ ក៏គង់បែកបាកគ្នាដោយលក្ខណៈដែលផ្សេងគ្នា ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលបែកបាកគ្នា និងមិនបែកបាកគ្នាយ៉ាងនេះ ។

៨- **សភាគវិសភាគតោ** ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលមានចំណែកស្មើគ្នានិងមិនស្មើគ្នា ។

អធិប្បាយថា : បណ្ដាធាតុទាំង ៤ នេះ ធាតុ ២ ខាងដើមគឺ បឋវីធាតុនិងអាបោធាតុមានចំណែកស្មើគ្នាព្រោះមានភាពធ្ងន់ដូចគ្នា ធាតុ ២ ខាងចុងគឺតេជោធាតុនិងវាយោធាតុមានចំណែកស្មើគ្នា ព្រោះមានភាពស្រាលដូចគ្នា តែថាធាតុ ២ ខាងដើមនិង ២ ខាងចុងមានចំណែកមិនស្មើគ្នា ព្រោះធាតុ ២

ខាងដើមមានភាពធ្ងន់ ឯធាតុ ២ ខាងចុងមានភាពស្រាល ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលមានចំណែកស្មើគ្នា និងមិនស្មើគ្នាយ៉ាងនេះ ។

៩- **អជ្ឈត្តិកពាហិរវិសេសតោ** ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលប្លែកគ្នារបស់ធាតុ ជាខាងក្នុងនិងធាតុជាខាងក្រៅ ។

អធិប្បាយថា : ធាតុខាងក្នុងជាទីអាស្រ័យរបស់វិញ្ញាណ-វត្ថុ ៦(១) មានចក្ខុវិញ្ញាណវត្ថុជាដើមផង ជាទីអាស្រ័យរបស់វិញ្ញត្តិទាំង ២ គឺកាយវិញ្ញត្តិនិងវចីវិញ្ញត្តិផង ជាទីអាស្រ័យរបស់ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ និងជីវិតិន្ទ្រិយផង ហើយប្រកបដោយឥរិយាបថមានសមុដ្ឋានទាំង ៤ ឯធាតុខាងក្រៅមិនមែនដូច្នោះឡើយ ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលប្លែកគ្នារបស់ធាតុជាខាងក្នុងនិងធាតុជាខាងក្រៅយ៉ាងនេះ ។

១០- **សង្គហតោ** ត្រូវធ្វើទុកក្នុងចិត្តដោយសង្គ្រោះ ។

អធិប្បាយថា : បឋវីធាតុណា ដែលមានកម្មជាដែនកើត

---

**១- វិញ្ញាណដែលអាស្រ័យនូវវត្ថុទាំង ៦ មានចក្ខុវត្ថុជាដើមហើយកើតឡើង ។**

លោកសង្គ្រោះចូលជាមួយគ្នាដោយអាបោធាតុ តេជោធាតុ វាយោធាតុ ណាដែលមានកម្មជាដែនកើត ព្រោះមានជាតិស្មើគ្នា បឋវីធាតុណា ដែលមានចិត្តជាដើមជាដែនកើត ក៏លោកសង្គ្រោះចូលជាមួយគ្នាដោយអាបោធាតុ តេជោធាតុ វាយោធាតុ ណាដែលមានចិត្តជាដើមជាដែនកើតដូចគ្នា ត្រូវធ្វើទុកក្នុងចិត្តដោយសង្គ្រោះយ៉ាងនេះ ។

១១- **បច្ចយតោ** ត្រូវធ្វើទុកក្នុងចិត្តដោយបច្ច័យ ។

អធិប្បាយថា : បឋវីធាតុ ដែលអាបោធាតុជួយប្រុងទុក តេជោធាតុជួយរក្សាទុក វាយោធាតុជួយបក់ផាត់ទុក ជាបច្ច័យជាទីពឹងផ្អែកនៃមហាភូតទាំង ៣ ដ៏សេស អាបាធាតុ តេជោធាតុ វាយោធាតុ តម្កល់នៅក្នុងបឋវីធាតុ ជួយប្រុងទុក រក្សាទុក បក់ផាត់ទុកនូវគ្នានិងគ្នា ជាបច្ច័យជួយផ្សារទុក បម្រុងទុក បក់ផាត់ទុក នូវមហាភូតទាំង ៣ ដ៏សេសអំពីខ្លួន ត្រូវធ្វើទុកក្នុងចិត្តដោយបច្ច័យយ៉ាងនេះ ។

១២- **អសមន្នាហារតោ** ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលមិនដឹងនូវគ្នានិងគ្នា ។

អធិប្បាយថា : បឋវីធាតុមិនបានដឹងថា “អញជាបឋវីធាតុ អញជាបច្ច័យជាទីពឹងផ្អែកនៃមហាភូតទាំង ៣”, សូម្បីមហាភូតទាំង ៣ ក៏មិនបានដឹងថា “បឋវីធាតុ ជាបច្ច័យជាទីពឹងផ្អែករបស់ខ្លួន” ត្រូវធ្វើទុកក្នុងចិត្តដោយភាពដែលមិនដឹងនូវគ្នានិងគ្នាយ៉ាងនេះ ។

១៣- **បច្ចយវិភាគតោ** ត្រូវធ្វើទុកក្នុងចិត្តដោយកិរិយាចែកនូវបច្ច័យ ។

អធិប្បាយថា : បច្ច័យរបស់ធាតុ មាន ៤ គឺ កម្ម ១ ចិត្ត ១ អាហារ ១ ឧតុ ១[១] ។

កម្មតែម្យ៉ាង ជាបច្ច័យដល់ធាតុដែលមានកម្មជាដែនកើត ចិត្តជាដើមតែម្យ៉ាងៗ ជាបច្ច័យដល់ធាតុ ដែលមានចិត្តជាដើមតែម្យ៉ាងៗ ជាដែនកើត កម្ម ចិត្ត អាហារ ឧតុ តែម្យ៉ាងៗ ជាជនក[២] បច្ច័យដល់ធាតុដែលមាន កម្ម ចិត្ត អាហារ ឧតុ តែម្យ៉ាងៗ ជាដែនកើត ហើយជាបច្ច័យ

---

១- កម្ម សំដៅយកកុសលាកុសលកម្ម ដែលញ៉ាំងរូបឲ្យកើតបាន ។ ចិត្ត សំដៅយកចិត្តណា ១ ដែលញ៉ាំងរូបឲ្យកើតបាន ។ អាហារ សំដៅយកអាហារខាងក្នុង ដែលញ៉ាំងរូបឲ្យកើតបាន ។ ឧតុ សំដៅយកតេជោធាតុ ។ ២- បច្ច័យញ៉ាំងធាតុនោះៗ ឲ្យកើត ។

ដទៃមានឧបនិស្សយប្បច្ច័យជាដើម ដល់ធាតុដ៏សេសបានខ្លះ ដោយបរិយាយ(១) ត្រូវធ្វើទុកក្នុងចិត្តដោយកិរិយាបែកនូវបច្ច័យយ៉ាងនេះ ។

កាលបើព្រះយោគីនឹករំពឹងធ្វើទុកក្នុងចិត្តរឿយៗ ដោយអាការទាំង ១៣ យ៉ាងដូចពោលមកនេះ ធាតុទាំង ៤ ក៏នឹងប្រាកដឡើង ហើយគទៅឧបចារសមាធិ ក៏នឹងកើតឡើងដោយពិត ។

បតុធាតុវវដ្ឋាន ចប់

*វិធីចម្រើននូវកម្មដ្ឋានទាំង ៤០ ចប់*

## ឈានកថា

ក្នុងទីបំផុតនៃកម្មដ្ឋានទាំង ៤០ នឹងរួបរួមពោលអំពីឈាន ដែលជាគុណត្រូវព្រះយោគីបានក្នុងកម្មដ្ឋានទាំងនោះតាមសមគួរ ដោយសេចក្ដីសង្ខេបតទៅ ។

ធម្មជាតអ្វីដែលហៅថា "ឈាន" មានប៉ុន្មានយ៉ាង? អធិប្បាយដូចម្ដេចខ្លះ?

---

១- ក្នុងអាការនេះ លោកពោលដោយពិស្ដារពេកណាស់ ដែលពោលមកនេះជាសង្ខេបក្រៃពេក ។

ធម្មជាតដែលសម្លឹងយកនូវអារម្មណ៍របស់ខ្លួនៗ មានបឋវីកសិណជាដើម ឬដែលដុតកម្ដៅនូវបច្ចនីកធម៌ទាំងឡាយ មាននីវរណធម៌ ៥ ជាដើម មិនឲ្យកើតឡើងបានហៅថា "ឈាន" ។

ឈាននេះ ក្នុងទីខ្លះលោកពោលទុកជា ២ យ៉ាងដូច្នេះគឺ

១- **អារម្មណូបនិជ្ឈាន** ឈានដែលសម្លឹងយកនូវអារម្មណ៍ បានដល់សមាបត្តិ ៨ ព្រមទាំងឧបចាររបស់ខ្លួន ។

២- **លក្ខណូបនិជ្ឈាន** ឈានដែលសម្លឹងយកនូវលក្ខណៈ បានដល់វិបស្សនា មគ្គ ផល ។

អធិប្បាយ : សមាបត្តិ ៨ ព្រមទាំងឧបចាររបស់ខ្លួនៗ ហៅថា "អារម្មណូបនិជ្ឈាន" ព្រោះសម្លឹងយកនូវអារម្មណ៍របស់កម្មដ្ឋានមានបឋវីកសិណជាដើម វិបស្សនា មគ្គ ផល ហៅថា "លក្ខណូបនិជ្ឈាន" ព្រោះវិបស្សនា សម្លឹងយកនូវលក្ខណៈមានអនិច្ចលក្ខណៈជាដើម មគ្គជាគ្រឿងញុំាងកិច្ចដែលសម្លឹងយកនូវអនិច្ចលក្ខណៈជាដើម របស់វិបស្សនានោះឲ្យសម្រេច ផលសម្លឹងយកនូវតថលក្ខណៈ គឺលក្ខណៈដែលពិតរបស់ព្រះនិព្វាន ។

ក្នុងទីនេះលោកសំដៅយកឈាន ២ យ៉ាងដទៃអំពីនោះគឺ

១- ឧបចារជ្ឈាន ឈានដែលប្រព្រឹត្តទៅក្នុងទីជិតនៃអប្បនា គឺជាបុព្វភាគនៃអប្បនា ។

២- អប្បនាឈាន ឈានដែលប្រព្រឹត្តទៅដោយអំណាចនៃអប្បនា ។

អធិប្បាយ : កាលដែលព្រះយោគី សម្លឹងយកនូវវង់កសិណជាដើម មកធ្វើជាអារម្មណ៍ ហើយបរិកម្មធ្វើទុកក្នុងចិត្តដរាបដល់នីវរណធម៌និងកិលេសទាំងពួង ទ្រោមស្ងប់ទៅជាលំដាប់ អង្គរបស់ឈានមានវិតក្កជាដើម ក៏កើតឡើងតែមិនទាន់មានកម្លាំង ចិត្តគ្រាន់តែប្រព្រឹត្តទៅក្នុងទីជិតនៃអប្បនាប៉ុណ្ណោះ មិនអាចឡើងកាន់អប្បនាបាន យ៉ាងនេះហៅថា "ឧបចារជ្ឈាន" ត្រង់ដែលអង្គរបស់ឈានកើតឡើងមានកម្លាំងក្លា ហើយចិត្តក៏ស្ទុះឡើងកាន់អប្បនាបាន ហៅថា "អប្បនាឈាន" ។

## *សេចក្តីប្លែកគ្នានៃឧបចារជ្ឈាននិងអប្បនាឈាន*

ឧបចារជ្ឈាននិងអប្បនាឈានប្លែកគ្នាដូចម្តេច?

ឧបចារជ្ឈានគឺអប្បនាឈានប្លែកគ្នាដូច្នេះគឺ ឧបចា-រជ្ឈាននៅជាកាមាវចរគ្រាន់តែលះនីវរណធម៌បាន ហើយប្រព្រឹត្តចូលទៅក្នុងទីជិតនៃអប្បនាប៉ុណ្ណោះ តែអង្គមានវិតក្កៈជាដើម កើតឡើងមិនទាន់មានកម្លាំងដូចពោលមកហើយ ជួនកាលគោងយកនូវនិមិត្តមកធ្វើជាអារម្មណ៍បាន ជួនកាលក៏ធ្លាក់ចុះកាន់ភវង្គវិញ តាំងនៅមិនជាប់បានយូរ ប្រៀបដូចជាកុមារតូចនៅមិនទាន់បេះក្រោកឈរខ្លួនឯងបាន មាតាចាប់លើកឡើងឲ្យរៀនឈរក៏មិនបានយូរប៉ុន្មាន តែងដួលចុះទៅលើផែនដីវិញជារឿយៗ ឯអប្បនាឈានជាមហគ្គតៈអាចសង្កត់នូវកាមាវចរគោត្រ ដែលជាកាមធាតុខាងក្រោមបាន ហើយស្ទុះចូលទៅកាន់មហគ្គតគោត្រ ដោយអំណាចដែលអង្គកើតឡើងមានកម្លាំងក្លាយ៉ាងវិសេស បិត្តអាចកាត់ផ្តាច់នូវភវង្គវារៈតែម្តង ហើយតាំងនៅអស់ថ្ងៃ ១ យប់ ១ បាន តែងប្រព្រឹត្តទៅតាមលំដាប់នៃកុសលជវន ប្រៀបដូចជាបុរសដែលមានកម្លាំង អាចក្រោកឡើងចាកអាសនៈ ហើយឈរនៅអស់ថ្ងៃ ១ បាន ។

## *ដំណើរដែលឈានកើត*

ដំណើរ ដែលឧបចារជ្ឈានទិងអប្បនាឈានកើត យ៉ាងដូចម្តេច?

ក្នុងកម្មដ្ឋានឯទៀតលើកទុកមិនបានពោល នឹង ពោលតែឈាន ដែលកើតឡើងដោយអំណាចនៃកសិណ ទាំង ១០ ទុកជាតួយ៉ាង តែសូម្បីក្នុងកម្មដ្ឋានឯទៀតៗ ក៏មាន ទំនងប្រហែលៗគ្នា ល្មមឲ្យពិចារណាទៅយល់បាន ប្លែក គ្នាតែកម្មដ្ឋានខ្លះមានទាំងឧបចារជ្ឈាន និងអប្បនាឈាន កម្ម-ដ្ឋានខ្លះមានតែឧបចារជ្ឈានប៉ុណ្ណោះ ក៏ក្នុងកសិណទាំង ១០ នេះ កាលបើព្រះយោគាវចរសម្លឹងយកកសិណណា ១ មកជា អារម្មណ៍ ហើយបរិកម្មធ្វើទុកក្នុងចិត្តតាមឈ្មោះរបស់កសិណ នោះៗ បើកភ្នែកសម្លឹងមើលវង់កសិណម្តង ធ្មេចភ្នែកនឹក រំពឹងម្តង បម្លងអារម្មណ៍នោះ ចូលមកក្នុងមនោទ្វារឲ្យបាន ស្ទាត់ ដរាបដល់ពេលដែលបើកភ្នែកឡើងឃើញវង់កសិណ នោះយ៉ាងណា ដល់ធ្មេចទៅវិញក៏ឃើញដូច្នោះដដែល ហៅថា “ឧគ្គហនិមិត្តកើត” ហើយតរុណសមាធិ គឺសមាធិ

យ៉ាងទី្វក៏កើតឡើងផង លុះព្រះយោគីក្រោកចាកអាសនៈនោះទៅរកទីឱកាសឯទៀតអង្គុយនៅយ៉ាងស្រួល ប្រមូលស្រាវយកឧគ្គហនិមិត្តនោះមកត្រិះរិះបរិកម្មហាត់បង្វឹក តាមឈ្មោះរបស់កសិណនោះៗ តទៅទៀត ពេលនោះនីវរណធម៌និងកិលេសទាំងពួងក៏ទ្រោមស្ងប់ទៅជាលំដាប់ ទើបបដិភាគនិមិត្តកើតឡើង អង្គឈានទាំង ៥ ក៏កើតឡើងផង តែនៅមានកម្លាំងថយដូចបានពោលមកហើយ ចិត្តក៏តម្កល់នៅមាំក្នុងឧបចារ-ភូមិ តែមិនទាន់សង្កត់នូវកាមាវចរគោត្រស្ទុះចូលទៅកាន់មហគ្គតគោត្របាននៅឡើយ គ្រាន់តែមានកម្លាំងវិសេសជាងកាមាវចរចិត្តជាប្រក្រតីប៉ុណ្ណោះ ត្រង់នេះព្រះយោគីក៏ចូលដល់ថ្នាក់ឧបចារជ្ឈាន ។

កាលបើព្រះយោគី បម្រើនបានបដិភាគនិមិត្តដូច្នេះហើយក៏ពុំបានលះបង់នូវព្យាយាម តែងលើកចិត្តឡើងឲ្យបែរមុខឆ្ពោះទៅកាន់បដិភាគនិមិត្តនោះ បរិកម្មកំណត់ធ្វើទុកក្នុងចិត្តតាមឈ្មោះរបស់កសិណនោះៗដដែល តមកមនោទ្វារាវជ្ជន-ចិត្តផ្តាច់បង់នូវភវង្គ ស្រាវយកនូវកសិណនោះៗ មកធ្វើជា

អារម្មណ៍ហើយកើតឡើង បើបុគ្គលនោះជាខិប្បាភិញ្ញា(១) ជវន ៤ បើជាទន្ធាភិញ្ញា(២) ជវន ៥ លឿនទៅក្នុងអារម្មណ៍នោះដដែល បណ្ដាជវន ទាំងនោះ ជវន ៣ ឬ ៤ ខាងដើមជាកាមាវចរ គ្រាន់តែមានវិតក្កៈ វិចារៈ បីតិ សុខៈ និងឯកគ្គតាមានកម្លាំងវិសេសជាងកាមាវចរចិត្តជាប្រក្រតី ឯជវនទី ៤ ឬទី ៥ ខាងចុងបំផុតទើបជារូបាវចរ បើជវន ៥ ទី ១ ឈ្មោះបរិកម្ម ទី ២ ឈ្មោះឧបចារៈ ទី ៣ ឈ្មោះអនុលោមៈ ទី ៤ ឈ្មោះគោត្រភូ ឯទី ៥ ជាតួអប្បនាចិត្ត បើជវន ៤ ទី ១ ឈ្មោះឧបចារៈ ទី ២ ឈ្មោះអនុលោមៈ ទី ៣ ឈ្មោះគោត្រភូ ទី ៤ ជាតួអប្បនាចិត្ត ។

កាលបើជវនលឿនទៅតាមលំដាប់ គ្រប់ទាំង ៥ ឬ ៤ ដូច្នេះហើយ ព្រះយោគីអង្គនោះ ក៏ចូលដល់ថ្នាក់អប្បនាឈាន ហើយចិត្តក៏ធ្លាក់ចុះកាន់ភវង្គវិញ ខាងក្រោយមកអាវជ្ជនចិត្តផ្ដាច់បង់នូវភវង្គ ហើយកើតឡើងដើម្បីពិចារណានូវឈាន តមកទៀត ឈានបច្ចវេក្ខណចិត្ត គឺចិត្តដែលសម្រាប់ពិចារណានូវឈានក៏កើតឡើង ។

---

១- បុគ្គលដែលមានប្រាជ្ញាក្លាត្រាស់ដឹងឆាប់ ។ ២- បុគ្គលដែលមានប្រាជ្ញាទន់ត្រាស់ដឹងយឺតយូរ ។

ធម្មជាតិអ្វីហៅថា “បរិកម្មៈ ឧបចារៈ អនុលោមៈ គោត្រភូ និងអប្បនា”?

កាមាវចរជវន ដែលពិចារណារកនូវអប្បនាហៅថា “បរិកម្ម” ដែលសសៀរចូលទៅជិតក្បែរអប្បនាហៅថា “ឧបចារៈ” ដែលប្រព្រឹត្តទៅតាមនូវបរិកម្មខាងដើមផង ប្រព្រឹត្តទៅតាមនូវអប្បនាខាងចុងផង ហៅថា “អនុលោមៈ” ដែលគ្របសង្កត់នូវកាមាវចរគោត្រ ហើយស្ទុះចូលទៅកាន់មហគ្គតគោត្រ ហៅថា “គោត្រភូ” ធម្មជាតដែលញុំាង សម្បយុត្តធម៌ឲ្យចូលទៅអែបជាប់នៅក្នុងអារម្មណ៍ បានដល់ បិត្តដែលតម្កល់នៅក្នុងឈាន ហៅថា “អប្បនា” ដំណើរ ដែលឧបចារជ្ឈាននិងអប្បនាឈានកើតឡើងយ៉ាងនេះឯង ។

*ចែកឈានតាមលំដាប់នៃសមាបត្តិ*

អប្បនាឈាន បើចែកតាមលំដាប់នៃសមាបត្តិ គឺថ្នាក់ដែលព្រះយោគីតែងចូលទៅជ្រក សម្ងំនៅជាសុខក្នុងបច្ចុប្បន្ននោះមាន ៨ គឺថ្នាក់រូបជ្ឈាន ៤ ហៅថា “រូបសមាបត្តិ” ថ្នាក់អរូបជ្ឈាន ៤ ហៅថា “អរូបសមាបត្តិ” ។

ថ្នាក់រូបជ្ឈាន ៤ គឺ បឋមៈ (ទី១) ១ ទុតិយៈ (ទី ២) ១ តតិយៈ (ទី ៣) ១ បតុត្ថៈ (ទី ៤) ១ តែលោកច្រើនហៅថា "បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន បតុត្ថជ្ឈាន" ដូច្នេះ ថ្នាក់អរូបជ្ឈាន ៤ ក៏ដូចគ្នា តែលោកច្រើនហៅតាមប្រភេទរបស់អារម្មណ៍ថា អាកាសានញ្ចាយតនៈ ។ ល ។ នេវសញ្ញានាសញ្ញាយតនៈ" ដូច្នេះវិញ សូម្បីឧបចារជ្ឈានដែលបានពោលមកហើយថាជាកាមាវចរនោះសោត បើបែកតាមប្រភេទនេះក៏មាន ៨ យ៉ាង ដូចគ្នា តាមសមគួរដល់ឈាននោះៗ បានឈ្មោះថា "ឧបចារៈរបស់បឋមជ្ឈាន ឧបចារៈរបស់ទុតិយជ្ឈាន" ដូច្នេះជាដើម ព្រោះថាមុនដែលឈាននោះៗ នឹងកើតឡើងសុទ្ធតែមានជវន ៣ ឬ ៤ (ឧបចារៈ អនុលោមៈ គោត្រភូ ឬបរិកម្មៈ ឧបចារៈ អនុលោមៈ គោត្រភូ) ដែលជាកាមាវចរលឿនទៅក្នុងបំណែកខាងដើម ដូចគ្នាទាំងរូបជ្ឈានទាំងអរូបជ្ឈាន ហើយជវនទាំងនេះ សុទ្ធតែនៅក្នុងអំណាចរបស់ឧបចារជ្ឈានដោយពិត ។

### *អង្គលះបង់និងអង្គប្រកបនៃរូបជ្ឈាន*

ឈានទាំងនោះមានគ្រឿងបំណាំយ៉ាងដូចម្តេច?

ក្នុងរូបជ្ឈានមានគ្រឿងបំណាំ ដោយអង្គដែលលះបង់បាន និងអង្គដែលប្រកបចូលមកបាន ឯក្នុងអរូបជ្ឈានមានគ្រឿងបំណាំដោយកន្លងនូវអារម្មណ៍ជាន់ក្រោម ហើយតោងយកនូវអារម្មណ៍ជាន់លើបាន តែក្នុងទីនេះនឹងពោលតែក្នុងរូបជ្ឈានប៉ុណ្ណោះ ឯអរូបជ្ឈានមិនបានពោលឡើយ ព្រោះបានពោលមកសព្វគ្រប់ក្នុងអារុប្បកម្មដ្ឋានខាងដើមហើយ ។

អង្គលះបង់និងអង្គប្រកបនៃរូបជ្ឈាននោះៗ ដូចម្តេច?

ក្នុងបឋមជ្ឈានមានអង្គដែលលះបង់បាន ៥ អង្គដែលប្រកបចូលមកបានក៏ ៥ ដូចគ្នា តែនឹងពណ៌នានូវអង្គដែលលះបង់បានជាមុន ។

អង្គដែលលះបង់បានទាំង ៥ នោះគឺ

១- កាមច្ឆន្ទៈ សេចក្តីផ្គងចិត្តចុះក្នុងកិលេសកាម និងវត្ថុកាម ។

២- ព្យាបាទៈ សេចក្តីគំនុំអាឃាតចំពោះអារម្មណ៍មិនជាទីប្រាថ្នា ។

៣- ថីនមិទ្ធៈ សេចក្តីធុញទ្រាន់និងងងុយដ្រប់ ឬជាសេចក្តីប្រអូសកាយប្រអូសចិត្ត ។

៤- ឧទ្ធច្ចកុក្កុច្ចៈ សេចក្តីរាយមាយចិត្តនិងរំខានចិត្ត ឬជាសេចក្តីអណ្តែតអណ្តូងចិត្ត និងក្តៅក្រហាយចិត្ត ។

៥- វិចិកិច្ឆា សេចក្តីសង្ស័យមិនអស់ហើយពីក្នុងចិត្ត ។

អង្គដែលប្រកបចូលមកបាន ៥ នោះគឺ

១- វិតក្កៈ សេចក្តីត្រិះរិះលើកចិត្តដាក់ទៅក្នុងអារម្មណ៍របស់កម្មដ្ឋាន ។

២- វិចារៈ សេចក្តីពិចារណាដុះខាត់នូវអារម្មណ៍របស់កម្មដ្ឋាន ។

៣- បីតិ សេចក្តីអំណរមានកម្លាំងក្លា អាចញ៉ាំងកាយនិងចិត្តឲ្យពេញសព្វទាំងអស់ បានដល់ផរណាបីតិ ។

៤- សុខៈ សេចក្តីស្រួលកាយស្រួលចិត្តអាចកម្ចាត់បង់នូវអាពាធក្នុងកាយនិងចិត្តបាន ។

៥- ចិត្តេកគ្គតា ភាពរបស់ចិត្តដែលមានអារម្មណ៍តែមួយឯកឯង ។

កាលបើព្រះយោគី លះបង់នូវអង្គដែលត្រូវលះបង់ទាំង ៥ ដោយវិក្ខម្ភនប្បហានៈ ហើយញុំាងអង្គដែលត្រូវប្រកបចូលទាំង ៥ ឲ្យកើតឡើងបាន ត្រូវដឹងថា “បឋមជ្ឈានកើតឡើងហើយ” ។

អង្គលះបង់និងអង្គប្រកបទាំងនេះ ជាគូសត្រូវដល់គ្នានិងគ្នាគឺ កាមច្ឆន្ទៈ ជាសត្រូវដល់ ឯកគ្គតា, ព្យាបាទៈ ជាសត្រូវដល់ បីតិ, ថីនមិទ្ធៈ ជាសត្រូវដល់ វិតក្កៈ, ឧទ្ធច្ចកុក្កុច្ចៈ ជាសត្រូវដល់ សុខៈ, វិចិកិច្ឆា ជាសត្រូវដល់ វិចារៈ ។

ដែលបាត់ជាគូសត្រូវនឹងគ្នាយ៉ាងនេះ ព្រោះថាអង្គប៉ែកខាងអកុសលក្តី ប៉ែកខាងកុសលក្តី ដែលអង្គណាមួយនឹងអាចកើតឡើងបាននោះ លុះតែគ្របសង្កត់នូវអង្គដែលជាសត្រូវដល់ខ្លួននោះបាន ។

ក្នុងទុតិយជ្ឈានមានអង្គដែលលះបង់បាន ២ គឺ វិតក្កៈ ១ វិចារៈ ១ មានអង្គដែលប្រកបចូល ៣ គឺ បីតិ ១ សុខៈ ១ ឯកគ្គតា ១ តែបីតិនិងសុខៈ ក្នុងទុតិយជ្ឈាននេះ មានសេចក្តីវិសេសជាងបីតិនិងសុខៈ ក្នុងបឋមជ្ឈាន គឺថា បីតិនិង

សុខៈក្នុងបឋមជ្ឈាន កើតអំពីស្ងាត់ចាកនីវរណធម៌ទាំង ៥ ឯក្នុងទុតិយជ្ឈាននេះ កើតអំពីសមាធិស្ងប់យ៉ាងវិសេសតមកអំពីបឋមជ្ឈាន ។

ក្នុងតតិយជ្ឈានមានអង្គដែលលះបង់បានតែ ១ គឺ បីតិ មានអង្គដែលប្រកបចូល ២ គឺ សុខៈ ១ ចិត្តេកគ្គតា ១ ។

ក្នុងចតុត្ថជ្ឈាន មានអង្គដែលលះបង់បានក៏តែ ១ គឺសុខៈ មានអង្គដែលប្រកបចូល ២ គឺ ឧបេក្ខា ១ ចិត្តេកគ្គតា ១ ឧបេក្ខាក្នុងទីនេះ លោកសំដៅយកឈានុបេក្ខា(១) ដែលព្រងើយនៅក្នុងឈាន មិនធ្លាក់ចុះក្នុងសុខនិងទុក្ខ មាន

---

១- ឧបេក្ខាមាន ១០ យ៉ាងគឺ ឆឡង្គុបេក្ខា ព្រងើយកន្តើយមិនសោមនស្ស-ទោមនស្ស ដោយឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ក្នុងទ្វារទាំងប្រាំមួយ ១ ព្រហ្មវិហារុបេក្ខា ព្រងើយកន្តើយ មានអាការជាយ៉ាងកណ្ដាលក្នុងសត្វទាំងឡាយ ១ ពោជ្ឈង្គុបេក្ខា ព្រងើយកន្តើយមានអាការជាយ៉ាងកណ្ដាល ចំពោះសហជាតធម៌ទាំងឡាយ ១ វីរិយុបេក្ខា ព្រងើយកន្តើយបានដល់ព្យាយាមដែលជាយ៉ាងកណ្ដាលមិនតឹងពេកធូរពេក ១ សង្ខារុបេក្ខា ព្រងើយកន្តើយជាយ៉ាងកណ្ដាលមិនប្រក្លូតប្រកាន់ក្នុងសង្ខារ ១ វេទនូបេក្ខា ព្រងើយកន្តើយមិនសោយអារម្មណ៍ថាជាទុក្ខជាសុខ ១ វិបស្សនូបេក្ខា ព្រងើយកន្តើយជាយ៉ាងកណ្ដាលក្នុងវិបស្សនា ១ តត្រមជ្ឈត្តុបេក្ខា ព្រងើយកន្តើយជាយ៉ាងកណ្ដាលចំពោះសហជាតធម៌ទាំងឡាយ ១ ឈានុ-បេក្ខា ព្រងើយកន្តើយនៅក្នុងឈានមិនធ្លាក់ចុះក្នុងសុខនិងទុក្ខ ១ បរិសុទ្ធុបេក្ខា ព្រងើយកន្តើយបរិសុទ្ធចាកបច្ចនីកធម៌ទាំងពួងមិនមានខ្វល់ខ្វាយនិងរម្ងាប់នូវបច្ចនីកធម៌ទាំងនោះទៀត ១ ។

លក្ខណៈជាកណ្តាលៗ មិនជាប់ចិត្តមិនខ្វល់ខ្វាយដោយសុខ និងទុក្ខ មានសេចក្តីនឿយណាយចាកបីតិ ។

ដែលពោលមកនេះជាឈានចតុក្កន័យ បើជាបញ្ចក្ក-ន័យវិញនោះ តាំងអំពីទុតិយជ្ឈានមក អង្គដែលត្រូវលះបង់បានមានតែមួយៗ ដរាបដល់បញ្ចមជ្ឈាន ឯអង្គដែលត្រូវប្រកបក៏ថយចុះមួយៗ ជាលំដាប់ ។

**វិធីប្រព្រឹត្តកន្លងនូវឈានជាន់ក្រោម ចូលទៅកាន់ឈានជាន់លើ**

កាលដែលព្រះយោគី នឹងប្រព្រឹត្តកន្លងនូវឈានជាន់ក្រោមៗដែលខ្លួនបាននោះ ហើយចូលទៅកាន់ឈានជាន់លើៗទៀតជាលំដាប់ តើត្រូវធ្វើកិច្ចដូចម្តេច? ដោយធម៌អ្វី? សេចក្តីយ៉ាងណា?

កាលព្រះយោគីបានសម្រេច ដល់ឈានជាន់ក្រោមណានីមួយហើយ បើមានប្រាថ្នាដើម្បីចូលទៅកាន់ឈានជាន់លើតតទៅទៀត គប្បីហាត់បង្វឹកនូវឈានជាន់ក្រោមដែលខ្លួនបានហើយនោះ ឲ្យថ្មឹកដោយវសី[១] ទាំង ៨ ជាមុន ដល់

១- ភាពដែលថ្មឹក ឬស្ទាត់ជំនាញ ។

ពេលដែលចេញចាកឈាននោះមកវិញ ត្រូវពិចារណាឲ្យឃើញទោសក្នុងឈានជាន់ក្រោម ឃើញអានិសង្សក្នុងឈានជាន់លើហើយធ្វើទុកក្នុងចិត្តនូវឈានជាន់លើតទៅ ដរាបដល់អប្បនាចិត្តកើតឡើង ។

*វសីទាំង ៥ នោះដូច្នេះគឺ*

១- **អាវជ្ជនវសី** ប្ទឹកក្នុងវិធីនឹករកនូវអង្គរបស់ឈាន ។

២- **សមាបជ្ជនវសី** ប្ទឹកក្នុងវិធីចូលកាន់ឈាន ។

៣- **អធិដ្ឋានវសី** ប្ទឹកក្នុងវិធីទប់ទុកនូវឈាន ។

៤- **វុដ្ឋានវសី** ប្ទឹកក្នុងវិធីចេញចាកឈាន ។

៥- **បច្ចវេក្ខណវសី** ប្ទឹកក្នុងវិធីពិចារណានូវអង្គរបស់ឈាន ។

សេចក្ដីថា : ព្រះយោគីត្រូវការនឹករកនូវឈាន ដែលខ្លួនបានហើយនោះ ទោះបីនឹករកក្នុងប្រទេសណាក្ដី ក្នុងពេលណាក្ដី ត្រង់អង្គណាក្ដី នឹកដល់ត្រឹមណាក្ដី ក៏នឹកបានភ្លាមៗ មួយរំពេចពុំមានយឺតយូរ យ៉ាងនេះ ហៅថាអាវជ្ជនវសី” ។

បើព្រះយោគី ត្រូវការចូលកាន់ឈានដែលបានហើយនោះ ទោះបីចូលក្នុងប្រទេសណាក្តី ក្នុងពេលណាក្តី ចូលដល់ត្រឹមណាក្តី ក៏ចូលបានភ្លាមៗមួយរំពេច ពុំមានយឺតយូរ យ៉ាងនេះហៅថា "សមាបជ្ជនវសី" ។

កាលព្រះយោគីចូលដល់ទៅក្នុងឈានហើយ បើត្រូវការបង់ទប់ទុកនូវឈាននោះ មិនឲ្យប្រព្រឹត្តទៅដោយរហ័ស ក៏អាចទប់ទុក ឲ្យតាំងនៅអស់កាលបំនួនផ្ទាត់ម្រាមដៃម្តង ឬ ២០ ដង យ៉ាងនេះហៅថា "អធិដ្ឋានវសី" ។

ដល់ពេលដែលព្រះយោគី បេញបាកឈាននោះមកវិញ ក៏អាចបេញបានយ៉ាងរហ័ស អស់កាលត្រឹមផ្ទាត់ម្រាមដៃម្តង ឬ ១០ ដងប៉ុណ្ណោះ ក៏អាចបេញមកបាន យ៉ាងនេះហៅថា "វុដ្ឋានវសី" ។

ជវនដែលប្រព្រឹត្តទៅខាងមុខ បន្ទាប់អំពីអាវជ្ជនចិត្តដែលនឹករកនូវអង្គរបស់ឈាន មានវិតក្កៈជាដើមតាមលំដាប់គ្នា ពុំមានយឺតយូរ ដោយភាពដែលថ្មីកក្នុងវិធីនឹក ហៅថា "បច្ចវេក្ខណវសី"ៗ នេះ ប្រព្រឹត្តទៅបន្ទាប់គ្នានឹងអាវជ្ជនវសី ។

ព្រះយោគីដែលដល់នូវបឋមជ្ឈាន ហើយបានហាត់បង្ហឹកឲ្យប៉ិនប្រសប់ដោយវសីទាំង ៥ ដូចពោលមកនេះ បើមានប្រាថ្នានឹងចូលកាន់ទុតិយជ្ឈានតទៅទៀត គប្បីចូលកាន់បឋមជ្ឈានដែលខ្លួនបាននោះជាមុន ដល់ពេលដែលចេញមកវិញ ត្រូវពិចារណាឲ្យឃើញទោសក្នុងបឋមជ្ឈាន ឃើញអានិសង្សក្នុងទុតិយជ្ឈានថា "សមាបត្តិនេះមានសត្រូវគឺនីវរណធម៌នៅជិតពេកណាស់ ហើយអង្គក៏នៅមានកម្លាំងថយព្រោះនៅមានវិតក្កៈនិងវិចារៈដែលជាអង្គដ៏គ្រោតគ្រាតនៅឡើយ ទុតិយ-ជ្ឈានដែលមានតែអង្គ ៣ គឺបីតិនិងសុខៈ និងឯកគ្គតា ទើបស្ងប់ល្អិតសុខុមយ៉ាងវិសេស" ហើយក៏គ្របសង្កត់នូវសេចក្ដីត្រេកអរក្នុងបឋមជ្ឈាននោះ ព្យាយាមធ្វើទុកក្នុងចិត្តរឿយៗនូវនិមិត្តរបស់កម្មដ្ឋាន មានបឋវីកសិណជាដើម តាមឈ្មោះរបស់កម្មដ្ឋាន ដែលខ្លួនចម្រើនបានដល់បឋមជ្ឈាននោះ លះបង់នូវអង្គដែលគ្រោតគ្រាត ធ្វើទុកក្នុងចិត្តតែអង្គដែលល្អិតសុខុម លំដាប់នោះមនោទ្វារាវជ្ជនចិត្ត កាត់ផ្ដាច់នូវភវង្គដោយសង្ឃឹមថា "ទុតិយជ្ឈាននឹងកើតឡើងឥឡូវនេះ"

ក៏តោងយកនិមិត្តរបស់កម្មដ្ឋាននោះៗ មកធ្វើជាអារម្មណ៍ ហើយកើតឡើង ខណៈនោះជវន ៤ ឬ ៥ លឿនទៅក្នុង អារម្មណ៍នោះៗដដែល ជវន ៣ ឬ ៤ ខាងដើមជាកាមាវចរ ជវនទី ៤ ឬទី ៥ ខាងចុងបំផុតជារូបាវចរ គឺជាតួអប្បនាចិត្ត គ្រានោះព្រះយោគីក៏ចូលដល់នូវទុតិយជ្ឈាន ។

កាលបើព្រះយោគី មានប្រាថ្នាដើម្បីប្រព្រឹត្តកន្លងនូវ ទុតិយជ្ឈាន ចូលទៅកាន់តតិយជ្ឈាន ប្រព្រឹត្តកន្លងនូវតតិយ-ជ្ឈានចូលទៅកាន់បតុត្ថជ្ឈាន ក៏គប្បីហាត់បង្វឹកនូវទុតិយជ្ឈាន ឬតតិយជ្ឈានដែលខ្លួនបានហើយនោះឱ្យស្ទាត់ដោយវសី ទាំង ៥ ជាមុនដូចគ្នា ដល់ពេលដែលចេញចាកឈានទោះៗ មក វិញ ត្រូវពិចារណាឱ្យឃើញទោសក្នុងទុតិយជ្ឈានថា "មាន សត្រូវតាំងនៅជិត ព្រោះនៅមានអង្គដែលគ្រោតគ្រាត គឺ បីតិ" ឃើញអានិសង្សក្នុងតតិយជ្ឈានថា "ស្ងប់ល្អិតយ៉ាង វិសេសព្រោះនៅមានតែអង្គ ដែលល្អិតសុខុមគឺសុខៈ និង ឯកគ្គតា" ឃើញទោសក្នុងតតិយជ្ឈានថា "មានសត្រូវតាំង នៅជិតព្រោះនៅមានអង្គដែលគ្រោតគ្រាតគឺសុខៈ" ឃើញ

អានិសង្សក្នុងចតុត្ថជ្ឈានថា “ស្ងប់ល្អិតយ៉ាងវិសេស ព្រោះនៅមានតែអង្គដែលល្អិតសុខុមគឺឧបេក្ខានិងចិត្តេកគ្គតា” ហើយគប្បីព្យាយាមធ្វើទុកក្នុងចិត្តឲ្យរឿយៗ នូវនិមិត្តរបស់កម្មដ្ឋានដែលខ្លួនបម្រើនបានដល់ថ្នាក់ឈានទាំងនោះ កំណាត់លះបង់នូវអង្គដែលគ្រោតគ្រាត ធ្វើទុកក្នុងចិត្តតែអង្គដែលល្អិតសុខុមដរាបដល់អប្បនាចិត្តកើតឡើង គ្រានោះព្រះយោគីក៏ចូលដល់នូវតតិយជ្ឈាន ឬចតុត្ថជ្ឈាន តាមលំដាប់នៃជវន ៤ ឬ ៥ ដួងពោលមកហើយ ។

ឈានកថាចប់

សមាធិភាវនានិសំសកថា

បន្ទាប់អំពីឈានកថាមក នឹងពណ៌នានូវអានិសង្សនៃសមាធិភាវនាដោយសេចក្តីសង្ខេបតទៅ ។

សមាធិភាវនាមានអានិសង្សប៉ុន្មានយ៉ាង? អ្វីខ្លះ? អធិប្បាយដូចម្តេច?

សមាធិភាវនាមានអានិសង្ស ៥ យ៉ាងគឺ

១- **ទិដ្ឋធម្មសុខវិហារានិសំសា** អប្បនាសមាធិភាវនា

មានកិរិយានៅជាសុខក្នុងបច្ចុប្បន្នជាអានិសង្ស ។

អធិប្បាយ : ព្រះខីណាស្រពទាំងឡាយ កាលបើមានប្រាថ្នាដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ហើយចម្រើននូវសមាធិចូលទៅកាន់ឈានមានចិត្តតម្កល់នៅឯកឯង ក្នុងអារម្មណ៍តែ ១ លោកក៏បានជៀសចេញចាកអារម្មណ៍ផ្សេងៗ សម្ងំនៅជាសុខអស់ថ្ងៃ ១ បាន ។

២- **វិបស្សនានិសំសា** ទាំងអប្បនាសមាធិភាវនាទាំងឧបចារសមាធិភាវនា សុទ្ធតែមានវិបស្សនាជាអានិសង្សដូចគ្នា ។

អធិប្បាយ : សេខបុគ្គលនិងបុថុជ្ជន កាលបើចេញចាកអំពីសមាបត្តិមក កំពុងមានចិត្តតម្កល់នៅមាំ ហើយពិចារណានូវវិបស្សនា ក៏នឹងបានដឹងច្បាស់នូវធម៌ដែលពិតព្រោះសមាធិភាវនា ជាបទដ្ឋាននៃវិបស្សនា ។

៣- **អភិញ្ញានិសំសា** អប្បនាសមាធិភាវនា មានអភិញ្ញាជាអានិសង្ស ។

អធិប្បាយ : ព្រះយោគីទាំងឡាយ ដែលញ៉ាំងសមាបត្តិទាំង ៨ ឲ្យកើតឡើងបាន វេលាដែលចេញចាកសមាបត្តិមកវិញ បើមានប្រាថ្នាដើម្បីញ៉ាំងអភិញ្ញាឲ្យកើតឡើងបាន ។

៤- **ភវវិសេសានិសំសា** សមាធិភាវនាទាំង ២ មានសម្បត្តិយ៉ាងវិសេសនៅក្នុងភពជាអានិសង្ស ។

អធិប្បាយ : អប្បនាសមាធិភាវនា នាំមកនូវសម្បត្តិយ៉ាងវិសេសក្នុងព្រហ្មលោក គឺថាព្រះយោគីដែលចម្រើនបានដល់ថ្នាក់បឋមជ្ឈានជាដើមហើយ បើមិនបានសាបសូន្យចាកឈានទាំងនោះទេ ទុកណាជាប្រាថ្នាក្តី មិនប្រាថ្នាក្តី ដល់ពេលដែលធ្វើកាលកិរិយាទៅ ក៏គង់នឹងទៅកើតក្នុងព្រហ្មលោកជាប្រាកដ ឯឧបចារសមាធិភាវនា នាំមកនូវសម្បត្តិយ៉ាងវិសេសក្នុងកាមាវចរសុគតិភពទាំង ៦ ជាន់ ។

៥- **និរោធានិសំសា** អប្បនាសមាធិភាវនា មាននិរោធជាអានិសង្ស ។

អធិប្បាយ : ព្រះអរិយបុគ្គលទាំងឡាយ កាលបើញ៉ាំង

សមាបត្តិទាំង ៨ ឲ្យកើតឡើង ហើយចូលកាន់និរោធសមាបត្តិ ក៏នឹងបានដល់នូវនិរោធនិព្វាន មានសភាពជាបុគ្គលមិនមានចិត្ត គង់នៅជាសុខក្នុងបច្ចុប្បន្នអស់ថ្ងៃ ៧ បាន ។

សមាធិភាវនានិសំសកថាចប់

## អភិញ្ញាកថា

លំដាប់នេះនឹងពណ៌នានូវអភិញ្ញា ដែលជាអានិសង្ស ទី ៣ របស់សមាធិភាវនា ដោយសង្ខេបតទៅ ដើម្បីញុំាងព្រះយោគីដែលជាអ្នកបម្រើនូវសមាធិ ឲ្យកាន់តែមានសេចក្តីពេញចិត្តជាភិយ្យោភាពឡើងទៀត ដោយបានឃើញនូវអានិសង្សដែលជាអស្ចារ្យគួរប្រាថ្នា ។

ក៏អភិញ្ញានេះ ក្នុងទីដទៃលោកពោលទុកទាំងលោកិយទាំងលោកុត្តរជា ៦ យ៉ាង ឯក្នុងទីនេះ លោកពោលទុកតែ ៥ យ៉ាង ព្រោះលោកសំដៅយកតែអភិញ្ញាជាលោកិយ ដែលជាអានិសង្សរបស់សមាធិភាវនាប៉ុណ្ណោះ ឯអភិញ្ញាដែលជាលោកុត្តរ លោកមិនបានពោលទុកក្នុងទីនេះឡើយ ព្រោះជាអានិសង្សរបស់វិបស្សនាភាវនា ។

អភិញ្ញាជាលោកិយ ៥ យ៉ាងនោះគឺ

១- **ឥទ្ធិវិធញ្ញាណ** ប្រាជ្ញាអាចបេះប្លែងឫទ្ធិគ្រប់ប្រការបាន ។

២- **ទិព្វសោតធាតុញ្ញាណ** ប្រាជ្ញាអាចស្តាប់ដឹងបាននូវសំឡេងរបស់មនុស្ស និងសំឡេងរបស់ទេវតាដោយសោតធាតុដែលប្រាកដដូចជាទិព្វ ។

៣- **បេតោបរិយញ្ញាណ** ប្រាជ្ញាអាចកំណត់ដឹងបាននូវទឹកចិត្តនៃអ្នកដទៃ ។

៤- **បុព្វេនិវាសានុស្សតិញ្ញាណ** ប្រាជ្ញាអាចរឭកបាននូវខន្ធបញ្ចកៈដែលធ្លាប់នៅអាស្រ័យក្នុងកាលមុន ។

៥- **សត្តានំ បុត្តូបបាតញ្ញាណ** ប្រាជ្ញាអាចដឹងបាននូវចុតិនិងបដិសន្ធិរបស់សត្វ ។

អភិញ្ញាជាគម្រប់ ៦ ដែលជាលោកុត្តរ ហើយលោកមិនបាននាំយកមកពោលទុកក្នុងនិទ្ទេស នៃសមាធិភាវនានេះនោះគឺ អាសវក្ខយញ្ញាណ បានដល់ប្រាជ្ញាដែលអាចញ៉ាំងអាសវៈឲ្យក្ស័យទៅបាន តែអាសវក្ខយញ្ញាណនេះ គ្រាន់តែ

ទាញយកមកបង្អួលបង្ហាញឲ្យឃើញប៉ុណ្ណោះ តទៅមិនបាន អធិប្បាយថែមទៀតឡើយ ព្រោះមិនមែនជាលំអានដែលត្រូវ អធិប្បាយក្នុងទីនេះ នឹងអធិប្បាយតែអភិញ្ញាដែលជាលោកិយ ៥ ខាងដើមប៉ុណ្ណោះឯង ។

អធិប្បាយក្នុងអភិញ្ញាទី ១- ឥទ្ធិវិធញ្ញាណ

ក្នុងឥទ្ធិវិធញ្ញាណទី ១ នេះ កាលបើព្រះយោគីបានហើយ ក៏អាចដើម្បីនឹងប្លែងនូវឫទ្ធិផ្សេងៗបាន ទោះបីព្រះយោគី តែម្នាក់ឯងហើយប្លែងខ្លួនឲ្យទៅជាច្រើននាក់ ដល់ ១ រយ ១ ពាន់នាក់ហើយសុទ្ធតែប្រារព្ធនូវអំពើផ្សេងៗ គ្នា ខ្លះប្រារព្ធ ដើម្បីសួរនូវប្រស្នា ខ្លះប្រារព្ធដើម្បីឆ្លើយនូវប្រស្នាជាដើម ពុំ នោះច្រើននាក់ប្លែងខ្លួនឲ្យទៅជាម្នាក់ឯងវិញក៏សឹងតែបាន កុំថា តែប៉ុណ្ណោះឡើយ ទោះបីព្រះយោគីអង្គនោះមានប្រាថ្នាដើម្បី មុជជ្រែកផែនដី ដើរលើទឹក ហោះទៅតាមអាកាស សម្តែង ឲ្យឃើញជាដំរី សេះ កងសេនាជាដើមឰដ៏អាកាស ក៏សឹង តែធ្វើបានដូចសេចក្តីប្រាថ្នាទាំងអស់ ។

ព្រះយោគីដែលជាអាទិកម្មិកៈ កាលបើមានប្រាថ្នាដើម្បីប្លែងនូវឫទ្ធិបែបណានីមួយដូចពោលមកហើយ គប្បីញ៉ាំងសមាបត្តិទាំង ៨ ឲ្យកើតឡើងក្នុងកសិណទាំង ៨ មានបឋវីកសិណជាដើមមានឱទាតកសិណជាទីបំផុត ហាត់បង្វឹកបិត្តឲ្យប៉ិ្នកជាមុនសិន ហើយសឡឹមអធិដ្ឋាននូវឫទ្ធិតាមដែលខ្លួនប្រាថ្នានោះជាខាងក្រោយ ទើបអាចនឹងសម្រេចដូចសេចក្តីបំណងបាន ។

ត្រូវហាត់បង្វឹកបិត្តយ៉ាងដូចម្តេច?

ត្រូវហាត់បង្វឹកដោយអាការ ១៤ យ៉ាងដូច្នេះគឺ

១- កសិណានុលោម ត្រូវចូលកាន់ឈានបណ្តោយទៅតាមលំដាប់នៃកសិណទាំង ៨ មានបឋវីកសិណជាដើមមានឱទាតកសិណជាទីបំផុត ។

២- កសិណបដិលោម ត្រូវចូលកាន់ឈានសាប្រាសឡើងមកវិញតាមលំដាប់នៃកសិណទាំង ៨ គឺចូលតាំងអំពីឱទាតកសិណ សាឡើងមកដរាបដល់បឋវីកសិណ ។

៣- កសិណានុលោមបដិលោម ត្រូវចូលកាន់ឈាន

បណ្ដោយទៅតាមលំដាប់នៃកសិណទាំង ៨ ហើយចូលសាឡើងមកវិញ ដរាបដល់បឋវីកសិណជាខាងដើមបំផុត ។

៤- ឈានានុលោម ត្រូវចូលកាន់ឈានបណ្ដោយទៅតាមលំដាប់នៃរូបជ្ឈានទាំង ៤ និងអរូបជ្ឈានទាំង ៤ ។

៥- ឈានបដិលោម ត្រូវចូលកាន់ឈានសាប្រាសឡើងមកវិញ តាំងអំពីខាងចុងបំផុត ដរាបមកដល់ខាងដើមបំផុត ។

៦- ឈានានុលោមបដិលោម ត្រូវចូលកាន់ឈានបណ្ដោយទៅតាមលំដាប់នៃឈាន ដរាបដល់ទីបំផុតខាងចុង ហើយសាប្រាសឡើងមកវិញ ដរាបដល់ទីបំផុតខាងដើម ។

៧- ឈានុក្កន្តក ត្រូវចូលផ្លោះរំលងឈានតែក្នុងកសិណដដែល គឺចូលកាន់បឋមជ្ឈានក្នុងបឋវីកសិណ ហើយផ្លោះរំលងទៅចូលដល់តតិយជ្ឈានតែម្ដង ក្នុងបឋវីកសិណដដែល បើកនូវបឋវីកសិណចូលទៅកាន់អាកាសានញ្ចាយតនៈ ហើយផ្លោះរំលងទៅចូលដល់អាកិញ្ចញ្ញាយតនៈតែម្ដង ត្រូវចូលផ្លោះរំលងឈានយ៉ាងនេះ គ្រប់កសិណទាំង ៨ ។

៨- កសិណុក្កន្តក ត្រូវចូលកាន់ឈានដដែល តែផ្លោះរំលងកសិណ គឺត្រូវចូលកាន់បឋមជ្ឈាន ក្នុងបឋវីកសិណ ហើយផ្លោះរំលងទៅដល់តេជោកសិណ នីលកសិណ លោហិតកសិណ តែចូលកាន់តែបឋមជ្ឈានដដែល ចូលកាន់ទុតិយជ្ឈានជាដើម ក៏ត្រូវផ្លោះរំលងកសិណបែបនេះដូចគ្នា ។

៩- ឈានកសិណុក្កន្តក ត្រូវចូលផ្លោះរំលងទាំងឈានទាំងកសិណ គឺត្រូវចូលកាន់បឋមជ្ឈានក្នុងបឋវីកសិណ ចូលកាន់តតិយជ្ឈានក្នុងតេជោកសិណ បើកនូវនីលកសិណ ចូលកាន់អាកាសានញ្ចាយតនៈ ហើយចូលកាន់អាកិញ្ចញ្ញាយតនៈ ខាងមុខអំពីលោហិតកសិណ ។

១០- អង្គសង្កន្តិក ត្រូវប្រព្រឹត្តកន្លងនូវអង្គ គឺត្រូវចូលរៀងទៅតាមលំដាប់របស់ឈាន មានបឋមជ្ឈានជាដើម តែក្នុងកសិណនីមួយៗ ។

១១- អារម្មណសង្កន្តិក ត្រូវប្រព្រឹត្តកន្លងនូវអារម្មណ៍ គឺត្រូវចូលកាន់ឈាននីមួយៗ ឲ្យបានគ្រប់កសិណទាំង ៨ ។

១២- អង្គារម្មណសង្កន្តិក ត្រូវប្រព្រឹត្តកន្លងទាំង

អង្គទាំងអារម្មណ៍ គឺត្រូវចូលកាន់បឋមជ្ឈានក្នុងបឋវីកសិណ ចូលកាន់ទុតិយជ្ឈានក្នុងអាបោកសិណ ចូលកាន់តតិយជ្ឈានក្នុងតេជោកសិណ ចូលកាន់ចតុត្ថជ្ឈានក្នុងវាយោកសិណ បើកនូវនីលកសិណ ចូលកាន់អាកាសានញ្ចាយតនៈ ចូលកាន់វិញ្ញាណញ្ចាយតនៈខាងមុខអំពីបីតកសិណ ចូលកាន់អាកិញ្ចញ្ញាយតនៈខាងមុខអំពីលោហិតកសិណ ចូលកាន់នេវសញ្ញានាសញ្ញាយតនៈខាងមុខអំពីឱទាតកសិណ ។

១៣- អង្គវវដ្ឋាបន ត្រូវកំណត់នូវអង្គ គឺត្រូវកំណត់ឲ្យដឹងថា "បឋមជ្ឈានមានអង្គ ៥ ទុតិយជ្ឈានមានអង្គ ៣ តតិយជ្ឈានមានអង្គ ២ ព្រមទាំងចតុត្ថជ្ឈាននិងអរូបជ្ឈានទាំង ៤ ក៏មានអង្គ ២ ដូចគ្នា" ។

១៤- អារម្មណវវដ្ឋាន ត្រូវកំណត់នូវអារម្មណ៍ គឺត្រូវកំណត់ឲ្យដឹងថា "បែបនេះបឋវីកសិណ បែបនេះអាបោកសិណជាដើម" ។

កាលបើព្រះយោគី បានហាត់បង្វឹកចិត្តឲ្យប៉ិនដោយអាការទាំង ១៤ យ៉ាងនេះហើយ បើមានប្រាថ្នាដើម្បីបង្អោន

ចិត្តទៅកាន់ឫទ្ធិឯណានីមួយ ក៏អាចដើម្បីនឹងញុំាងឫទ្ធិនោះឲ្យកើតឡើងបានជាប្រាកដ ។

*អ្វីដែលលោកហៅថា "ឫទ្ធិ"? មានប៉ុន្មានយ៉ាង? អ្វីខ្លះ? ក្នុងឥទ្ធិវិធញាណនេះ លោកសំដៅយកឫទ្ធិណាខ្លះ?*

ធម្មជាតិដែលសម្រេចបានដូចសេចក្ដីប្រាថ្នា លោកហៅថា "ឫទ្ធិ" ។ នេះ បើពោលដោយរួបរួមទាំងអស់ មាន ១០ យ៉ាងគឺ

១- **អធិដ្ឋានា ឥទ្ធិ** ឫទ្ធិសម្រេចដោយអធិដ្ឋានគឺតួព្រះយោគីតែម្នាក់ ហើយអធិដ្ឋានឲ្យទៅជា ១ រយ ១ ពាន់នាក់ជាដើមបាន ។

២- **វិកុព្វនា ឥទ្ធិ** ឫទ្ធិអាចផ្លាស់ភេទជាប្រក្រតីឲ្យទៅជាភេទដទៃបាន គឺបើព្រះយោគីមានប្រាថ្នាដើម្បីប្លែងខ្លួនជាកុមារតូច ជានាគ ជាគ្រុឌ ជាកងទ័ពជាដើមក៏សឹងតែបាន ។

៣- **មនោមយា ឥទ្ធិ** ឫទ្ធិជាវិការនៃចិត្ត គឺថាបើព្រះយោគី មានប្រាថ្នាដើម្បីអធិដ្ឋានចិត្តឲ្យទៅជាមានរូបក៏អាចអធិដ្ឋានកាយជាប្រក្រតីឲ្យទៅជាប្រហោង ហើយ

អធិដ្ឋានចិត្ត ឲ្យទៅជាកាយដទៃចេញមកអំពីកាយជាប្រក្រតី ហាក់ដូចជាពស់លូនចេញមកអំពីជបជាដើមបាន ។

៤- **ញាណវិប្ផារា ឥទ្ធិ** ឫទ្ធិដែលផ្សាយចេញមកអំពីអរហត្តមគ្គញាណរបស់សត្វដែលកើតក្នុងបច្ឆិមភព គឺឧបនិស្ស័យនៃព្រះអរហត្ត បើមាននៅក្នុងសន្តានរបស់សត្វណាក៏អាចជួយការពារជីវិតសត្វនោះ មិនឲ្យអន្តរាយដោយហេតុផ្សេងៗ បាន ដូចជាព្រះសង្កិច្ចត្ថេរ ។

៥- **សមាធិវិប្ផារា ឥទ្ធិ** ឫទ្ធិដែលផ្សាយចេញមកអំពីសមាធិ របស់លោកអ្នកចូលកាន់សមាបត្តិ អាចជួយការពារនូវអន្តរាយផ្សេងៗ បាន ដូចជាព្រះសារីបុត្តត្ថេរជាដើម ។

៦- **អរិយា ឥទ្ធិ** ឫទ្ធិដែលកើតចំពោះតែព្រះអរិយ ដែលលោកបានដល់នូវភាពដែលប្ដឹកក្នុងចិត្ត អាចផ្សាយនូវមេត្តាព្រហ្មវិហារ ឬធ្វើទុកក្នុងចិត្តថាជាធាតុ ក្នុងវត្ថុដែលជាបដិកូលឲ្យទៅជាមិនបដិកូលវិញបាន ពុំនោះផ្សាយអសុភសញ្ញា ឬធ្វើទុកក្នុងចិត្តថាមិនទៀង ក្នុងវត្ថុដែលមិនបដិកូលឲ្យទៅជាបដិកូលវិញក៏បាន ។

៧- **កម្មវិបាកជា ឥទ្ធិ** ឫទ្ធិដែលកើតអំពីកម្មវិបាក អាចឱ្យហោះ ហើរដើរតាមអាកាសបាន មិនបាច់មានឈានសមាបត្តិអ្វីឡើយ ដូចសត្វបក្សីទាំងអស់ ទេវតាទាំងអស់ មនុស្សក្នុងបឋមកប្ប និងវិនិបាតិកៈពួកខ្លះ ។

៨- **បុញ្ញវតោ ឥទ្ធិ** ឫទ្ធិរបស់បុគ្គលអ្នកមានបុណ្យ អាចឱ្យធ្វើដំណើរតាមអាកាសជាដើមបាន ដូចស្តេចបរមចក្រពត្តិ ព្រះអង្គគ្រាន់តែទ្រង់ព្រះសុពណ៌បាទ ក៏អាចហោះទៅតាមអាកាសបាន ព្រមទាំងចតុរង្គិនីសេនា ពុំនោះដូចឫទ្ធិរបស់ជោតិកសេដ្ឋីជាដើម ។

៩- **វិជ្ជាមយា ឥទ្ធិ** ឫទ្ធិដែលសម្រេចអំពីមន្តវិជ្ជា ដូចឫទ្ធិរបស់បុគ្គលអ្នកទ្រទ្រង់នូវមន្តវិជ្ជា (ពិទ្យាធរ) គ្រាន់តែរាយមន្ត ក៏អាចហោះទៅកាន់អាកាស សម្តែងឱ្យឃើញជាដំរី ជាសេះ ជាកងសេនាផ្សេងៗ បាន ។

១០- **តត្ថ តត្ថ សម្មាបយោគបច្ចយា ឥជ្ឈនដ្ឋេន ឥទ្ធិ** ឫទ្ធិសម្រេច ព្រោះបច្ច័យដែលប្រកបព្យាយាមត្រូវល្អ ក្នុងការងារនោះៗ ដូចសិប្បកម្មនិងវេជ្ជកម្មខ្លះដែលបុគ្គលប្រកបព្យាយាម

ត្រូវល្អ ពុំនោះដូចរៀនត្រៃវេទ រៀនព្រះត្រៃបិដក ឬយ៉ាងហោចត្រឹមតែរៀនភ្ជួររាស់ជាដើម ក៏គង់ញ៉ាំងប្រយោជន៍ឱ្យសម្រេចទៅតាមថ្នាក់បាន ។

បណ្ដាឫទ្ធិទាំង ១០ យ៉ាងនេះ ឫទ្ធិដែលលោកសំដៅយកក្នុងឥទ្ធិវិធញ្ញាណ ជាអភិញ្ញាទី ១ នេះ តែឫទ្ធិ ៣ យ៉ាងគឺ **អធិដ្ឋានា ឥទ្ធិ** ១ **វិកុព្វនា ឥទ្ធិ** ១ **មនោមយា ឥទ្ធិ** ១ ប៉ុណ្ណោះ ឫទ្ធិក្រៅអំពីនេះ លោកមិនបានរាប់ថាជាអភិញ្ញាឡើយ ។

*អើក៏! ក្នុងឫទ្ធិទាំង ៣ យ៉ាងនេះ **អធិដ្ឋានា ឥទ្ធិ**ទី ១ សេចក្ដីថា ព្រះយោគីតែម្នាក់ឯង អាចអធិដ្ឋានឱ្យទៅជាច្រើននាក់ដល់ ១ រយ ១ ពាន់នាក់បាន ឬច្រើននាក់អធិដ្ឋានឱ្យនៅតែម្នាក់វិញបាន ត្រូវអធិដ្ឋានដូចម្ដេច?*

ដើមដំបូងត្រូវញ៉ាំងធម៌ដែលជាភូមិរបស់ឫទ្ធិ ៤ យ៉ាង ដែលជាជើងរបស់ឫទ្ធិ ៤ យ៉ាង ដែលជាជំហានរបស់ឫទ្ធិ ៨ យ៉ាង ដែលជាមូលរបស់ឫទ្ធិ ១៦ យ៉ាង ឱ្យសម្រេចជាមុនសិន ហើយសង្កឹមអធិដ្ឋានដោយញាណជាខាងក្រោយ ទើបអាចសម្រេចឫទ្ធិតាមសេចក្ដីប្រាថ្នាបាន ។

ធម៌ដែលជាភូមិរបស់ឫទ្ធិ ៤ យ៉ាងគឺ

១- បឋមជ្ឈាន ឈ្មោះថាវិវេកជភូមិ គឺភូមិដែលកើតអំពីកាយវិវេកនិងចិត្តវិវេក ។

២- ទុតិយជ្ឈាន ឈ្មោះថាបីតិសុខភូមិ គឺភូមិដែលមានតែបីតិសុខ ។

៣- តតិយជ្ឈាន ឈ្មោះថាឧបេក្ខាសុខភូមិ គឺភូមិដែលមានតែឧបេក្ខានិងសុខ ។

៤- ចតុត្ថជ្ឈាន ឈ្មោះថាអទុក្ខមសុខភូមិ គឺភូមិដែលមិនមានទាំងទុក្ខវេទនាទាំងសុខវេទនា ។

ធម៌ដែលជាជើងរបស់ឫទ្ធិ ៤ យ៉ាង គឺ

១- ឆន្ទសមាធិ សមាធិមានឆន្ទជាអធិបតី គឺសមាធិដែលព្រះយោគីបម្រើនបាន ព្រោះអាស្រ័យយកឆន្ទជាធំ ។

២- វីរិយសមាធិ សមាធិមានវីរិយជាអធិបតី គឺសមាធិដែលព្រះយោគីបម្រើនបាន ព្រោះអាស្រ័យយកវីរិយជាធំ ។

៣- ចិត្តសមាធិ សមាធិមានចិត្តជាអធិបតី គឺសមាធិដែលព្រះយោគីបម្រើនបាន ព្រោះអាស្រ័យយកចិត្តជាធំ ។

៤- វីមំសាសមាធិ សមាធិមានវីមំសាគឺប្រាជ្ញាជាអធិបតី គឺសមាធិដែលព្រះយោគីបម្រើនបាន ព្រោះអាស្រ័យយកប្រាជ្ញាជាធំ ។

ជំហានរបស់ឫទ្ធិ ៨ យ៉ាងនោះ លោកបែកទុកជាគូៗដូច្នេះគឺ ឆន្ទនិងសមាធិជាគូ ១ វីរិយនិងសមាធិជាគូ ១ ចិត្តនិងសមាធិជាគូ ១ វីមំសានិងសមាធិជាគូ ១ ផ្សំទាំងអស់ត្រូវជា ៨ ហៅថា "ជំហានរបស់ឫទ្ធិ" ។

មូលរបស់ឫទ្ធិ ១៦ យ៉ាងគឺ

១- **អនោនតំ ចិត្តំ** ចិត្តមិនឱនចុះដោយកោសជ្ជ ។

២- **អនុន្នតំ ចិត្តំ** ចិត្តមិនខ្ពស់ឡើងដោយឧទ្ធច្ច ។

៣- **អភិនតំ ចិត្តំ** ចិត្តមិនប្រាលដោយរាគ(១) ។

៤- **អនុបនតំ ចិត្តំ** ចិត្តមិនប្រាសចេញដោយព្យាបាទ

៥- **អនិស្សិតំ ចិត្តំ** ចិត្តមិនអាស្រ័យនៅដោយទិដ្ឋិ ។

៦- **អប្បដិពទ្ធំ ចិត្តំ** ចិត្តមិនប្រតិពទ្ធដោយឆន្ទរាគ(១)

---

១-២- រាគនិងឆន្ទរាគជាតួកិលេសតែ ១ តែរាគជាកិលេសយ៉ាងស្តើងគ្រាន់តែជាប់នៅក្នុងអារម្មណ៍ដែលមកដល់ហើយប៉ុណ្ណោះ ឯឆន្ទរាគជាកិលេសយ៉ាងក្រាសអាចជាប់នៅក្នុងអារម្មណ៍ដែលនៅក្នុងទីឆ្ងាយបាន ។

៧- **វិប្បមុត្តំ ចិត្តំ** ចិត្តផុតស្រឡះបាកកាមរាគ ។

៨- **វិសំយុត្តំ ចិត្តំ** ចិត្តប្រាសស្រឡះបាកសង្កិលេស-ធម៌និងយោគធម៌ ។

៩- **វិមរិយាទិកតំ ចិត្តំ** ចិត្តដែលព្រះយោគីប្រតិបត្តិធ្វើមិនឲ្យមានទីទំនប់ គឺកិលេសសូម្បីបន្តិចបន្តួច ។

១០- **ឯកត្តគតំ ចិត្តំ** ចិត្តដែលដល់នូវភាពតែម្នាក់ឯង គឺចិត្តដែលតម្កល់នៅមាំមិនកម្រើកដោយកិលេស មានសភាពផ្សេងៗ ។

១១- **សទ្ធាយ បរិគ្គហិតំ ចិត្តំ** ចិត្តដែលព្រះយោគីឃុំគ្រងដោយសទ្ធា មិនកម្រើកដោយអស្សទ្ធិយ គឺភាពដែលមិនជឿ ។

១២- **វីរិយេន បរិគ្គហិតំ ចិត្តំ** ចិត្តដែលព្រះយោគីឃុំគ្រងដោយវីរិយ មិនកម្រើកដោយកោសជ្ជ ។

១៣- **សតិយា បរិគ្គហិតំ ចិត្តំ** ចិត្តដែលព្រះយោគីឃុំគ្រងដោយសតិ មិនកម្រើកដោយបមាទ ។

១៤- **សមាធិនា បរិគ្គហិតំ ចិត្តំ** ចិត្តដែលព្រះយោគី

ឃុំគ្រងដោយសមាធិ មិនកម្រើកដោយឧទ្ធច្ច ។

១៥- **បញ្ញាយ បរិគ្គហិតំ ចិត្តំ** ចិត្តដែលព្រះយោគី ឃុំគ្រងដោយបញ្ញា មិនកម្រើកដោយអវិជ្ជា ។

១៦- **ឱភាសគតំ ចិត្តំ** ចិត្តដែលដល់នូវឱភាសគឺចិត្តដែលភ្លឺស្វាង មិនកម្រើកដោយអវិជ្ជន្ធការ ។

កាលបើព្រះយោគី បានញុំាងធម៌ដែលជាភូមិ ជាជើង ជាជំហាន ជាមូលរបស់ឫទ្ធិទាំងអម្បាលនេះឲ្យសម្រេចសព្វគ្រប់ហើយ ដល់វេលាដែលចូលកាន់បតុត្ថជ្ឈាន ហើយចេញមកវិញ បើមានប្រាថ្នាដើម្បីអធិដ្ឋានខ្លួនដែលតែម្នាក់ឯងឲ្យទៅជា ១ រយ ១ ពាន់នាក់ គប្បីធ្វើបរិកម្មថា “**សតំ ហោមិ សតំ ហោមិ** អញទៅជា ១ រយនាក់ៗ” ឬបរិកម្មថា “**សហស្សំ ហោមិ សហស្សំ ហោមិ** អញទៅជា ១ ពាន់នាក់ៗ” ដូច្នេះ ហើយត្រឡប់ចូលកាន់បតុត្ថជ្ឈានម្តងទៀត ដល់ចេញមកវិញ គប្បីអធិដ្ឋានឲ្យទៅជា ១ រយ ឬ ១ ពាន់នាក់ ដោយញាណដែលជាតួអភិញ្ញា លំដាប់នោះអត្តភាព ១ រយនាក់ ឬ ១ ពាន់នាក់ ក៏កើតឡើងដំណាលគ្នានឹងចិត្តដែលអធិដ្ឋាននោះឯង ។

វិធីអធិដ្ឋានធ្វើអត្តភាពច្រើនឲ្យតិច ធ្វើវត្ថុដែលមិនកំបាំងឲ្យកំបាំង ដែលកំបាំងឲ្យមិនកំបាំង ដែលប្រាកដឲ្យមិនប្រាកដ ដែលមិនប្រាកដឲ្យប្រាកដ ដើរទម្លាយជញ្ជាំង ទម្លាយកំផែង ទម្លាយភ្នំ មិនមានទើសទាល់ មុជជ្រែកផែនដី ដើរលើទឹក បណ្តែតខ្លួនទៅតាមអាកាសទាំងព្នែន ទាំងជំ-ណោក ទាំងបង្គុយ អធិដ្ឋានធ្វើឲ្យព្រះចន្ទ្រ ព្រះអាទិត្យមកប្រតិស្ឋានក្នុងហត្ថបាសហើយស្ទាបអង្អែលដោយដៃ ហោះទៅកាន់ទេវលោកឬព្រហ្មលោកទាំងកាយ អធិដ្ឋានធ្វើទីឆ្ងាយឲ្យជិត ទីជិតឲ្យឆ្ងាយ ធ្វើទរទឹកនិងទរភ្លើងឲ្យប្រព្រឹត្តទៅជាគូៗ(១) ជាដើម ក៏មានន័យប្រហែលៗគ្នា ប្លែកគ្នាតែវិធីដែលប្រើកសិណប៉ុណ្ណោះឯង ។

*ត្រង់វិធីដែលសម្តែងថា "ហោះទៅកាន់ទេវលោកនិងព្រហ្មលោកទាំងកាយបាន" នោះតើហោះទៅដោយប្រការដូចម្តេច? ត្រង់នេះមុខគួរឲ្យសង្ស័យពេកណាស់ ។*

---

**១- វិធីដែលអធិដ្ឋានធ្វើទរទឹកនិងភ្លើងឲ្យប្រព្រឹត្តទៅជាគូៗនេះ ធ្វើបានចំពោះតែព្រះពុទ្ធ មិនទូទៅដល់សាវកដទៃឡើយ ។**

អើ! គួរឲ្យសង្ស័យមែនហើយ ព្រោះក្នុងសម័យនេះមិនដែលឃើញមានចំពោះភ្នែក តែថានេះហើយជាវិស័យរបស់អ្នកមានឫទ្ធិ ធម្មតាអ្នកមានឫទ្ធិអាចហោះទៅកាន់ទីណាៗទាំងកាយដែលប្រាកដដល់ភ្នែកអ្នកទាំងពួងក៏បាន ដែលមិនប្រាកដដល់ភ្នែកអ្នកទាំងពួងក៏បាន វេលាណាដែលលោកមានប្រាថ្នាដើម្បីហោះទៅទាំងកាយ ដែលប្រាកដដល់ភ្នែកអ្នកទាំងពួង លោកបង្អោនចិត្តឲ្យលុះក្នុងអំណាចកាយ លើកយកឈានចិត្តដាក់ទៅក្នុងកាយ ធ្វើដំណើរចិត្តឲ្យយឺតយូរទៅតាមកាយ ហើយលោកចូលកាន់សុខសញ្ញាដែលសម្បយុត្តដោយឧបេក្ខា និងលហុសញ្ញាដែលផុតស្រឡះចាកនីវរណធម៌ និងបច្ចនីកធម៌មានវិតក្កជាដើម ដែលកើតព្រមដោយចិត្តដែលប្រកបដោយឫទ្ធិរបស់លោក លំដាប់នោះកាយរបស់លោកក៏ស្រាលដូចជាប៉ុយគ ហើយលោកអាចហោះទៅបានដូចជាប៉ុយគដែលខ្យល់ផើយឡើង ដោយចូលកាន់វាយោកសិណ ពុំនោះលោកចូលកាន់បឋវីកសិណ និម្មិតជាផ្លូវពួងអាកាស ហើយយាងទៅដោយព្រះបាទក៏បាន វេលាណាដែលលោក

មានប្រាថ្នាដើម្បីហោះទៅទាំងកាយ តែមិនប្រាកដដល់ភ្នែកអ្នកទាំងពួងនោះ លោកបង្អោនកាយឱ្យលុះទៅតាមអំណាចបិត្ត លើកកាយដាក់ទៅក្នុងបិត្ត ធ្វើកាយឱ្យមានដំណើររហ័សទៅតាមបិត្ត ហើយលោកចូលកាន់សុខសញ្ញានិងលហុសញ្ញា ដែលកើតព្រមដោយបិត្តដែលប្រកបដោយឫទ្ធិលំដាប់នោះ លោកក៏អាចហោះទៅបានដោយកាយដាយ៉ាងរហ័ស តាមដំណើរបិត្តមិនប្រាកដដល់ភ្នែកអ្នកទាំងពួងឡើយ ។

វិនិច្ឆ័យមកនេះ សង្ខេបពេកណាស់មិនល្មមកាត់សេចក្តីសង្ស័យរបស់អ្នកដែលច្រើន ទៅដោយសេចក្តីសង្ស័យនោះបានឡើយ តែមកមានសង្ឃឹមដល់ផ្លូវដែលមានមកគគាបតាំងអំពីខាងដើមដរាបដល់ទីបំផុតយ៉ាងនេះហើយ មុខជាមិនលែងមានអ្នកដំណើរដើរទៅដល់ស្រុក ដែលនៅក្នុងទីបំផុតផ្លូវនោះឡើយ ឬបើមិនបានដល់ ក៏គង់ជិតល្មមតែដឹងដំណឹងជាប្រាកដមកដល់បានមិនខាន អើ! បើមិនដើរហើយបេះតែសង្ស័យក្រែងមិនមានស្រុកនៅក្នុងទីបំផុតផ្លូវនោះ តើនឹងថាជាដូចម្តេច?

ឫទ្ធិដែលពោលមកក្នុងខាងលើទាំងប៉ុន្មាននេះ សុទ្ធតែអធិដ្ឋានាឥទ្ធិទាំងអស់ ។

វិកុព្វនាឥទ្ធិទី ២ និងមនោមយាឥទ្ធិទី ៣ មុនដែលនឹងអធិដ្ឋានឫទ្ធិ ក៏ត្រូវហាត់បង្វឹកចិត្តដោយអាការទាំង ១៤ យ៉ាង ញុំាងធម៌ដែលជាភូមិរបស់ឫទ្ធិជាដើម ឲ្យសម្រេច ដូចក្នុងអធិដ្ឋា-នាឥទ្ធិដែរ ប្លែកគ្នាតែវិធីដែលនឹងអធិដ្ឋានឫទ្ធិប៉ុណ្ណោះ ។

*អើ! បើដូចនោះត្រូវអធិដ្ឋានដូចម្ដេច?*

ក្នុងវិកុព្វនាឥទ្ធិទី ២ បើព្រះយោគីមានប្រាថ្នាដើម្បីផ្លាស់ភេទជាប្រក្រតី ឲ្យទៅជាកុមារតូច ជានាគ ជាគ្រុឌ ជាដើម គប្បីចូលកាន់បតុត្ថជ្ឈានដូចពោលមកហើយ ដល់វេលាដែលចេញមកវិញត្រូវបរិកម្មថា "អញជាកុមារតូច ជានាគ ជាគ្រុឌ ជាដើម" ដូចនេះ ហើយចូលត្រឡប់ទៅវិញ ដល់ចេញមកម្ដងទៀតត្រូវអធិដ្ឋានឫទ្ធិ ទៅតាមទំនងដែលខ្លួនប្រាថ្នានោះៗ ក៏នឹងបានសម្រេចដូចសេចក្ដីប្រាថ្នាដោយពិត ។

ក្នុងមនោមយាឥទ្ធិទី ៣ បើព្រះយោគីមានប្រាថ្នាដើម្បីអធិដ្ឋានចិត្ត ឲ្យទៅជាកាយមួយ ដទៃអំពីកាយជាប្រក្រតី

ក៏គប្បីចូលកាន់បតុត្ថជ្ឈានដូចគ្នា ដល់បេញមកវិញត្រូវអធិដ្ឋានកាយជាប្រក្រតីឲ្យមានប្រហោង ហើយនឹករកនូវកាយដទៃក្នុងបន្លោះនោះ ធ្វើបរិកម្មតាមទំនងដែលពោលមកហើយ លំដាប់នោះកាយដទៃដែលជាវិការនៃចិត្ត ក៏កើតមានឡើងហាក់ដូចជាពស់លូនបេញមកជាដើម ។

ឫទ្ធិទាំង ៣ យ៉ាងដូចពណ៌នាមកនេះ លោកបាត់ជាអភិញ្ញាទី ១ ឈ្មោះថា “ឥទ្ធិវិធញ្ញាណ” ។

*អធិប្បាយក្នុងអភិញ្ញាទី ២- ទិព្វសោតធាតុញ្ញាណ*

*ធម្មជាតអ្វីដែលហៅថា “ទិព្វសោតធាតុញ្ញាណ”?*

ញាណដែលអាចឲ្យស្តាប់នូវសំឡេងរបស់ទេវតា និងសំឡេងរបស់មនុស្សទាំងឡាយបាន មិនមានសេសសល់ប្រាកដដូចជាទិព្វសោតធាតុហៅថា “ទិព្វសោតធាតុញ្ញាណ

*ដូចម្តេចទិព្វសោតធាតុ?*

បសាទសោតធាតុរបស់ទេវតាទាំងឡាយ ដែលកើតអំពីសុចរិតកម្ម មិនមានប្រឡាក់ប្រឡូសដោយប្រមាត់ ស្លេស្មនិងឈាមជាដើម ផុតស្រឡះចាកគ្រឿងសៅហ្មង អាចទទួល

នូវសទ្ទារម្មណ៍ក្នុងទីឆ្ងាយបាន ហៅថា “ទិព្វសោតធាតុ” ។

*បើបសាទសោតធាតុ របស់ទេវតាទាំងឡាយកើតមកអំពីសុចរិតកម្ម ចុះញាណសោតធាតុរបស់ព្រះយោគីអង្គនេះ ដែលប្រាកដដូចជាបសាទ-សោតធាតុដែរ តើកើតមកអំពីគុណជាតអ្វី?*

ញាណសោតធាតុរបស់ព្រះយោគីអង្គនេះ កើតមកអំពីកុសលភាវនា ដែលលោកប្រារព្ធដោយកម្លាំងនៃព្យាយាមយ៉ាងមាំ ។

*បើដូច្នោះ ព្រះយោគីត្រូវញ៉ាំងញាណសោតធាតុ ដែលហៅថា “ទិព្វសោតធាតុញាណ” នេះឲ្យកើតឡើងបានដោយប្រការដូចម្ដេច?*

ដើមដំបូងត្រូវចូលកាន់បតុត្ថជ្ឈាន ដែលជាទីតាំងនៃអភិញ្ញាជាមុន ដល់វេលាដែលចេញមកវិញ ត្រូវតាំងបរិកម្មសមាធិចិត្ត(១) នឹករំពឹងរកសំឡេងដែលគ្រោតគ្រាតដល់គន្លងនៃសោតបសាទជាប្រក្រតី បើក្នុងព្រៃមានសំឡេងនៃសត្វសីហជាដើម បើក្នុងវិហារវិញមានសំឡេងរគាំងនិងសំឡេងស្គរជាដើម ត្រូវនឹករកសំឡេងដែលល្អិតចុះមកជាលំដាប់ដរាប

១- ចិត្តដែលតម្កល់នៅមាំដោយខណិកសមាធិ ដែលប្រព្រឹត្តទៅដោយអំណាចនៃបរិកម្ម ឬ ឧបចាររបស់ទិព្វសោតញាណ ។

មកដល់សំឡេងភិក្ខុ សាមណេរស្វាធ្យាយជាប្រក្រតី សំឡេងសត្វស្លាប សូរសន្ធឹកខ្យល់ សូរសន្ធឹកជំហានដើរ សូរសន្ធឹកទឹកពុះ សូរស្លឹកត្នោតដែលស្ងួតដោយត្រូវកម្តៅថ្ងៃ និងសូរសន្ធឹកស្រមោចខ្មៅ-ស្រមោចក្រហមជាទីបំផុត ត្រូវធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តគ្រប់ទិសទាំង ១០ មានបុរត្ថិមទិសជាដើម តាំងអំពីសំឡេងដែលគ្រោតគ្រាត ដរាបដល់សំឡេងដែលល្អិតសុខុម ដូចពោលមកហើយ សំឡេងទាំងនេះកុំថាដល់ទៅបរិកម្មសមាធិចិត្តឡើយ សូម្បីតែចិត្តជាប្រក្រតីក៏គង់ប្រាកដមកដល់បាន ។

កាលបើព្រះយោគី បានធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តរឿយៗ យ៉ាងនេះ លំដាប់នោះ មនោទ្វារាវជ្ជនចិត្តក៏ស្រាវយកនូវសំឡេងទាំងនោះ សំឡេងណា ១ មកធ្វើជាអារម្មណ៍ដោយសង្ឃឹមថា “ទិព្វសោតធាតុនឹងកើតឡើងឥឡូវនេះ” ហើយកើតឡើង ដល់មនោទ្វារាវជ្ជនចិត្តនោះរលត់ទៅវិញបន្ទាប់មក ជវនទាំងឡាយ ៤ ឬ ៥ ក៏សឿនទៅដោយលំដាប់គ្នា តាមសមគួរដល់បុគ្គលដែលមានបញ្ញាក្លា នឹងមាន

បញ្ចាទន់ បណ្ដាជវនទាំងនោះ ជវន ៣ ឬ ៤ ខាងដើម ជាកាមាវចរមានឈ្មោះថាបរិកម្មជវនជាដើម ឯជវនទី ៤ ឬ ទី ៥ ខាងចុងបំផុត ជាតួអប្បនាចិត្ត សម្បយុត្តដោយ ចតុត្ថជ្ឈាន ញាណដែលកើតឡើងមួយអន្លើដោយអប្បនា-ចិត្តនោះឯងដែលជាតួទិព្វសោតធាតុ ខាងមុខអំពីនោះទៅ ទិព្វសោតធាតុក៏ធ្លាក់ចុះកាន់វង្វង់នៃសោតបសាទវិញ ទិព្វ-សោតធាតុញាណនេះ ព្រះយោគីគប្បីធ្វើឲ្យកើតឡើងបាន ដោយប្រការដូច្នេះឯង ។

តមកត្រូវព្រះយោគី ខំសង្វាតបម្រើនធ្វើឲ្យកាន់តែមាន កម្លាំងក្លាឡើងជាលំដាប់ ដើមដំបូងត្រូវកំណត់ទីប្រមាណ ១ អង្គុលី ហើយនឹកថា "អញនឹងស្ដាប់នូវសំឡេងក្នុងចន្លោះ នេះ" តមកទៀតត្រូវកំណត់ទីប្រមាណ ២ អង្គុលី ៤ អង្គុលី ៨ អង្គុលី ១ បំអាម ១ គក់ កំណត់បម្រើនឡើងបន្តិចម្ដងៗ ដរាប ដល់ពេញចក្រវាឡទាំងមូលឬក្រៃលែងជាងនោះទៅទៀត ។

ព្រះយោគី ដែលបាននូវទិព្វសោតធាតុយ៉ាងនេះហើយ ក៏អាចដើម្បីនឹងស្ដាប់នូវសំឡេងរបស់មនុស្ស និងសំឡេងដែល

ជាទិព្វរបស់ទេវតា ក្នុងឱកាសដែលកំណាត់នោះបានទាំងអស់ជរាបដល់ព្រហ្មលោកជាទីបំផុត ទោះបីសំឡេងទាំងនោះគ្រោតគ្រាតក្តី ល្អិតសុខុមក្តី ស្ថិតនៅក្នុងទីជិតក្តី ឆ្ងាយក្តី តិចក្តី ច្រើនក្តី គឺកកងជាមួយគ្នាដល់ប៉ុន្មានក្តី ក៏អាចកំណាត់ដឹងបានដោយឡែកៗ អំពីគ្នាថា “នេះសំឡេងនេះ នោះសំឡេងនោះ” មិនមានច្រឡូកច្រឡំគ្នាឡើយ ។

អធិប្បាយក្នុងអភិញ្ញាទី ៣- ចេតោបរិយញ្ញាណ

ធម្មជាតអ្វីដែលហៅថា “ចេតោបរិយញ្ញាណ”?

ប្រាជ្ញាដែលកំណាត់ដឹងនូវចិត្ត នៃបុគ្គលដទៃដោយចិត្តរបស់ខ្លួន ហៅថា “ចេតោបរិយញ្ញាណ” ។

ចេតោបរិយញ្ញាណនេះ ព្រះយោគីអាចធ្វើឱ្យកើតឡើងបានដោយប្រការដូចម្តេច?

តាមដែលពិតនោះ ចេតោបរិយញ្ញាណនេះសម្រេចមកអំពីទិព្វចក្ខុ ព្រោះហេតុនោះ ព្រះយោគីដែលមានប្រាថ្នាដើម្បីធ្វើឱ្យកើតឡើង គប្បីចម្រើនផ្សាយនូវពន្លឺរបស់កសិណ[១] ផ្លុះ

---

**១- មើលក្នុងអភិញ្ញាទី ៥ ខាងចុង ។**

បំភ្លឺមើលពណ៌ឈាម ដែលអាស្រ័យនៅ ក្នុងហទយរូប នៃបុគ្គល ដទៃដោយទិព្វចក្ខុ ហើយសន្សឹមស្វែងរកចិត្តជាខាងក្រោយ ។

ចិត្តមានរូបដែរឬហ្ន៎ ទើបព្រះយោគីអាចផ្ចុះបំភ្លឺមើលទៅឃើញដោយទិព្វចក្ខុហើយស្វែងរកបាន? ។

មិនដូច្នោះទេ តែលោកអាចកំណត់ដឹងបានដោយឃើញពណ៌ឈាមដែលអាស្រ័យនៅក្នុងហទយរូបប៉ុណ្ណោះឯង ព្រោះថាវេលាដែលសោមនស្សចិត្តប្រព្រឹត្តទៅ ឈាមមានពណ៌ក្រហមប្រាកដដូចជាផ្លែជ្រៃទុំ ទោមនស្សចិត្តប្រព្រឹត្តទៅ ឈាមមានពណ៌ខ្មៅប្រាកដដូចជាផ្លែព្រីងទុំ ឧបេក្ខាចិត្តប្រព្រឹត្តទៅ ឈាមថ្លាប្រាកដដូចជាប្រេងល្ង ព្រោះហេតុនោះ ទើបលោកអាចកំណត់ដឹងបានដូចនេះ មិនតែប៉ុណ្ណោះឡើយ លោកអាចទាំងកំណត់ដឹងបានដរាបមកដល់រូបខាងក្រៅផងទៀតថា "រូបនេះមានសោមនស្សិន្ទ្រិយជាសមុដ្ឋាន នេះមានទោមនស្សិន្ទ្រិយជាសមុដ្ឋាន នេះមានឧបេក្ខិន្ទ្រិយជាសមុដ្ឋាន" ចេតោបរិយញាណនេះ ព្រះយោគី អាចធ្វើឲ្យកើតឡើងដោយប្រការដូចនេះឯង ។

កាលបើព្រះយោគី បានញុំាងចេតោបរិយញ្ញាណឲ្យកើតឡើងយ៉ាងនេះហើយ គប្បីចម្រើនធ្វើឲ្យកាន់តែមានកម្លាំងឡើងជាលំដាប់ដរាបដល់កំណត់ដឹងបាននូវកាមាវចរចិត្ត រូបាវចរ-ចិត្ត អរូបាវចរចិត្តទាំងអស់ សូម្បីមិនចាំបាច់ឃើញនូវពណ៌របស់ឈាមដែលអាស្រ័យនៅក្នុងហទយរូបនោះឡើយ ។

*ចុះបើព្រះយោគីមានប្រាថ្នា ដើម្បីកំណត់ដឹងនូវចិត្ត នៃបុគ្គលដទៃក្នុងអរូបភព តើលោកឃើញនូវហទយរូបរបស់បុគ្គលណា? រមិលមើលនូវឥន្ទ្រិយវិការរបស់បុគ្គលណា?*

លោកមិនចាំបាច់ឃើញនូវហទយរូប មិនចាំបាច់រមិលមើលនូវឥន្ទ្រិយវិការរបស់បុគ្គលណានីមួយឡើយ នេះហើយជាវិស័យរបស់បុគ្គលដែលមានឫទ្ធិ ធម្មតាបុគ្គលដែលមានឫទ្ធិ កាលបើនឹករកនូវចិត្តក្នុងទីណា ១ ក៏អាចដឹងនូវចិត្តទាំង ១៦ ប្រភេទបាន ។

ចិត្តទាំង ១៦ ប្រភេទនោះគឺ

១- **សរាគំ ចិត្តំ** ចិត្តប្រកបដោយរាគៈ បានដល់លោភសហគតចិត្ត ៨ ។

២- **វីតរាគំ ចិត្តំ** ចិត្តប្រាសចាករាគៈ បានដល់កុសល-
ចិត្ត និងអព្យាកតចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

៣- **សទោសំ ចិត្តំ** ចិត្តប្រកបដោយទោស បានដល់
ទោមនស្សចិត្ត ២ ។

៤- **វីតទោសំ ចិត្តំ** ចិត្តប្រាសចាកទោស បាន
ដល់កុសលចិត្តនិងអព្យាកតចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។

៥- **សមោហំ ចិត្តំ** ចិត្តប្រកបដោយមោហៈ បានដល់
វិចិកិច្ឆាសហគតចិត្ត និងឧទ្ធច្ចសហគតចិត្តទាំង ២ ន័យមួយ
ទៀតថា អកុសលចិត្តទាំង ១២ ឈ្មោះថាចិត្តប្រកបដោយ
មោហទាំងអស់ ព្រោះថាមោហកើតទួទៅក្នុងអកុសលចិត្ត
ទាំងពួង ។

៦- **វីតមោហំ ចិត្តំ** ចិត្តប្រាសចាកមោហៈ បានដល់
ចិត្តដែលសល់អំពីអកុសលចិត្តទាំង ១២ ។

៧- **សង្ខិត្តំ ចិត្តំ** ចិត្តរួញរា បានដល់ចិត្តដែលថីនមិទ្ធ
គ្របសង្កត់ ។

៨- **វិក្ខិត្តំ ចិត្តំ** ចិត្តរាត់រាយ បានដល់ចិត្តដែលឧទ្ធច្ច គ្របសង្កត់ ។

៩- **មហគ្គតំ ចិត្តំ** ចិត្តដល់នូវភាវៈជាធំ បានដល់ រូបាវចរចិត្តនិងអរូបាវចរចិត្ត ។

១០- **អមហគ្គតំ ចិត្តំ** ចិត្តមិនដល់នូវភាវៈជាធំ បាន ដល់ចិត្តដែលសល់អំពីរូបាវចរចិត្តនិងអរូបាវចរចិត្ត ។

១១- **សឧត្តរំ ចិត្តំ** ចិត្តប្រកបដោយចិត្តដែលប្រសើរ ជាង បានដល់ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ។

១២- **អនុត្តរំ ចិត្តំ** ចិត្តមិនមានចិត្តដែលប្រសើរជាង បានដល់លោកុត្តរចិត្ត ។

១៣- **សមាហិតំ ចិត្តំ** ចិត្តតម្កល់នៅមាំ បានដល់ ចិត្តដែលដល់នូវឧបចារសមាធិ និងចិត្តដែលដល់នូវអប្បនា-សមាធិ ។

១៤- **អសមាហិតំ ចិត្តំ** ចិត្តមិនតម្កល់នៅមាំ បាន ដល់ចិត្តដែលមិនដល់នូវសមាធិទាំង ២ យ៉ាង ។

១៥- **វិមុត្តំ ចិត្តំ** ចិត្តផុតស្រឡះ បានដល់ចិត្តដែលដល់នូវវិមុត្តិទាំង ៥ យ៉ាង(១) ។

១៦- **អវិមុត្តំ ចិត្តំ** ចិត្តមិនផុតស្រឡះ បានដល់ចិត្តដែលមិនដល់នូវវិមុត្តិទាំង ៥ យ៉ាង ។

ព្រះយោគី ដែលបាននូវចេតោបរិយញ្ញាណ យ៉ាងនេះហើយ ក៏អាចដើម្បីកំណត់ដឹង នូវចិត្តគ្រប់ប្រការបាន ដូចពោលមកនេះឯង តែបើព្រះយោគីអង្គនោះជាបុថុជ្ជន នឹងកំណត់ដឹងនូវចិត្តរបស់ព្រះអរិយបុគ្គលពុំបានឡើយ សូម្បីតែព្រះអរិយបុគ្គលដូចគ្នា តែថ្នាក់ជាន់ទាប ក៏មិនអាចដើម្បីកំណត់ដឹងនូវចិត្តរបស់ព្រះអរិយបុគ្គលថ្នាក់ជាន់ខ្ពស់ជាងខ្លួនបាន ។

អធិប្បាយក្នុងអភិញ្ញាទី ៤- បុព្វេនិវាសានុស្សតិញ្ញាណ

*ធម្មជាតអ្វីដែលហៅថា “ បុព្វេនិវាសានុស្សតិញ្ញាណ”?*

---

១- វិមុត្តិមាន ៥ យ៉ាងគឺ វិក្ខម្ភនវិមុត្តិ រួចចាកនីវរណធម៌ទាំង ៥ ដោយសង្កត់សង្កិន បានដល់សមាបត្តិទាំងប្រាំបី១ តទង្គវិមុត្តិ រួចចាកនិច្ចសញ្ញាជាដើមដោយកំណត់នូវអង្គដែលជាសត្រូវដល់ធម៌នោះៗ បានដល់អនុបស្សនាទាំងប្រាំពីរ ១ សមុច្ឆេទវិមុត្តិ រួចចាកកិលេសដោយផ្តាច់បង់ខ្លួនឯង បានដល់មគ្គបួន ១ បដិបស្សទ្ធិវិមុត្តិ រួចចាកកិលេសដោយកើតឡើងក្នុងទីបំផុតនៃកិលេសដែលមគ្គរម្ងាប់បានរួចហើយ បានដល់ផលបួន ១ និស្សរណវិមុត្តិ រួចចាកកិលេសដោយរលាស់ចេញ បានដល់ព្រះនិព្វាន ១ ។

ញាណដែលសម្បយុត្តដោយស្មារតី ដែលអាចរឭកឃើញនូវខន្ធសន្តានរបស់ខ្លួន ដែលធ្លាប់អាស្រ័យនៅក្នុងអតីតជាតិ ហៅថា “បុព្វេនិវាសានុស្សតិញាណ” ។

*ចុះដែលរឭកឃើញនោះតើរឭកឃើញដូចម្ដេច? ទៅទល់ត្រឹមណា?*

ខន្ធសន្តានដែលរាប់បញ្ចូលក្នុងភពមួយៗ មានបដិសន្ធិជាមូលមានចុតិជាទីបំផុត មានអាការពណ៌សម្បុរល្អ-អាក្រក់យ៉ាងណា សោយសុខ-ទុក្ខយ៉ាងណា មានអាយុតិច-ច្រើនយ៉ាងណា មានការចិញ្ចឹមជីវិតយ៉ាងណា មានអាហារសម្រាប់បរិភោគយ៉ាងណា កើតនៅក្នុងកំណើតណា គតិណា វិញ្ញាណដ្ឋិតិណា សត្តាវាសណា សត្វនិកាយណា មាននាមនិងគោត្រជាអ្វី ក៏រឭកឃើញបានគ្រប់ទាំងអស់ តាំងអំពីជាតិ ១ ជាតិ ២ ដរាបដល់ជាតិដែលកើតនៅក្នុងសំវដ្ដកប្ប(១) និងវិវដ្ដកប្ប(២) ជាអនេក ។

*ត្រូវញុំាងញាណនេះឲ្យកើតឡើងដោយប្រការដូចម្ដេច?*

បើព្រះយោគីជាអាទិកម្មិក ដល់វេលាជាខាងក្រោយភត្ត

---

១- កប្បដែលកំពុងវិនាស ។ ២- កប្បដែលកំពុងចម្រើន ។

ត្រូវចូលទៅរកទីដែលស្ងាត់ចាកអារម្មណ៍ផ្សេងៗ ហើយចូលកាន់ឈានទាំង ៤ តាំងអំពីបឋមជ្ឈានដរាបដល់ចតុត្ថជ្ឈានដល់ចេញមកវិញ ត្រូវនឹករំពឹងរកកិច្ចដែលខ្លួនធ្វើកន្លងហើយក្នុងថ្ងៃនោះ តាំងអំពីបង្គុយជាខាងក្រោយបំផុត ឡើងទៅជាលំដាប់ដរាបដល់កិច្ចដែលធ្វើហើយក្នុងបច្ចូសសម័យ មជ្ឈិមយាម បឋមយាម រហូតដល់កិច្ចដែលធ្វើហើយអស់ថ្ងៃ ១ យប់ ១ កិច្ចទាំងប៉ុន្មាននេះ កុំឋាដល់ទៅបរិកម្មសមាធិចិត្ត សូម្បីតែចិត្តជាប្រក្រតីក៏ប្រាកដមកដល់បាន ។

កាលបើព្រះយោគី នឹករំពឹងរកកិច្ចដែលធ្វើកន្លងហើយយ៉ាងនេះ បើមានកិច្ចណាមួយដែលមិនប្រាកដត្រូវចូលកាន់ចតុត្ថជ្ឈាន ហើយចេញមកវិញនឹករំពឹងរកថែមទៀត ត្រាតែបានប្រាកដជាក់ច្បាស់ឡើង ។

តទៅ ត្រូវនឹករំពឹងរកកិច្ចដែលធ្វើកន្លងហើយក្នុងថ្ងៃទី ២ ទី ៣ ទី ៤ ទី ៥ ទី ១០ កន្លះខែ ១ ខែ ១ ឆ្នាំ ១០ ឆ្នាំ ២០ ឆ្នាំ ដរាបទៅទល់បដិសន្ធិក្នុងភពនេះហើយបើកន្លងបដិសន្ធិក្នុងភពនេះនឹករំពឹងរកនាមនិងរូប ដែលប្រព្រឹត្តទៅក្នុងចុតិក្ខណៈ ក្នុងភព

មុន ត្រូវនឹករំពឹងរកយ៉ាងនេះ កុំគប្បីដាក់ធុរៈឈប់លែងនឹកនោះឡើយ បើត្រង់ណាកំបាំងមិនប្រាកដត្រូវឧស្សាហ៍ចូលកាន់បតុត្ថជ្ឈានឲ្យរឿយៗ ដល់ចេញមកវិញត្រូវនឹករំពឹងរកត្រង់នោះ ត្រាតែបានប្រាកដជាក់ច្បាស់ឡើង ។

ញាណដែលចាប់យកនូវបង្គុយជាខាងក្រោយបំផុត ជរាបមកដល់បដិសន្ធិក្នុងភពនេះមកធ្វើជាអារម្មណ៍នោះ មិនបានឈ្មោះថា "បុព្វេនិវាសានុស្សតិញាណ" ឡើយ គឺបានឈ្មោះថា "បរិកម្មសមាធិញាណ"(១) ត្រាតែមនោទ្វារាវជ្ជនចិត្តកន្លងនូវបដិសន្ធិក្នុងភពនេះ ស្រាវយកនូវនាមនិងរូបក្នុងចុតិក្ខណក្នុងភពមុនមកធ្វើជាអារម្មណ៍ ហើយកើតឡើង ១ ខណៈរលត់ទៅវិញ បន្ទាប់មកជវន ៤ ឬ ៥ ចាប់យកនាមនិងរូបនោះដដែលមកធ្វើជាអារម្មណ៍ ហើយលឿនទៅរៀងតាមលំដាប់គ្នា ជវន ៣ ឬ ៤ ខាងដើមជាកាមាវចរ មានឈ្មោះថា "បរិកម្មជវន" ជាដើម ដូចពោលមកហើយ ជវនទី ៤ ឬ ទី ៥ ខាងក្រោយបំផុតជារូបាវចរ គឺជាតួអប្បនាចិត្តដែលសម្បយុត្ត

---

១- អាចារ្យខ្លះឲ្យឈ្មោះថា "អតីតំសញាណ" ញាណជាចំណែកខាងអតីត។

ដោយបតុត្តជ្ឈាន ញាណដែលកើតឡើងមួយអន្លើដោយអប្បនាចិត្តនោះ ទើបបានឈ្មោះថា "បុព្វេនិវាសានុស្សតិ-ញាណ" សូម្បីរឮកបានក្រៃលែងជាងនេះ ជាលំដាប់ដរាបដល់អស់សំវដ្តកប្បវិវដ្តកប្បជាអនេក ក៏មានន័យដូចគ្នានឹងន័យនេះដែរ ព្រះយោគីត្រូវញុំាងបុព្វេនិវាសានុស្សតិញាណឲ្យកើតឡើងដោយប្រការដូច្នេះឯង ។

*ជនដែលរឮកបាននូវបុព្វេនិវាសនេះ មានប៉ុន្មានពួក? ពួកណាខ្លះ?*

ជនដែលរឮកបាននូវបុព្វេនិវាសនេះ មាន ៦ ពួក គឺ តិរ្ថិយពួក ១ បកតិសាវកពួក ១ មហាសាវក ៨០ ពួក ១ អគ្គសាវកទាំងគូពួក ១ ព្រះបច្ចេកពុទ្ធពួក ១ ព្រះពុទ្ធពួក ១ ។

*ចុះជនទាំង ៦ ពួកនេះរឮកឃើញបានស្មើគ្នាទាំងអស់ឬដូចម្តេច? ព្រោះហេតុអ្វី?*

មិនមែនរឮកបានស្មើគ្នាទាំងអស់ទេ ព្រោះជនទាំង ៦ ពួកនេះ មានបញ្ញានិងអភិនីហារផ្សេងៗគ្នា ។

អធិប្បាយថា តិរ្ថិយ ឬតាបសពួកខ្លះដែលជាកម្មវាទី កិរិយវាទី អ្នកបាននូវបុព្វេនិវាសានុស្សតិញាណ រឮកជាតិ

បានយ៉ាងច្រើនបំផុតត្រឹម ៤០ កប្ប ព្រោះពួកនេះមានប្រាជ្ញាទន់ដោយមិនបានកំណត់នូវនាមនិងរូប បកតិសាវករពួកបានអស់ ១ រយកប្បខ្លះ ១ ពាន់កប្បខ្លះ ព្រោះលោកមានប្រាជ្ញាច្រើនដោយបានកំណត់នូវនាមនិងរូប អសីតិមហាសាវក រឭកបានអស់ ១ សែនកប្ប អគ្គសាវកទាំងគូរឭកបានអស់ ១ អសង្ខេយ្យនិង ១ សែនកប្ប ព្រះបច្ចេកពុទ្ធរឭកបាន ២ អសង្ខេយ្យ និង ១ សែនកប្ប ព្រោះអភិនីហាររបស់លោកទាំង ៣ ពួកនេះតែបំនួនប៉ុណ្ណោះ ឯព្រះពុទ្ធរឭកបានអស់កាលរកកំណត់មិនបាន ព្រោះប្រាជ្ញារបស់ព្រះអង្គមិនមានអ្វីមករាំងរាបានឡើយ ។

សេចក្ដីប្លែកគ្នានៃកិរិយារឭកបាននូវបុព្វេនិវាស របស់ជនទាំង ៦ ពួកនេះ នៅមានច្រើនតទៅទៀតណាស់ តែមិនល្មមនឹងមកអធិប្បាយក្នុងទីនេះឲ្យសព្វគ្រប់បាន ។

អធិប្បាយក្នុងអភិញ្ញាទី៥- សត្តានំ ចុតូបបាតញាណ ។

*ធម្មជាតអ្វីដែលហៅថា “សត្តានំ ចុតូបបាតញាណ” -បានដល់អ្វី?*

ញាណដែលដឹងបាននូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ

ហៅថា "សត្តានំ ចុតូបបាតញាណ" បានដល់ទិព្វចក្ខុញាណ ។

*អ្វីសោត ហៅថា "ទិព្វចក្ខុញាណ"?*

ញាណចក្ខុ ដែលកើតអំពីកុសលភាវនា ដែលព្រះយោគីប្រារព្ធដោយកម្លាំងនៃព្យាយាមយ៉ាងមាំ អាចឲ្យសម្រេចកិច្ចខាងមើលឃើញនូវចុតិនិងបដិសន្ធិរបស់សត្វបាន ឬអាចមើលឃើញនូវរូបដែលជាវិស័យនៃមនុស្ស និងរូបដែលជាវិស័យនៃទេវតាបាន ទោះបីរូបនោះគ្រោតគ្រាតឬល្អិត ស្ថិតនៅក្នុងទីជិតឬឆ្ងាយ ក្នុងទីវាលឬកំបាំងដល់ប៉ុន្មានក្តី ក៏អាចមើលឃើញទាំងអស់ប្រាកដដូចជាបសាទចក្ខុដែលជាទិព្វ កើតអំពីសុចរិតកម្មរបស់ទេវតាទាំងឡាយ ដែលមិនមានប្រឡាក់ប្រឡូសដោយប្រមាត់ស្លេស្ម និងឈាមជាដើម ផុតស្រឡះចាកគ្រឿងសៅហ្មង អាចទទួលនូវអារម្មណ៍ ដែលនៅក្នុងទីឆ្ងាយបានហៅថា "ទិព្វចក្ខុញាណ" ។

*ជនពួកណាដែលបាននូវទិព្វចក្ខុ ហើយអាចឃើញទាំងចុតិទាំងបដិសន្ធិរបស់សត្វបាន?*

ដែលបាននូវទិព្វចក្ខុ ហើយអាចឃើញទាំងចុតិទាំងបដិសន្ធិរបស់សត្វបាន បំពោះតែពួកពុទ្ធបុត្រគឺពួកសាវករបស់

ព្រះពុទ្ធប៉ុណ្ណោះ ឯពួកតិរ្ថិយខាងក្រៅមិនអាចឃើញទាំងចុតិបដិសន្ធិដូចនោះបានឡើយ ខ្លះឃើញបានតែត្រឹមចុតិ ខ្លះឃើញបានតែត្រឹមបដិសន្ធិ ព្រោះថាដែលឃើញទាំង ២ យ៉ាងបានលុះតែលោកដែលមានទិដ្ឋិដ៏បរិសុទ្ធ ។

មានពាក្យដំណាលថា

បុគ្គលណាដែលឃើញតែចុតិម្យ៉ាង មិនឃើញនូវបដិ-សន្ធិផង បុគ្គលនោះនឹងប្រកាន់នូវឧច្ឆេទទិដ្ឋិ ព្រោះមិនឃើញមានសត្វដែលកើតទៀត បុគ្គលណាដែលឃើញតែបដិសន្ធិម្យ៉ាងមិនឃើញនូវចុតិផង បុគ្គលនោះនឹងប្រកាន់នូវនវសត្ត-បាតុភាវសស្សតទិដ្ឋិ គឺប្រកាន់ថា "សត្វដែលកើតប្រាកដឡើងទាំងប៉ុន្មានសុទ្ធតែសត្វថ្មីទាំងអស់" ព្រោះមិនឃើញមានសត្វដែលច្យុតពីភពណាៗ មកកើត ឯពួកពុទ្ធសាវកលោកអាចឃើញបានទាំង ២ យ៉ាង ព្រោះលោកមានទិដ្ឋិដ៏បរិសុទ្ធ ផុតបាកទិដ្ឋិទាំង ២ ប្រការនេះ ។

*ដែលពោលមកនេះដូចជាចំពោះតែពុទ្ធសាវកម្យ៉ាង ទើបអាចឃើញទាំងចុតិទាំងបដិសន្ធិរបស់សត្វទាំងឡាយ បានមិនមែនទេឬ? អើ បើដូចនោះព្រះពុទ្ធគ្រប់ព្រះអង្គមិនអាចឃើញបានទេឬ?*

ឱ! ត្រឹមតែសាវករបស់ព្រះអង្គប៉ុណ្ណោះក៏អាចឃើញបាន ទៅហើយ ចាំបាច់ពោលថ្វីដល់ព្រះពុទ្ធដែលព្រះអង្គជាកំពូល ផ្ទើមក្នុងលោករកបុគ្គលណាមួយប្រៀបផ្ទឹមមិនបាននោះ ដែល ពោលមកនេះ គ្រាន់តែបង្អួលឲ្យឃើញបុគ្គលដែលមានទិដ្ឋិ ដ៏បរិសុទ្ធទេតើ ។

*ចុះដែលលោកឃើញនូវចុតិនិងបដិសន្ធិនោះ តើឃើញក្នុងខណៈ ដែលសត្វច្យុត ក្នុងខណៈដែលសត្វកាន់យកនូវបដិសន្ធិនោះឬ?*

មិនដូចនោះទេ លោកមិនអាចឃើញដោយទិព្វចក្ខុ ក្នុងខណៈដែលសត្វច្យុត និងខណៈដែលសត្វកាន់យកនូវបដិ-សន្ធិនោះឡើយ លោកអាចឃើញបានតែត្រឹមខណៈដែល សត្វទៀបនឹងច្យុត និងខណៈដែលសត្វកាន់យកនូវបដិសន្ធិ រួចហើយប៉ុណ្ណោះឯង ព្រោះថាលក្ខណៈរបស់ទិព្វចក្ខុនេះ អាច ឃើញបានតែរបស់ដែលមានរូប បើមិនមានរូបក៏មិនអាច ឃើញបានឡើយ តែបើលោកឃើញនូវសត្វណាដែលទៀប នឹងច្យុតលោកអាចដឹងបានថា “សត្វនេះនឹងច្យុតឥឡូវនេះ ហើយទៅកើតក្នុងភពនេះ សោយសុខឬសោយទុក្ខបែបនេះ

បើឃើញសត្វណាដែលកាន់យកនូវបដិសន្ធិរូបហើយ ទោះបីថយថោកឬឧដុង្គឧត្តមក្តី មានពណ៌សម្បុរល្អឬអាក្រក់ក្តី មានទ្រព្យស្តុកស្តម្ភឬកំសត់ទុរគតក្តី លោកក៏អាចដឹងបានថា “សត្វនេះប្រកបដោយអានិសង្សរបស់ធម៌នេះ សត្វនេះសោយនូវផលរបស់កម្មនេះ” ។

ក្នុងទិព្វចក្ខុញាណ គឺត្ថ សត្តាធំ បុត្វបបាតញាណនេះ មានញាណដែលជាបរិវារ (បរិភណ្ឌ) ២ យ៉ាងគឺ

១- អនាគតំសញាណ ញាណដែលដឹងបានទៅក្នុងបំណែកខាងអនាគត ។

២- យថាកម្មុបគញាណ ញាណដែលដឹងបាននូវសត្វដែលចូលមកកើតតាមសមគួរដល់កម្ម ។

អធិប្បាយ ត្រង់ដែលព្រះយោគីចម្រើនផ្សាយនូវពន្លឺរបស់កសិណាផ្លុះបំភ្លឺមើលទៅឃើញសត្វ ដែលកំពុងសោយទុក្ខក្នុងនរក ឬកំពុងសោយសម្បត្តិដ៏ប្រសើរក្នុងស្ថានសួគ៌ជាដើម ជាកិច្ចរបស់ទិព្វចក្ខុញាណ ត្រង់ដែលព្រះយោគីឃើញនូវសត្វទាំងឡាយ ដែលប្រព្រឹត្តធ្វើនូវអំពើទុច្ចរិត ឬសុចរិតផ្សេងៗ

ក្នុងបច្ចុប្បន្នជាតិនេះ ហើយអាចដឹងបានទៅខាងអនាគតថា “សត្វដែលប្រព្រឹត្តធ្វើនូវអំពើយ៉ាងនេះ ដល់ទម្លាយខន្ធទៅនឹងទៅកើតក្នុងភពនេះ បែបយ៉ាងនេះ សត្វនោះប្រព្រឹត្តធ្វើនូវអំពើយ៉ាងនោះ ដល់ទម្លាយខន្ធទៅនឹងទៅកើតក្នុងភពនោះបែបយ៉ាងនោះ” ដូច្នេះឈ្មោះថា “អនាគតំសញ្ញាណ” ត្រង់ដែលព្រះយោគីឃើញសត្វកំពុងសោយទុក្ខក្នុងនរក ឬកំពុងសោយសម្បត្តិក្នុងស្ថានសួគ៌ជាដើម ហើយធ្វើទុកក្នុងចិត្តថា “សត្វទាំងឡាយនេះបានជាមកសោយទុក្ខ ឬសោយសម្បត្តិយ៉ាងនេះ តើព្រោះធ្វើនូវអំពើកម្មដូចម្តេចហ្ន៎?” លំដាប់នោះញាណមួយចាប់យកនូវកម្មដែលសត្វធ្វើនោះ មកធ្វើជាអារម្មណ៍ដូច្នេះថា “ព្រោះធ្វើនូវកម្មនេះៗ” ហើយកើតឡើង ញាណដែលដឹងបានយ៉ាងនេះឈ្មោះថា “យថាកម្មុបគញាណ” ។

*ទិព្វចក្ខុញាណនេះ ព្រះយោគីអាចបម្រើនឲ្យកើតឡើងបានដោយប្រការដូចម្តេច?*

បើព្រះយោគីដែលជាអាទិកម្មិក គប្បីធ្វើនូវបតុត្ថជ្ឈានជាទីតម្កល់នៃអភិញ្ញា ដែលមានកសិណទាំង ៨ ជាអារម្មណ៍

ឲ្យគួរដល់កិរិយាកើតឡើងនៃទិព្វចក្ខុ ដោយអាការ ១៤ យ៉ាងជាដើម ហើយយកតេជោកសិណ ឱទាតកសិណ អាលោកកសិណ ទាំង ៣[១] នេះ កសិណណាមួយ មកផ្តែបទុកឲ្យជិត ហើយគប្បីចម្រើននូវកសិណារម្មណ៍នោះ ឲ្យស្ទាត់នៅតែត្រឹមថ្នាក់ឧបចារជ្ឈាន កុំគប្បីញ៉ាំងអប្បនាឲ្យកើតឡើងក្នុងកសិណារម្មណ៍ដែលចម្រើនហើយនោះឡើយ បើញ៉ាំងអប្បនាឲ្យកើតឡើងក្នុងកសិណារម្មណ៍នោះ នឹងទៅជានិស្ស័យរបស់បាទកជ្ឈាន មិនមែនជានិស្ស័យរបស់បរិកម្ម ព្រោះថា អភិញ្ញាទាំងអស់មិនដែលសម្រេចដល់ព្រះយោគី ដែលមិនបានធ្វើបរិកម្មនោះឡើយ ។

ព្រោះហេតុនោះ ត្រូវព្រះយោគីចម្រើននូវកសិណារម្មណ៍នោះ ទប់ទុកឲ្យនៅតែត្រឹមឧបចារភូមិប៉ុណ្ណោះ ផ្សាយពន្លឺឲ្យកាន់តែមានកម្លាំងឡើងបន្តិចម្តងៗ ហើយសម្លឹងមើលនូវរូបដែលតាំងនៅក្នុងឱកាសដែលផ្សាយពន្លឺទៅដល់នោះ តែបើព្រះយោគីកំពុងសម្លឹងមើលនូវរូបទាំងនោះ ហើយវារៈរបស់

១- ក្នុងកសិណទាំង ៣ នេះ អាលោកកសិណប្រសើរជាងទាំងអស់ ។

បរិកម្មកន្លងហួសទៅ ពន្លឺក៏បាត់ទៅផង ត្រូវបូលកាន់បាទក-ជ្ឈានឲ្យរឿយៗដល់បេញមកវិញត្រូវផ្សាយពន្លឺឲ្យកាន់តែមានកម្លាំងក្លាឡើងជាលំដាប់ ដរាបដល់ព្រះយោគីអាចដើម្បីកំណត់ឲ្យពន្លឺកើតឡើងក្នុងទីត្រឹមណា ពន្លឺក៏ផ្សាយទៅតាំងនៅក្នុងទីត្រឹមនោះ ហើយអង្គុយសម្លឹងមើលនូវរូបអស់ថ្ងៃ ១ បាន ។

ក្នុងវេលាណា ដែលរូបយ៉ាងកំបាំងមិនបានមកកាន់រង្វង់របស់មំសចក្ខុ ដូចរូបដែលតាំងនៅក្នុងផ្ទៃ អាស្រ័យនៅក្នុងហទយវត្ថុ អាស្រ័យនៅខាងក្រោមផ្ទៃផែនដី ខាងក្រៅភ្នំក្រៅកំផែង នៅក្នុងចក្រវាឡដទៃ រូបទាំងនោះក៏មកកាន់រង្វង់នៃញាណចក្ខុរបស់ព្រះយោគីនោះ ហាក់ដូចជាប្រាកដដល់មំសចក្ខុ វេលានោះត្រូវដឹងថា "ទិព្វចក្ខុកើតឡើងហើយ" ទិព្វចក្ខុនោះឯងហើយដែលអាចដើម្បីឃើញនូវរូបបាន ចិត្តដែលជាបំណែកខាងដើម មិនអាចដើម្បីឃើញនូវរូបបានឡើយ តែទិព្វចក្ខុនោះជាសត្រូវដល់បុថុជ្ជន ។

*ព្រោះហេតុអ្វីទិព្វចក្ខុនោះ ទើបជាសត្រូវដល់បុថុជ្ជន?*

ព្រោះថា បើព្រះយោគីអធិដ្ឋានឲ្យពន្លឺកើតឡើងក្នុងទី

ណាៗ ទីនោះៗ ទោះបីរំលងផែនដី រំលងសមុទ្រ រំលងភ្នំក្តី ក៏មានពន្លឺផ្លុះបាំងជាមួយគ្នាទាំងអស់ ហើយបើព្រះយោគី សម្លឹងមើលទៅឃើញ រូបយក្ស រូបអារក្សទឹកជាដើម ដែល សម្បើមៗ គួរខ្លាច នៅក្នុងទីនោះៗ ភ័យក៏មុខជានឹងកើត ឡើង កាលបើដូច្នេះ ព្រះយោគីអង្គនោះ ជួនកាលក្រឡុកចិត្ត ដល់នូវភាវៈឆ្កួតដោយអំណាចនៃឈានក៏សឹងមាន ហេតុនោះ ព្រះយោគីមិនគប្បីធ្វេសប្រហែសតែក្នុងវិធីដែលមើលនូវរូបនោះ ឡើយ ត្រូវចម្រើនវិបស្សនាតទៅទៀត ។

លំដាប់ដែលកើតឡើងនៃទិព្វចក្ខុនោះដូច្នេះគឺ ដើម ដម្បូងមនោទ្វារាវជ្ជនចិត្ត ស្រាវយកនូវរូបដូចពោលមកហើយ នោះមកធ្វើជាអារម្មណ៍ ហើយកើតឡើង ដល់រលត់ទៅវិញ ជវន ៤ ឬ ៥ ចាប់យកនូវរូបនោះដដែល មកធ្វើជាអារម្មណ៍ ហើយកើតឡើង រៀងតាមលំដាប់គ្នា ដូចន័យដែលបាន ពោលមកហើយក្នុងខាងដើម ចិត្តដែលជាចំណែកខាងដើម ជាកាមាវចរនៅប្រកបដោយវិតក្កនិងវិចារ អត្ថសាធកចិត្ត[១]

---

១- ចិត្តដែលញ៉ាំងប្រយោជន៍ឲ្យសម្រេច ។

ខាងចុងបំផុតជារូបាវចរ សម្បយុត្តដោយចតុត្ថជ្ឈាន ញាណ ដែលកើតមួយអន្លើដោយអត្ថសាធកចិត្តនោះ លោកហៅថា "សត្តានំ ចុតូបបាតញាណ" ដូច្នេះក៏បាន ហៅថា "ទិព្វចក្ខុ-ញាណ" ដូច្នេះក៏បាន ។

សត្តានំ ចុតូបបាតញាណ ឬ ទិព្វចក្ខុញាណនេះ ព្រះយោគីអាចចម្រើនឲ្យកើតឡើងដោយប្រការដូច្នេះឯង ។

អភិញ្ញា ដែលបានអធិប្បាយរៀងតាមលំដាប់មកតែ ៥ យ៉ាង តែលោករាប់យកញាណដែលជាបរិវាររបស់ទិព្វចក្ខុ ២ យ៉ាងថែមមកទៀតត្រូវជា ៧ យ៉ាង ដូចពណ៌នាមកនេះឯង ។

អភិញ្ញាកថាចប់

*សមាធិនិទ្ទេសសង្ខេប ចប់ តែប៉ុណ្ណោះ*

---

*ជុំទី៣ ចប់*